១២៧-លោក នៅ ជា មន្ត្រីការិ.ដឹកជញ្ជូន នៃមន្ទីរសាធារណការ និងដឹកជញ្ជូនខេត្តព្រះសីហនុ
១២៨-លោក ជុន សុខុម មន្ត្រីការិ.ដឹកជញ្ជូន នៃមន្ទីរសាធារណការ និងដឹកជញ្ជូនខេត្តព្រះសីហនុ
១២៩-លោកស្រី សាម យុទ្ធារី មន្ត្រីការិ.ដឹកជញ្ជូន នៃមន្ទីរសាធារណការ និងដឹកជញ្ជូនខេត្តព្រះសីហនុ

១៣០-លោក **ពេជ្រ សំអឿន** មន្ត្រីការិ.ដឹកជញ្ជូន នៃមន្ទីរសាធារណការ និងដឹកជញ្ជូនខេត្តព្រះសីហនុ
១៣១-លោកស្រី **គីម អាន** មន្ត្រីការិ.រដ្ឋបាល-បុគ្គលិក នៃមន្ទីរសាធារណការ និងដឹកជញ្ជូនខេត្តព្រះសីហនុ
១៣២-លោក **ម៉ក់ ចន្ទ** មន្ត្រីការិ.សាធារណការ នៃមន្ទីរសាធារណការ និងដឹកជញ្ជូនខេត្តព្រះសីហនុ
១៣៣-លោក **គ្រាជ្ញ សុន** មន្ត្រីការិ.សាធារណការ នៃមន្ទីរសាធារណការ និងដឹកជញ្ជូនខេត្តព្រះសីហនុ
១៣៤-លោក **គីម ឃុល** មន្ត្រីការិ.សាធារណការ នៃមន្ទីរសាធារណការ និងដឹកជញ្ជូនខេត្តព្រះសីហនុ
១៣៥-លោក **គ្រួច ញឹម** មន្ត្រីការិ.សាធារណការ នៃមន្ទីរសាធារណការ និងដឹកជញ្ជូនខេត្តស្ទឹងត្រែង
១៣៦-លោកស្រី **ខេន ឃុនណាក់** មន្ត្រីការិ.ដឹកជញ្ជូន នៃមន្ទីរសាធារណការ និងដឹកជញ្ជូនខេត្តក្រចេះ
១៣៧-លោកស្រី **នែម សំអួរ** មន្ត្រីការិ.រដ្ឋបាល-បុគ្គលិក នៃមន្ទីរសាធារណការ និងដឹកជញ្ជូនខេត្តក្រចេះ
១៣៨-លោក **ទ្រាំ ជឿន** មន្ត្រីការិ.សាធារណការ នៃមន្ទីរសាធារណការ និងដឹកជញ្ជូនខេត្តព្រះវិហារ
១៣៩-លោក **មាស ឡុង** មន្ត្រីការិ.សាធារណការ នៃមន្ទីរសាធារណការ និងដឹកជញ្ជូនខេត្តព្រះវិហារ
១៤០-លោក **រី នឿន** មន្ត្រីបច្ចេកទេស ការិ.សាធារណការ នៃមន្ទីរសាធារណការនិងដឹកជញ្ជូនខេត្តព្រះវិហារ
១៤១-លោកស្រី **កែវ គុណគីរួន** មន្ត្រីការិ.ផែនការ-គណនេយ្យនៃមន្ទីរសាធារណការនិងដឹកជញ្ជូនខេត្តព្រះវិហារ
១៤២-លោក **នី ណារ៉ា** មន្ត្រីបច្ចេកទេស ការិ.ដឹកជញ្ជូន នៃមន្ទីរសាធារណការនិងដឹកជញ្ជូនខេត្តរតនគីរី
១៤៣-លោក **ថង ប្រសើត** ប្រធានការិ.សាធារណការស្រុកតាវែង នៃមន្ទីរសាធារណការនិងដឹកជញ្ជូនខេត្តរតនគីរី
១៤៤-លោកស្រី **ទ្រាំ ស្រីម៉ៅ** មន្ត្រីការិ.រដ្ឋបាល-បុគ្គលិក នៃមន្ទីរសាធារណការនិងដឹកជញ្ជូនខេត្តរតនគីរី
១៤៥-លោកស្រី **ដួង គីមលី** មន្ត្រីការិ.ផែនការ-គណនេយ្យ នៃមន្ទីរសាធារណការនិងដឹកជញ្ជូនខេត្តរតនគីរី
១៤៦-លោក **តាំង ស្រ៊ុន** មន្ត្រីការិ.ផែនការ-គណនេយ្យ នៃមន្ទីរសាធារណការនិងដឹកជញ្ជូនខេត្តរតនគីរី
១៤៧-លោក **តុក សំអឿន** អនុប្រធានការិ.សាធារណការ នៃមន្ទីរសាធារណការនិងដឹកជញ្ជូនខេត្តមណ្ឌលគីរី
១៤៨-លោក **ជី រិទ្ធី** ប្រធានការិ.សាធារណការស្រុកសែនមនោរម្យ នៃមន្ទីរសាធារណការនិងដឹកជញ្ជូនខេត្តមណ្ឌលគីរី

មាត្រា២.-

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និងរដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន ត្រូវអនុវត្ត អនុក្រឹត្យនេះ អោយទទួលបាន លទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ២៦ ខែ កុម្ភៈ ឆ្នាំ ២០១០

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល :

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា១ និងមាត្រា២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខៈ ២៣៣ .អនក្រ.បក

អនុក្រឹត្យ
ស្ដីពីការជូនមេដាយមុនីសារាភ័ណ្ឌ

រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្ដីពីការបង្កើតនិងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

សម្រេច

មាត្រា ១.-

ត្រូវបានបំពាក់ មេដាយមុនីសារាភ័ណ្ឌ ថ្នាក់ ធិបឌិន្ទ ប្រគេនព្រះតេជគុណ ទ័ន សឿន ព្រះចៅអធិការវត្តព្រៃកបង្គង ដែលបានបរិច្ចាគបច្ច័យ ចំនួន ១១២.៥១០ ដុល្លារអាមេរិក ចូលរួមជួយកសាង កុដិបេតុងកំពស់ ០២ជាន់ ចំនួន ០១ខ្នង របងបេតុង ប្រវែង ៧៥ម៉ែត្រ និង ផ្លូវក្រាលបេតុង ប្រវែង ១៧០ម៉ែត្រ ស្ថិតនៅវត្តព្រៃកបង្គង ឃុំព្រែកតាកូវ ស្រុកខ្សាច់កណ្ដាល ខេត្តកណ្ដាល។

មាត្រា ២.-

រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងអភិបាលនៃគណៈអភិបាលខេត្តកណ្ដាល ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ២៩ ខែ ១ ឆ្នាំ ២០១០
នាយករដ្ឋមន្ត្រី

សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួលៈ
-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្ដេចនាយករដ្ឋមន្ត្រី
-ដូចមាត្រា១ និងមាត្រា២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ: ២៣៤.អនក្រ.បក

អនុក្រឹត្យ
ស្តីពីការជូនមេដាយស្ថាបនាជាតិ

រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
-បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
-បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
-បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
-តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

សម្រេច

មាត្រា ១.

ត្រូវបានបំពាក់ **មេដាយស្ថាបនាជាតិ** តាមលំដាប់ថ្នាក់ ជូនសប្បុរសជន ចំនួន ១៣រូប ដែលបានបរិច្ចាគធនធានផ្ទាល់ខ្លួន ចូលរួមកសាង កុដិបេតុង កំពស់ ០២ជាន់ ចំនួន ០១ខ្នង របងបេតុង ប្រវែង ៧៥ម៉ែត្រ និង ផ្លូវក្រាលបេតុង ប្រវែង ១៧០ម៉ែត្រ ស្ថិតនៅវត្តព្រែកបង្កង ឃុំព្រែកតាកូវ ស្រុកខ្សាច់កណ្តាល ខេត្តកណ្តាល ដូចមានរាយនាមខាងក្រោម៖

ក-មេដាយមាសស្ថាបនាជាតិ៖

១-	អ្នកស្រី	អ៊ុំ ឡាងហៀង	សប្បុរសជនខ្មែររស់នៅសហរដ្ឋអាមេរិក	ថវិកា ១៣.៥០០ ដុល្លារ
២-	លោក	ជា ម៉ុង	សប្បុរសជននៅរាជធានីភ្នំពេញ	ថវិកា ១២.៥០០ ដុល្លារ
៣-	ឧបាសក	សេង ហេង	សប្បុរសជននៅរាជធានីភ្នំពេញ	ថវិកា ១២.១០០ ដុល្លារ
៤-	លោក	នេត មុន្នី	សប្បុរសជននៅរាជធានីភ្នំពេញ	ថវិកា ១១.៥០០ ដុល្លារ

ខ-មេដាយប្រាក់ស្ថាបនាជាតិ៖

១-	លោក	សេង សំណាង	សប្បុរសជននៅរាជធានីភ្នំពេញ	ថវិកា ៨.១៥០ ដុល្លារ
២-	ឧបាសក	ឆួង សាំង	សប្បុរសជននៅរាជធានីភ្នំពេញ	ថវិកា ៧.៩០០ ដុល្លារ
៣-	ឧបាសក	ម៉ា ចំរើន	សប្បុរសជននៅរាជធានីភ្នំពេញ	ថវិកា ៧.៨៧០ ដុល្លារ

៤-	ឧបាសក	គ្រួច ហ៊ឹម	សប្បុរសជននៅខេត្តកណ្តាល	ថវិកា ៧.៥៧៣ ដុល្លារ
៥-	ឧបាសក	រ័ត្ន ព្រិល	សប្បុរសជននៅខេត្តកណ្តាល	ថវិកា ៧.៥៦០ ដុល្លារ
៦-	ឧបាសក	គីម ហៃ	សប្បុរសជននៅខេត្តកណ្តាល	ថវិកា ៧.១៥០ ដុល្លារ
៧-	អ្នកស្រី	សយ ឡាត	សប្បុរសជននៅរាជធានីភ្នំពេញ	ថវិកា ៧.០៥០ ដុល្លារ

គ-មេដាយសុវត្ថិភាពរឹទ្ធិស្ថាបនាជាតិ:

១-	លោក	រ័ត្ន សុខជា	សប្បុរសជននៅខេត្តកណ្តាល	ថវិកា ៣.៧៨០ ដុល្លារ
២-	លោក	ហ៊ឹម ឆាំក់	សប្បុរសជននៅខេត្តកណ្តាល	ថវិកា ៣.៧៦០ ដុល្លារ

មាត្រា ២.

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និង អភិបាលនៃគណៈអភិបាលខេត្តកណ្តាល ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ កុម្ភៈ ឆ្នាំ ២០១០

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល:
- -ក្រសួងព្រះបរមរាជវាំង
- -អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- -អគ្គលេខាធិការដ្ឋានរដ្ឋសភា
- -អគ្គលេខាធិការរាជរដ្ឋាភិបាល
- -ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- -ដូចមាត្រា១ និងមាត្រា២
- -រាជកិច្ច
- -ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ២៣៥ . អនក្រ.បក

អនុក្រឹត្យ
ស្តីពីការជូនមេដាយការងារ

១៣៥

រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើតនិងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា

សម្រេច

មាត្រា១.-

ត្រូវបានបំពាក់ **មេដាយការងារ** តាមលំដាប់ថ្នាក់ ជូនមន្ត្រីរាជការ និងបុគ្គលិកសិក្សា ចំនួន ៥៨ រូប នៃមន្ទីរអប់រំ យុវជន និងកីឡា ខេត្តស្ទឹងត្រែង ដែលមានស្នាដៃល្អក្នុងការបំពេញភារកិច្ចជូនជាតិមាតុភូមិកន្លងមក ដូចមានរាយនាមខាងក្រោម :-

ក-មេដាយមាសការងារ :

១	លោក លួន ផងឌី	ប្រធានការិយាល័យ	ការិ.អប់រំយុវជន និងកីឡាស្រុក	សៀមបាង
២	លោក ប៉ាន់ អ៊ិនឃាង	ប្រធានការិយាល័យ	ការិ.អប់រំយុវជន និងកីឡាស្រុក	ថាឡាបរិវ៉ាត់
៣	លោក ធិប ឡាងឌី	ប្រធានការិយាល័យ	ការិ.អប់រំយុវជន និងកីឡាស្រុក	ស្ទឹងត្រែង
៤	លោកស្រី បួរ ប្រាណិត	នាយិកា	សាលាមត្តេយ្យ ពន្លឺកុមារ	ស្ទឹងត្រែង
៥	លោក រស់ ប៊ិន	មន្ត្រី	ការិ.អប់រំយុវជន និងកីឡាស្រុក	សៀមបាង
៦	លោក ឡុង ថា	មន្ត្រី	កំរងសាលាកោះព្រះ	សៀមបូក
៧	លោក ប៉ង ប៊ុនទីង	មន្ត្រី	ការិ.អប់រំយុវជន និងកីឡាស្រុក	សេសាន
៨	លោកស្រី គីន សំណាង	មន្ត្រី	មជ្ឈមណ្ឌលគរុកោសល្យភូមិភាគ	ស្ទឹងត្រែង

៩	លោក ប៉ារ៉ំ បូណា	មន្ត្រី	ការិ.អប់រំយុវជន និងកីឡាស្រុក	សៀមបូក
១០	លោកស្រី ណយ នីវ៉ន	មន្ត្រី	ការិ.ផែនការគណនេយ្យមន្ទីរ អយក២	ស្ទឹងត្រែង
១១	លោកស្រី ហម យឹម	គ្រូបន្ទុកថ្នាក់	សាលាបឋមសិក្សាកោះព្រះ	សៀមបូក
១២	លោកស្រី យ៉ាន យ៉ុន	គ្រូបន្ទុកថ្នាក់	សាលាបឋមសិក្សាពងទឹក	ថាឡាបរិវ៉ាត់
១៣	លោក ងិន ចន្ថា	គ្រូបន្ទុកថ្នាក់	សាលាបឋមសិក្សាថាឡាបរិវ៉ាត់	ថាឡាបរិវ៉ាត់
១៤	លោក លី មិណា	គ្រូបន្ទុកថ្នាក់	សាលាបឋមសិក្សាស្ទឹងត្រែងក្រុង	ស្ទឹងត្រែង
១៥	លោកស្រី ជ្រី សុភា	គ្រូបន្ទុកថ្នាក់	សាលាបឋមសិក្សាបាចុង	ស្ទឹងត្រែង
១៦	លោកស្រី ហង្ស វណ្ណត	គ្រូបន្ទុកថ្នាក់	អនុវិទ្យាល័យព្រះបាទ	ស្ទឹងត្រែង
១៧	លោក ខេង ចំរើន	គ្រូបន្ទុកថ្នាក់	វិទ្យាល័យហ៊ុនសែនស្ទឹងត្រែង	ស្ទឹងត្រែង
១៨	លោក វ៉ាន់ វ៉ៃន	គ្រូបន្ទុកថ្នាក់	សាលាបឋមសិក្សាកាតួត	សេសាន
១៩	លោកស្រី ស៊ូ ចាន់ណា	គ្រូបន្ទុកថ្នាក់	សាលាបឋមសិក្សាកោះព្រះ	សៀមបូក
២០	លោកស្រី ស៊ុម ណារី	គ្រូបន្ទុកថ្នាក់	វិទ្យាល័យព្រះរាជបូជនីយកិច្ច	ស្ទឹងត្រែង

ខ_មេដាយប្រាក់ការងារ :

១	លោក ម៉ៅ ប៊ុនថៃ	នាយក	វិទ្យាល័យព្រះរាជបូជនីយកិច្ច	ស្ទឹងត្រែង
២	លោក សំ ប៊ុនធិន	នាយក	អនុវិទ្យាល័យសេរីវ័ត្ត	សៀមប៉ាង
៣	លោក ផាត់ ភាព	នាយក	អនុវិទ្យាល័យថាឡាបរិវ៉ាត់	ថាឡាបរិវ៉ាត់
៤	លោក តែម ជុំ	នាយក	អនុវិទ្យាល័យសេសាន	សេសាន
៥	លោក ណុប បូរ៉ាត	នាយក	សាលាបឋមសិក្សាស្វាយះកោះ	សៀមបូក
៦	លោក មឿង ងឿង	នាយក	សាលាបឋមសិក្សាកំភុន	សេសាន
៧	លោក ឡុន សុផល	មន្ត្រី	សាលាបឋមសិក្សាអនុវត្ត	ស្ទឹងត្រែង
៨	លោក យិន សារឿន	មន្ត្រី	ការិយាល័យអប់រំក្រៅប្រព័ន្ធ	ស្ទឹងត្រែង
៩	លោក លួន ស៊ីសែង	មន្ត្រី	សាលាបឋមសិក្សាកញ្ចាញទឹក	សៀមប៉ាង
១០	លោក អន ស៊ីខាំផក	មន្ត្រី	កំរងសាលាស្រែក្រសាំង	សៀមបូក
១១	លោកស្រី សាន សារ៉ាត់	មន្ត្រី	ការិ.អប់រំយុវជន និងកីឡាស្រុក	ថាឡាបរិវ៉ាត់
១២	លោក គង់ សំអឿន	មន្ត្រី	សាលាបឋមសិក្សាសម្តេចក្រុមព្រះ	ស្ទឹងត្រែង
១៣	លោក សន វិចិត្រ	មន្ត្រី	សាលាបឋមសិក្សាស្ទឹងត្រែងក្រុង	ស្ទឹងត្រែង
១៤	លោក ទុន ដារា	មន្ត្រី	ការិ.អប់រំយុវជន និងកីឡាស្រុក	ស្ទឹងត្រែង
១៥	លោកស្រី ម៉ែន សុខា	មន្ត្រី	កំរងសាលាថាឡាបរិវ៉ាត់	ថាឡាបរិវ៉ាត់
១៦	លោក ពុត សូឡៃ	គ្រូបន្ទុកថ្នាក់	សាលាបឋមសិក្សាឈើទាលជ្រុំ	សៀមប៉ាង
១៧	លោក ហឿង បេង	គ្រូបន្ទុកថ្នាក់	សាលាបឋមសិក្សាគិរីវង្សា	សៀមប៉ាង

១៨	លោក ឡាន់ ចាន់បូ	គ្រូបន្ទុកថ្នាក់	សាលាបឋមសិក្សាកោះសំពាយ	សៀមបូក
១៩	លោកស្រី គឹម សារឿន	គ្រូបន្ទុកថ្នាក់	សាលាបឋមសិក្សាស្រែក្រសាំង	សៀមបូក
២០	លោកស្រី ហង្ស សុឃៀម	គ្រូបន្ទុកថ្នាក់	សាលាបឋមសិក្សាកោះសំពាយ	សៀមបូក
២១	លោក ភោគ ខែក	គ្រូបន្ទុកថ្នាក់	សាលាបឋមសិក្សាអូររៃ	ថាឡាបរិវ៉ាត់
២២	លោក ជួន ឆន	គ្រូបន្ទុកថ្នាក់	សាលាបឋមសិក្សាថាឡាបរិវ៉ាត់	ថាឡាបរិវ៉ាត់
២៣	លោក សួយ ហួ	គ្រូបន្ទុកថ្នាក់	សាលាបឋមសិក្សាស្រែគរ	សេសាន
២៤	លោក ផាត់ ខាំធុយ	គ្រូបន្ទុកថ្នាក់	សាលាបឋមសិក្សាក្រឡាពុះ	សេសាន
២៥	លោកស្រី មាស ចាន់ឆេង	គ្រូបន្ទុកថ្នាក់	សាលាបឋមសិក្សាបាចុង	ស្ទឹងត្រែង
២៦	លោក តាត ព្រឹក្សា	គ្រូបន្ទុកថ្នាក់	អនុវិទ្យាល័យហ៊ុនសែនសាមគ្គី	ស្ទឹងត្រែង
២៧	លោកស្រី សាន សារីម	គ្រូបន្ទុកថ្នាក់	សាលាបឋមសិក្សាកាំងម៉េម៉ាយ	ស្ទឹងត្រែង
២៨	លោក តី កង	គ្រូបន្ទុកថ្នាក់	សាលាបឋមសិក្សាកោះខនឌិន	ស្ទឹងត្រែង
២៩	លោក អាន ធី	គ្រូបន្ទុកថ្នាក់	វិទ្យាល័យព្រះរាជបូជនីយកិច្ច	ស្ទឹងត្រែង

គ_មេដាយសំរឹទ្ធការងារ :

១	លោក ឯក ស៊ីវ៉ន	ប្រធានកំរង	កំរងសាលាកោះស្រឡាយ	សៀមបូក
២	លោកស្រី ពុត យ៉ន	នាយិកា	សាលាបឋមសិក្សាអូរឬស្សីកណ្តាល	សៀមបូក
៣	លោក អន ស៊ីនហួ	នាយក	អនុវិទ្យាល័យសៀមបូក	សៀមបូក
៤	លោក ប៉យ ផុត	នាយក	សាលាបឋមសិក្សាកោះស្នែង	ថាឡាបរិវ៉ាត់
៥	លោក ផង ដែង	នាយក	សាលាបឋមសិក្សាពងទឹក	ថាឡាបរិវ៉ាត់
៦	លោក ម៉ែន ឆន	នាយក	សាលាបឋមសិក្សាឆ្វាំង	ថាឡាបរិវ៉ាត់
៧	លោក ស្រី ឈៀម សុណ្ណារី	នាយិកា	សាលាបឋមសិក្សាក្រឡាពាស	ថាឡាបរិវ៉ាត់
៨	លោក ថា សោភា	នាយក	សាលាបឋមសិក្សាស្រែតាប៉ាន	សេសាន
៩	លោក ជា សុផល	នាយក	សាលាបឋមសិក្សាអនុវត្ត	ស្ទឹងត្រែង
១០	លោក ខាត់ លីមឃាង	មន្ត្រី	ការិយាល័យមធ្យមសិក្សា	ស្ទឹងត្រែង
១១	លោក ស៊ឹម ស្រ៊ុន	មន្ត្រី	ការិ.អប់រំយុវជន និងកីឡាស្រុក	សៀមបូក
១២	លោក គង់ សុភ័ក្ត្រ	មន្ត្រី	អនុវិទ្យាល័យហ៊ុនសែនកោះស្រឡាយ	សៀមបូក
១៣	លោក សេង វិរៈ	មន្ត្រី	កំរងសាលាកោះខនឌិន	ស្ទឹងត្រែង
១៤	លោក សោម សុខគង់	មន្ត្រី	ការិ.ផែនការ គននេយ្យមន្ទីរអយក២	ស្ទឹងត្រែង
១៥	លោកស្រី សួស ច័ន្ទតរុណី	មន្ត្រី	ការិ.បឋមសិក្សា និងមត្តេយ្យមន្ទីរអយក២	ស្ទឹងត្រែង
១៦	លោកស្រី និន ប៊ុននី	មន្ត្រី	សាលាបឋមសិក្សាខ្វួសួន	ស្ទឹងត្រែង

១៧	លោក ទីម សុកុល	មន្ត្រី	កំរងសាលាកោះខនឌិន	ស្ទឹងត្រែង
១៨	លោក ថង សែ	មន្ត្រី	សាលាបឋមសិក្សាសម្តេចឪ សម្តេចម៉ែ	ស្ទឹងត្រែង
១៩	លោក អ៊ាន អ៊ូច	មន្ត្រី	សាលាបឋមសិក្សាហ៊ុនសែនបាចុង	ស្ទឹងត្រែង
២០	លោក ខាត់ សម្បត្តិ	មន្ត្រី	សាលាបឋមសិក្សាអូរពងមាន់	ស្ទឹងត្រែង
២១	លោក ស្រី សាន់ សុខឿន	មន្ត្រី	វិទ្យាល័យហ៊ុនសែនស្ទឹងត្រែង	ស្ទឹងត្រែង
២២	លោកស្រី យ៉ាន់ សុវិជ្ជា	មន្ត្រី	វិទ្យាល័យហ៊ុនសែនស្ទឹងត្រែង	ស្ទឹងត្រែង
២៣	លោកស្រី វណ្ណ រមណីយ៍	មន្ត្រី	មជ្ឈមណ្ឌលគរុកោសល្យភូមិភាគ	ស្ទឹងត្រែង
២៤	លោក ច័ន្ទ សម្ផស្ស	មន្ត្រី	ការិ.យុវជន និងកីឡាមន្ទីរ អយកខ	ស្ទឹងត្រែង
២៥	លោកស្រី យ៉ុន សារឿន	មន្ត្រី	សាលាមត្តេយ្យ ពន្លឺកុមារ	ស្ទឹងត្រែង
២៦	លោក ដួង អត្រា	គ្រូបន្ទុកថ្នាក់	សាលាបឋមសិក្សាខាន់ខឿ	សៀមប៉ាង
២៧	លោក ចាត់ ឧដន	គ្រូបន្ទុកថ្នាក់	សាលាបឋមសិក្សាសៀមប៉ាង	សៀមប៉ាង
២៨	លោក ខៀវ ស៊ីឡៃ	គ្រូបន្ទុកថ្នាក់	សាលាបឋមសិក្សាកញ្ជាទឹក	សៀមប៉ាង
២៩	លោក អ៊ុយ ខែនី	គ្រូបន្ទុកថ្នាក់	សាលាបឋមសិក្សាបានហួយ	សៀមប៉ាង
៣០	លោក ហួន សារិន	គ្រូបន្ទុកថ្នាក់	សាលាបឋមសិក្សាសៀមបូក	សៀមបូក
៣១	លោក គីម ភិរុណ	គ្រូបន្ទុកថ្នាក់	សាលាបឋមសិក្សាដីរផុង	ថាឡាបរិវ៉ាត់
៣២	លោក ថង ស៊ុន	គ្រូបន្ទុកថ្នាក់	សាលាបឋមសិក្សាកាំងចាម	ថាឡាបរិវ៉ាត់
៣៣	លោក សោម ពិសិដ្ឋ	គ្រូបន្ទុកថ្នាក់	សាលាបឋមសិក្សាសំអាង	ថាឡាបរិវ៉ាត់
៣៤	លោក ស្រី ជា ចាន្ថា	គ្រូបន្ទុកថ្នាក់	សាលាបឋមសិក្សាអូរស្វាយ	ថាឡាបរិវ៉ាត់
៣៥	លោកស្រី ទី សារះវង្សី	គ្រូបន្ទុកថ្នាក់	សាលាបឋមសិក្សាថាឡាបរិវ៉ាត់	ថាឡាបរិវ៉ាត់
៣៦	លោក ហន ឆន	គ្រូបន្ទុកថ្នាក់	សាលាបឋមសិក្សាអន្លង់ស្វាយ	ថាឡាបរិវ៉ាត់
៣៧	លោក ងួន មារិន	គ្រូបន្ទុកថ្នាក់	សាលាបឋមសិក្សាព្រះរំកិល	ថាឡាបរិវ៉ាត់
៣៨	លោក វង្ស សុគន្ធ	គ្រូបន្ទុកថ្នាក់	អនុវិទ្យាល័យថាឡាបរិវ៉ាត់	ថាឡាបរិវ៉ាត់
៣៩	លោក វ៉ាន់ នីម	គ្រូបន្ទុកថ្នាក់	អនុវិទ្យាល័យថាឡាបរិវ៉ាត់	ថាឡាបរិវ៉ាត់
៤០	លោក ស្រី ជា សៀន	គ្រូបន្ទុកថ្នាក់	សាលាបឋមសិក្សាថាឡាបរិវ៉ាត់	ថាឡាបរិវ៉ាត់
៤១	លោកស្រី នូ ចាន់ហឿ	គ្រូបន្ទុកថ្នាក់	សាលាបឋមសិក្សាកំភុន	សេសាន
៤២	លោក អន្ថា ខាំហុត	គ្រូបន្ទុកថ្នាក់	សាលាបឋមសិក្សាបានបុង	សេសាន
៤៣	លោក សូ ដារិទ្ធ	គ្រូបន្ទុកថ្នាក់	អនុវិទ្យាល័យសេសាន	សេសាន
៤៤	លោក ព្រហ្ម ទ្រី	គ្រូបន្ទុកថ្នាក់	សាលាបឋមសិក្សាសាឃួន	ស្ទឹងត្រែង
៤៥	លោក កែវ គីមម៉ក់	គ្រូបន្ទុកថ្នាក់	សាលាបឋមសិក្សាខាំផាន់	ស្ទឹងត្រែង

៤៦	លោកស្រី ជួប គឹមយ៉េង	គ្រូបន្ទុកថ្នាក់	សាលាបឋមសិក្សាភូមិថ្មី	ស្ទឹងត្រែង
៤៧	លោកស្រី អ៊ុក សុមន្ថា	គ្រូបន្ទុកថ្នាក់	សាលាបឋមសិក្សាសាមគ្គីអភិវឌ្ឍន៍	ស្ទឹងត្រែង
៤៨	លោក ញ៉ូ ស៊ីសុគន្ធ	គ្រូបន្ទុកថ្នាក់	សាលាបឋមសិក្សាសម្តេចក្រុមព្រះ	ស្ទឹងត្រែង
៤៩	លោក ស្រ៊ីង ស្រេម	គ្រូបន្ទុកថ្នាក់	វិទ្យាល័យព្រះរាជបូជនីយកិច្ច	ស្ទឹងត្រែង

មាត្រា២.-

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា និងអភិបាលនៃគណៈអភិបាលខេត្តស្ទឹងត្រែង ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ កុម្ភៈ ឆ្នាំ២០១០

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល :

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចក្នុងមាត្រា ១ និង មាត្រា ២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ២៣៦ អនក្រ.បក

អនុក្រឹត្យ

ស្តីពី

ការតែងតាំងក្រុមប្រឹក្សាភិបាលនៃអាជ្ញាធរជាតិ ដើម្បីការពារ និងអភិវឌ្ឍរមណីយដ្ឋានវប្បធម៌ធម្មជាតិ នៃប្រាសាទព្រះវិហារ

រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៩ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការបង្កើតទីស្តីការគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤០៦/១៨៣ ចុះថ្ងៃទី ១៣ ខែ មេសា ឆ្នាំ ២០០៦ ស្តីពីការកំណត់រមណីយដ្ឋានប្រាសាទព្រះវិហារ

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៦០៦/២៤៨ ចុះថ្ងៃទី ០១ ខែ មិថុនា ឆ្នាំ ២០០៦ ស្តីពីការបង្កើតអាជ្ញាធរជាតិ ដើម្បីការពារ និងអភិវឌ្ឍរមណីយដ្ឋានវប្បធម៌ធម្មជាតិនៃប្រាសាទព្រះវិហារ

-បានឃើញអនុក្រឹត្យលេខ ១១ អនក្រ.បក ចុះថ្ងៃទី ២៩ ខែ មករា ឆ្នាំ ២០០៨ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ របស់អគ្គនាយកដ្ឋាននៃអាជ្ញាធរជាតិ ដើម្បីការពារនិងអភិវឌ្ឍរមណីយដ្ឋានវប្បធម៌នៃប្រាសាទព្រះវិហារ

-យោងតាមតម្រូវការចាំបាច់នៃការងារ

សម្រេច

មាត្រា ១ : ត្រូវបានតែងតាំងក្រុមប្រឹក្សាភិបាល នៃអាជ្ញាធរជាតិដើម្បីការពារនិងអភិវឌ្ឍរមណីយដ្ឋានវប្បធម៌ធម្មជាតិនៃប្រាសាទព្រះវិហារ ដែលមានសមាសភាពដូចតទៅ ÷

១- ឯកឧត្តម **ជុច ភឿន**	រដ្ឋលេខាធិការក្រសួងវប្បធម៌ និងវិចិត្រសិល្បៈនិងជាប្រធានអាជ្ញាធរជាតិដើម្បីការពារនិងអភិវឌ្ឍរមណីយដ្ឋានធម្មជាតិនៃប្រាសាទព្រះវិហារ	ប្រធាន

២- ឯកឧត្តម **អ៊ុំ ម៉ារ៉ា**	អភិបាលនៃគណៈអភិបាលខេត្តព្រះវិហារ	អនុប្រធាន
៣- ឯកឧត្តម **សូ ម៉ារ៉ា**	រដ្ឋលេខាធិការក្រសួងទេសចរណ៍	សមាជិក
៤- ឯកឧត្តម **សួស យ៉ារ៉ា**	អនុរដ្ឋលេខាធិការទីស្តីការគណៈរដ្ឋមន្ត្រី	សមាជិក
៥- ឯកឧត្តម **ញាណ ឡេង**	អនុរដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ	សមាជិក
៦- ឯកឧត្តម **ម៉ម សុផាណា**	អនុរដ្ឋលេខាធិការក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់	សមាជិក
៧- ឯកឧត្តម **គីម សុវណ្ណា**	អនុរដ្ឋលេខាធិការក្រសួងមហាផ្ទៃ	សមាជិក
៨- ឯកឧត្តម **ធា ដុប**	អនុរដ្ឋលេខាធិការក្រសួងបរិស្ថាន	សមាជិក
៩- ឯកឧត្តម **ឱក សុផុន**	អគ្គនាយកបេតិកភណ្ឌនៃក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ	សមាជិក
១០- ឯកឧត្តម **ភឹម មុនី**	អគ្គនាយកដ្ឋាននៃក្រសួងសាធារណការ និងដឹកជញ្ជូន	សមាជិក
១១- ឯកឧត្តម **ហង់ សុត**	អគ្គនាយកនៃអាជ្ញាធរជាតិដើម្បីការពារ និងអភិវឌ្ឍរមណីយដ្ឋានវប្បធម៌ធម្មជាតិ នៃប្រាសាទព្រះវិហារ	សមាជិក និងជាលេខាធិការ ។

មាត្រា ២: រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងរៀបចំដែនដីនគរូបនីយកម្មនិងសំណង់ រដ្ឋមន្ត្រីក្រសួងបរិស្ថាន រដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន រដ្ឋមន្ត្រីក្រសួងវប្បធម៌និងវិចិត្រសិល្បៈ រដ្ឋមន្ត្រីក្រសួងទេសចរណ៍ ប្រធានអាជ្ញាធរជាតិដើម្បីការពារនិងអភិវឌ្ឍរមណីយដ្ឋាន វប្បធម៌ធម្មជាតិនៃប្រាសាទព្រះវិហារ និងសាមីខ្លួន ដូចមានចែងក្នុងមាត្រា១ ខាងលើ ត្រូវអនុវត្តអនុក្រឹត្យនេះ អោយមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី[illegible] ខែ[illegible] ឆ្នាំ ២០១០

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល :
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ: ២៣៧ អនក្រ.បក

អនុក្រឹត្យ
ស្តីពី
ការលុបឈ្មោះមន្ត្រីរាជការ

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាស អោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៩ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតទីស្តីការគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- យោងតាមសំណើរបស់រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី

សម្រេច

មាត្រា១: ត្រូវបានលុបឈ្មោះលោក **គា គិរីរេណុល** អនុប្រធានវិទ្យាស្ថានទំនាក់ទំនងអន្តរជាតិនៃរាជបណ្ឌិតសភាកម្ពុជា ចេញពីក្របខ័ណ្ឌទីស្តីការគណៈរដ្ឋមន្ត្រី ចាប់ពីថ្ងៃទី ០១ ខែ មីនា ឆ្នាំ ២០១០ តទៅ ដោយមូលហេតុ សាមីខ្លួន បោះបង់ចោលការងារ ។

មាត្រា២: បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

មាត្រា៣: រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង-ស្ថាប័នពាក់ព័ន្ធ និងសាមីខ្លួន ដូចមានចែងក្នុងមាត្រា១ ខាងលើ ត្រូវអនុវត្តអនុក្រឹត្យនេះ អោយមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ, ថ្ងៃទី ២៦ ខែ កុម្ភៈ ឆ្នាំ ២០១០

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល ៖
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៣
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ១៥ សសរ

សេចក្តីសម្រេច
ស្តីពី
ការរៀបចំការចងសម្ព័ន្ធមេត្រីភាព
រវាងអង្គភាពកងទ័ព អង្គភាពនគរបាលជាតិ ជាមួយស្ថាប័ន-អង្គភាពស៊ីវិល

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៧ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងការពារជាតិ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០១/២៣៧ ចុះថ្ងៃទី ១៨ ខែ កក្កដា ឆ្នាំ ២០០១ ស្តីពីការកែសម្រួលតួនាទី ភារកិច្ច និងរចនាសម្ព័ន្ធចាត់តាំងរបស់អគ្គបញ្ជាការដ្ឋាននៃកងយោធពលខេមរភូមិន្ទ
- បានឃើញអនុក្រឹត្យលេខ ៦៥ អនក្រ.បក ចុះថ្ងៃទី ១៤ ខែ កញ្ញា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងការពារជាតិ
- បានឃើញអនុក្រឹត្យលេខ ១៦ អនក្រ ចុះថ្ងៃទី ២០ ខែ ធ្នូ ឆ្នាំ ១៩៩៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងមហាផ្ទៃ
- យោងតាមការងារចាំបាច់របស់រាជរដ្ឋាភិបាល

ស ម្រេ ច

ប្រការ ១.-

ត្រូវបានរៀបចំការចងសម្ព័ន្ធមេត្រីភាពរវាងអង្គភាពកងទ័ព អង្គភាពនគរបាលជាតិ ជាមួយស្ថាប័ន-អង្គភាពស៊ីវិល ដូចខាងក្រោម :

ក.-អង្គភាពកងទ័ព

ក.១.-យោធភូមិភាគទី៣

-ខេត្តកោះកុង

១-កងអនុសេនាធំទី១ កងអនុសេនាធំទី២ ស្រុកមណ្ឌលសីមា និងបញ្ជាការដ្ឋានតំបន់ប្រតិបត្តិការសឹកកោះកុងចងសម្ព័ន្ធមេត្រីភាពជាមួយ :

-គណៈអភិបាលខេត្តកោះកុង និងប្រធានមន្ទីរអង្គភាពនានាជុំវិញខេត្ត និង

-ក្រុមហ៊ុន FU HAI INVESTMENT របស់ឧកញ៉ា **លឹម ស៊ីណា**។

២-បញ្ជាការដ្ឋានតំបន់ប្រតិបត្តិការសឹកកោះកុង ចងសម្ព័ន្ធមេត្រីភាពជាមួយ :

-ឧកញ៉ា **អ៊ាត សីម៉ា**។

ក.២.-យោធភូមិភាគទី៤

-ខេត្តព្រះវិហារ

១-កងវរសេនាតូចការពារព្រំដែនលេខ៤០៥ ខេត្តព្រះវិហារ ចងសម្ព័ន្ធមេត្រីភាពជាមួយ :

-ក្រសួងធនធានទឹក និង ឧតុនិយម

-ក្រុមហ៊ុនសីលាដាម៉ិច និង

-ក្រុមហ៊ុនរតនាខួអបភើរេសិន។

២-អង្គភាពទីបញ្ជាការតំបន់ប្រតិបត្តិការសឹករងព្រះវិហារ ចងសម្ព័ន្ធមេត្រីភាពជាមួយ :

-សាលាខេត្តព្រះវិហារ និងមន្ទីរ អង្គភាពជុំវិញខេត្ត។

៣-កងអនុសេនាធំលេខ១ ស្រុកឆែប ចងសម្ព័ន្ធមេត្រីភាពជាមួយ :

-សាលាខេត្តព្រះវិហារ និងមន្ទីរអង្គភាពជុំវិញខេត្ត។

៤-កងអនុសេនាធំលេខ២ ស្រុកជាំក្សាន្ត ចងសម្ព័ន្ធមេត្រីភាពជាមួយ :

-ក្រុមហ៊ុនស៊ីចាន់ផុនហ្វាមី អ៊ិនវេសមេន ឌីវេឡុបមេន ខូអិលធីឌី និង

-ក្រុមហ៊ុនហ្វ្រីនឌីវេឡុបមេនខូអិលធីឌី។

៥-កងអនុសេនាធំលេខ៣ ស្រុកជាំក្សាន្ត ចងសម្ព័ន្ធមេត្រីភាពជាមួយ :

-ក្រុមហ៊ុនស៊ីចាន់ផុនហ្វាមីអ៊ិនវេសមេន ឌីវេឡុបមេន ខូអិលធីឌី និង

-ក្រុមហ៊ុនហ្វ្រីនឌីវេឡុបមេនខូអិលធីឌី។

-ខេត្តឧត្តរមានជ័យ

១-កងវរសេនាតូចការពារព្រំដែនលេខ៤០៦ ខេត្តឧត្តរមានជ័យ ចងសម្ព័ន្ធមេត្រីភាពជាមួយ :

-ក្រសួងធនធានទឹក និង ឧតុនិយម

-សាលាខេត្ត

-ក្រុមហ៊ុនចំការកៅស៊ូជុប និង

-ក្រុមហ៊ុនអង្គរវត្តស៊ីម៉ងត៍លីមីធីត ។

២-កងវរសេនាតូចការពារព្រំដែនលេខ៤០៧ ខេត្តឧត្តរមានជ័យ ចងសម្ព័ន្ធមេត្រីភាពជាមួយ :

-សម្ព័ន្ធក្រុមហ៊ុនសាងសង់នៃក្រសួងធនធានទឹក និងឧតុនិយម

-សាលាខេត្ត

-ក្រុមហ៊ុនអង្គរស៊ូហ្គើរ

-ក្រុមហ៊ុនខេមបូឌា ខេន អេន ស៊ូហ្គើរវ៉ែលី

-ក្រុមហ៊ុនទន្លេស៊ូហ្គើរ និង

-ប្រធានទីស្នាក់ការត្រួតពិនិត្យច្រកទ្វារព្រំដែនអន្តរជាតិអូរស្មាច់ ។

៣-អង្គភាពទីបញ្ជាការតំបន់ប្រតិបត្តិការសឹករងខេត្តឧត្តរមានជ័យ ចងសម្ព័ន្ធមេត្រីភាពជាមួយ :

-សាលាខេត្តឧត្តរមានជ័យ និងមន្ទីរ អង្គភាពជុំវិញខេត្ត ។

៤-កងអនុសេនាធំលេខ៤ ស្រុកត្រពាំងប្រាសាទ ចងសម្ព័ន្ធមេត្រីភាពជាមួយ :

-សាលាស្រុកត្រពាំងប្រាសាទ

-អង្គភាពរដ្ឋបាលព្រៃឈើប្រចាំស្រុកត្រពាំងប្រាសាទ

-មន្ទីរប្រៃសណីយ៍ និងទូរគមនាគមន៍

-មន្ទីរបរិស្ថាន និង

-មន្ទីរសាធារណការ និងដឹកជញ្ជូន ។

៥-កងអនុសេនាធំលេខ៥ ស្រុកត្រពាំងប្រាសាទ ចងសម្ព័ន្ធមេត្រីភាពជាមួយ :

-សាលាស្រុកត្រពាំងប្រាសាទ

-អង្គភាពរដ្ឋបាលជលផលប្រចាំខេត្តឧត្តរមានជ័យ

-មន្ទីរពាណិជ្ជកម្ម

-មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

-មន្ទីរធម្មការ និងសាសនា

-មន្ទីរកិច្ចការនារី និង

-ក្រុមហ៊ុន L.H.R ASEAN INVESTMENT Co.,Ltd. ។

៦-កងអនុសេនាធំលេខ៦ ស្រុកអន្លង់វែង ចងសម្ព័ន្ធមេត្រីភាពជាមួយ :

-សាលាស្រុកអន្លង់វែង

-អង្គភាពរដ្ឋបាលព្រៃឈើប្រចាំស្រុកអន្លង់វែង

-សាខាពន្ធដារខេត្ត

-មន្ទីរផែនការ

-មន្ទីរទំនាក់ទំនងជាមួយរដ្ឋសភា ព្រឹទ្ធសភា និងអធិការកិច្ច

-មន្ទីរធនធានទឹក និងឧតុនិយម

-ស្នាក់ការគយ និងរដ្ឋាករច្រកទ្វារព្រំដែនអន្តរជាតិជាំ និង

-លោក **ស៊្រឹន យ៉ុង** និងលោកស្រី **ពៅ ដានី** ។

៧-កងអនុសេនាធំលេខ៧ ស្រុកអន្លង់វែង ចងសម្ព័ន្ធមេត្រីភាពជាមួយ :

-សាលាស្រុកអន្លង់វែង

-ក្រុមហ៊ុនអគ្គិសនីអន្លង់វែង(លោកស្រី **ញឹក សុខអៀង**)

-ក្រុមហ៊ុន សំរោងរ៉ាប់ប័រ

-លោកប្រធានទីស្នាក់ការច្រកទ្វារព្រំដែនអន្តរជាតិជាំ

-មន្ទីររៀបចំដែនដី នគរូបនីយកម្ម និងសំណង់ និង

-មន្ទីរទេសចរណ៍ ។

៨-កងអនុសេនាធំលេខ៨ ក្រុងសំរោង ចងសម្ព័ន្ធមេត្រីភាពជាមួយ :

-សាលាក្រុងសំរោង

-អង្គភាពរដ្ឋបាលព្រៃឈើប្រចាំក្រុងសំរោង

-សាខាគយ និងរដ្ឋាករ

-ទីស្នាក់ការគយ និងរដ្ឋាករប្រចាំច្រកព្រំដែនអន្តរជាតិអូរស្មាច់

-ទីស្នាក់ការកាំកុងត្រូលប្រចាំច្រកព្រំដែនអន្តរជាតិអូរស្មាច់

-ក្រុមហ៊ុនម៉ាស៊ីនកិនស្រូវ អេងសួ និង

-ក្រុមហ៊ុន SORLA INVESTMENT Co.,LTD. ។

៩-កងអនុសេនាធំលេខ៩ ក្រុងសំរោង ចងសម្ព័ន្ធមេត្រីភាពជាមួយ :

-សាលាក្រុងសំរោង

-មន្ទីរអប់រំ យុវជន និងកីឡា

-មន្ទីរវប្បធម៌ និងវិចិត្រសិល្បៈ

-មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

-រតនាគារខេត្ត

-មន្ទីរព័ត៌មាន និង

-ក្រុមហ៊ុន SORLA INVESTMENT Co.,LTD. ។

១០-កងអនុសេនាធំលេខ១០ ស្រុកបន្ទាយអំពិល ចងសម្ព័ន្ធមេត្រីភាពជាមួយ :

-សាលាស្រុកបន្ទាយអំពិល

-ក្រុមហ៊ុន ពន្លឺមានជ័យ ខនស្រ្តាក់សិន

-មន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

-មន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា

-មន្ទីរឧស្សាហកម្ម រ៉ែ និងថាមពល និង

-ឧកញ៉ា **គុជ ស៊ីនិត**។

១១-កងអនុសេនាធំលេខ១១ ស្រុកបន្ទាយអំពិល ចងសម្ព័ន្ធមេត្រីភាពជាមួយ :

-សាលាស្រុកបន្ទាយអំពិល

-អង្គភាពរដ្ឋបាលព្រៃឈើប្រចាំស្រុកបន្ទាយអំពិល

-មន្ទីរសុខាភិបាល

-មន្ទីរអភិវឌ្ឍន៍ជនបទ និង

-ឧកញ៉ា **គុជ ស៊ីនិត**

-ខេត្តសៀមរាប

កងវរសេនាតូចការពារព្រំដែនលេខ៤០៨ ខេត្តសៀមរាប ចងសម្ព័ន្ធមេត្រីភាពជាមួយ :

-ឯកឧត្តមឧកញ៉ា **សៀង ណាំ**។

ក.៣-យោធភូមិភាគទី៥

-ខេត្តបន្ទាយមានជ័យ

១-កងវរសេនាតូចការពារព្រំដែនលេខ៥០៥ ខេត្តបន្ទាយមានជ័យ ចងសម្ព័ន្ធមេត្រីភាពជាមួយ :

-សាលាខេត្តបន្ទាយមានជ័យ

-សាលាក្រុងសិរីសោភ័ណ

-មន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

-សាខាគយ និងរដ្ឋាករខេត្ត

-ខណ្ឌរដ្ឋបាលជលផល

-ច្រកទ្វារអន្តរជាតិប៉ោយប៉ែត

-ក្រុមហ៊ុន លីអ៊ុតនីអ៊ុមផត អ៊ិចផត

-សមាគមរោងម៉ាស៊ីនកិនស្រូវបន្ទាយមានជ័យ

-ក្រុមហ៊ុន អានកូ និងក្រុមហ៊ុនកាស៊ីណូហ្គោលដិនហ្វ្រោន របស់ឯកឧត្តមឧកញ៉ា **គុក អាន**

-ឧកញ៉ា **សូ ងួន** និង

-ឧកញ៉ា **ខូវ សម្បត្តិ**។

២-កងអនុសេនាធំលេខ១ ស្រុកថ្មពួក ចងសម្ព័ន្ធមេត្រីភាពជាមួយ :

-សាលាស្រុកថ្មពួក

-សាលាស្រុកព្រះនេត្រព្រះ

-មន្ទីរសង្គមកិច្ចអតីតយុទ្ធជន និងយុវនីតិសម្បទា

-មន្ទីរអភិវឌ្ឍន៍ជនបទខេត្ត

-មន្ទីរវប្បធម៌ និងវិចិត្រសិល្បៈ

-សាខាពន្ធដារខេត្ត

-ច្រកទ្វារបឹងត្រកួន

-ការដ្ឋានផលិតថ្ម ណុប ទួច និង

-ការដ្ឋានផលិតថ្ម អាំង គីហេង ។

៣-កងអនុសេនាធំលេខ២ ស្រុកថ្មពួក ចងសម្ព័ន្ធមេត្រីភាពជាមួយ :

-សាលាស្រុកមង្គលបុរី

-សាលាស្រុកភ្នំស្រុក

-មន្ទីរឧស្សាហកម្ម រ៉ែ និងថាមពល

-មន្ទីរកសិកម្ម

-មន្ទីរសុខាភិបាល

-អគ្គិសនីខេត្ត

-រតនាគារខេត្ត

-មន្ទីរធម្មការ និងសាសនា

-ខណ្ឌរដ្ឋបាលព្រៃឈើ

-សណ្ឋាគារសែសិន

-ភោជនីយដ្ឋានជំនោរសែសិន និង

-ការដ្ឋានថ្ម លីម ហេង ។

៤-កងអនុសេនាធំលេខ៣ ស្រុកស្វាយចេក ចងសម្ព័ន្ធមេត្រីភាពជាមួយ :

-សាលាស្រុកស្វាយចេក

-មន្ទីរអប់រំ យុវជន និងកីឡា

-មន្ទីរធនធានទឹក និងឧតុនិយម

-មន្ទីរពាណិជ្ជកម្ម

-ក្រុមហ៊ុនតៃហាំងអភិវឌ្ឍន៍

-ក្រុមហ៊ុនទ្រីស្រ៊ាង

-ការដ្ឋានថ្មកូណៃ និង

-ភោជនីយដ្ឋានបឹងឈូក ។

៥-កងអនុសេនាធំលេខ៤ ក្រុងប៉ោយប៉ែត ចងសម្ព័ន្ធមេត្រីភាពជាមួយ :

-សាលាក្រុងប៉ោយប៉ែត

-មន្ទីរទេសចរណ៍

-មន្ទីរកិច្ចការនារី

-មន្ទីរព័ត៌មាន

-មន្ទីរប្រៃសណីយ៍ និងទូរគមនាគមន៍

-ធនាគារខេត្ត

-កាំកុងត្រូលខេត្ត

-ក្រុមហ៊ុនលីហួរគាងអ៊ិមផត អ៊ិចផត

-ក្រុមហ៊ុនភីអេភីស៊ីគ្រុបខូអិលធីឌី និង

-ការដ្ឋានថ្មលីមសុថារី ។

៦-កងអនុសេនាធំលេខ៥ ស្រុកម៉ាឡៃ ចងសម្ព័ន្ធមេត្រីភាពជាមួយ :

-សាលាស្រុកម៉ាឡៃ

-មន្ទីរផែនការ

-មន្ទីរបរិស្ថាន

-មន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដី

-មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

-មន្ទីរទំនាក់ទំនងជាមួយរដ្ឋសភា ព្រឹទ្ធសភា និងអធិការកិច្ច

-មន្ទីរសាធារណការ និងដឹកជញ្ជូន

-ច្រកទ្វារតំបន់ម៉ាឡៃ

-ក្រុមហ៊ុនម៉ាឡៃត្រេឌីង និង

-ក្រុមហ៊ុនទ្រីទូចអ៊ិនវេសមិន ។

.ខេត្តបាត់ដំបង

១-កងវរសេនាតូចការពារព្រំដែនលេខ៥០៦ ខេត្តបាត់ដំបង ចងសម្ព័ន្ធមេត្រីភាពជាមួយ :

-សាលាក្រុងបាត់ដំបង

-មន្ទីរកសិកម្ម និង

-សម្ព័ន្ធម៉ាស៊ីនកិនស្រូវកម្ពុជា ។

២-កងវរសេនាតូចការពារព្រំដែនលេខ៥០៩ ខេត្តបាត់ដំបង ចងសម្ព័ន្ធមេត្រីភាពជាមួយ :

-មន្ទីរសាធារណការ និងដឹកជញ្ជូន

-ក្រុមហ៊ុនដឹកជញ្ជូនប៉ាស៊ីហ្វិក

-ក្រុមហ៊ុនដឹកជញ្ជូនត្បូងពេជ្រ និង

-ក្រុមហ៊ុន ជីប ម៉ុង Group (ដែក ស៊ីម៉ង់) របស់ឧកញ៉ា **លាង ឃុន** ។

៣-កងអនុសេនាធំលេខ៦ ស្រុកសំពៅលូន និងផ្នែកសឹករងស្រុកសំពៅលូន ចងសម្ព័ន្ធមេត្រីភាពជាមួយ :

-សាលាស្រុកសំពៅលូន

-មន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីខេត្ត

-មន្ទីរសុខាភិបាល

-ខណ្ឌរដ្ឋបាលជលផលបាត់ដំបង

-ម្ចាស់អាជីវកម្មឡូតិ៍នេសាទលេខ២ និង

-ម្ចាស់អាជីវកម្មឡូតិ៍នេសាទលេខ៦។

៤-កងអនុសេនាធំលេខ៧ ស្រុកភ្នំព្រឹក និងផ្នែកសឹករងស្រុកភ្នំព្រឹក ចងសម្ព័ន្ធមេត្រីភាពជាមួយ :

-សាលាស្រុកភ្នំព្រឹក

-មន្ទីរពាណិជ្ជកម្ម

-មន្ទីរទេសចរណ៍

-សាខាគយ និងរដ្ឋាករ

-សាខាកាំកុងត្រូល

-ម្ចាស់អាជីវកម្មឡូតិ៍នេសាទលេខ១

-ម្ចាស់អាជីវកម្មឡូតិ៍នេសាទលេខ៤ និង

-សមាគមស្រូវមាសកម្ពុជា។

៥-កងអនុសេនាធំលេខ៨ ស្រុកកំរៀង និងផ្នែកសឹករងស្រុកកំរៀង ចងសម្ព័ន្ធមេត្រីភាពជាមួយ :

-សាលាស្រុកកំរៀង

-មន្ទីសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

-សាខាពន្ធដារខេត្ត និង

-ក្រុមហ៊ុន ប្រាណស៊ី អាហារ៍ណ នីហារ៍ណ ។

៦-កងអនុសេនាធំលេខ៩ ស្រុកសំឡូត និងផ្នែកសឹករងស្រុកសំឡូត ចងសម្ព័ន្ធមេត្រីភាពជាមួយ :

-សាលាស្រុកសំឡូត

-មន្ទីរឧស្សាហកម្ម រ៉ែ និងថាមពលខេត្ត និងអង្គភាពរដ្ឋាករទឹកបាត់ដំបង

-អង្គភាពអគ្គិសនីបាត់ដំបង

-ក្រុមហ៊ុន ហុង ហួតលី (ថ្មសំណង់ភ្នំតាគ្រាម) និង

-ឧកញ៉ា **ណាង សុធី**។

-ខេត្តប៉ៃលិន

១-កងវរសេនាតូចការពារព្រំដែនលេខ៩០៧ ខេត្តប៉ៃលិន ចងសម្ព័ន្ធមេត្រីភាពជាមួយ :

-សាលាខេត្តប៉ៃលិន

-មន្ទីរសាធារណការ និងដឹកជញ្ជូន

-មន្ទីរអភិវឌ្ឍន៍ជនបទ

-មន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

-មន្ទីរពាណិជ្ជកម្ម

-មន្ទីរព័ត៌មាន

-មន្ទីរទេសចរណ៍

-មន្ទីរប្រៃសណីយ៍ និងទូរគមនាគមន៍

-មន្ទីរបរិស្ថាន

-សាខាគយ និងរដ្ឋាករខេត្ត

-រតនាគារខេត្ត

-សាខាប្រព័ន្ធទូរស័ព្ទ Metfone

-លោកស្រី **ជឹង យូគៀង** ក្រុមអាជីវករ

-លោកស្រី **ស៊ុម ប៉ាង** ក្រុមហ៊ុនពេជ្រសំណាង និង

-លោកស្រី **ឃុត សុធារី** ក្រុមអាជីវករ ។

២-កងអនុសេនាធំលេខ១១០ ស្រុកសាលាក្រៅ និងផ្នែកសឹករងស្រុកសាលាក្រៅ ចងសម្ព័ន្ធមេត្រីភាពជាមួយ :

-មន្ទីរអប់រំ យុវជន និងកីឡា

-មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

-មន្ទីរធនធានទឹក និងឧតុនិយម

-មន្ទីរកិច្ចការនារី

-ផ្នែករដ្ឋបាលព្រៃឈើ

-ទីស្នាក់ការគយ និងរដ្ឋាករ ច្រកទ្វារព្រំដែន

-លោក **ឡោ ស៊ុនជាង** ក្រុមអាជីវករ

-លោក **ឃុន វណ្ណៈ** ក្រុមហ៊ុនឃុនវណ្ណៈវឌ្ឍនៈភាព

-សាខាប្រព័ន្ធទូរស័ព្ទ Samart

-សាខាប្រព័ន្ធទូរស័ព្ទ Mfone

-លោក **លី** ប្រធានទីស្នាក់ការផ្សារប៉ាហ៊ី និង

៣-កងអនុសេនាធំលេខ១១ ក្រុងប៉ៃលិន និងផ្នែកសឹករងក្រុងប៉ៃលិន ចងសម្ព័ន្ធមេត្រីភាពជាមួយ :

-មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

-មន្ទីរធម្មការ និងសាសនា

-សាខាពន្ធដារខេត្ត

-មន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា

-មន្ទីរផែនការ

-មន្ទីរវប្បធម៌ និងវិចិត្រសិល្បៈ

-មន្ទីរទំនាក់ទំនងជាមួយរដ្ឋសភា ព្រឹទ្ធសភា និងអធិការកិច្ច

-ក្រុមហ៊ុន ឆឹន-ផៃ-វិស្វកម្ម(អគ្គិសនី)

-លោក **សេង គីម** ក្រុមហ៊ុនសាងសង់ផ្លូវលំ

-សាខាប្រព័ន្ធទូរស័ព្ទ Mobitel

-សាខាប្រព័ន្ធទូរស័ព្ទ Beeline

-លោក **ខាត់ សារឿន** សិប្បកម្មឡសំងួតកសិផល

-លោក **ថូ ម៉ាស់** អាជីវកម្មទឹកស្អាត

-លោកស្រី **ឡេង សុភា** អាជីវករ(បែមប៊ូ) និង

-សាខាធនាគារ "**កាណាឌីយ៉ា ចំការ់**"។

-ខេត្តពោធិ៍សាត់

១-កងវរសេនាតូចការពារព្រំដែនលេខ៥០៨ ខេត្តពោធិ៍សាត់ ចងសម្ព័ន្ធមេត្រីភាពជាមួយ :

-សាលាខេត្តពោធិ៍សាត់ និងមន្ទីរអង្គភាពទាំងអស់ជុំវិញខេត្ត

-ក្រុមហ៊ុន YE TAK GROUP របស់ឧកញ៉ា **ថៃ ហុកឈួន**

-ក្រុមហ៊ុន H & L Group របស់ឧកញ៉ា **អ៊ឹង លីហេង**

-ឯកឧត្តម **មុយ គី** ប្រធានសភាពាណិជ្ជកម្មខេត្ត និងសមាជិកសភាពាណិជ្ជកម្មខេត្តទាំងអស់

-លោក **គួយ វុច** ម្ចាស់សណ្ឋាគារពោធិ៍សាត់សិនជ្ជឺរី

-លោក **ឌួន សេង** ម្ចាស់សណ្ឋាគារភ្នំពេជ្រ

-លោក **លី សាវុធ** ប្រធានឡូតិ៍នេសាទលេខ១

-លោក **ភោគ ហ៊ួច** ប្រធានឡូតិ៍នេសាទលេខ២

-លោក **សែម វៃ** ប្រធានឡូតិ៍នេសាទលេខ៣

-លោក **ចាម ឈុន** ប្រធានឡូតិ៍នេសាទលេខ៦

-លោក **ឈូរ ងួន** ប្រធានឡូតិ៍នេសាទលេខ៧

-លោក **ខៀ ហេង** ប្រធានស្ថានីយ៍ប្រេងឥន្ធនៈ និង

-លោក **អៀ ឆាយមីន** អាជីវករផ្សារថ្មីខេត្ត។

២-កងអនុសេនាធំលេខ១១២ ស្រុកវាលវែង ចងសម្ព័ន្ធមេត្រីភាពជាមួយ :

-សាលាខេត្តពោធិ៍សាត់ និងមន្ទីរអង្គភាពទាំងអស់ជុំវិញខេត្ត

-ឧកញ៉ា **មុយ គី** ប្រធានសភាពាណិជ្ជកម្មខេត្ត និងសមាជិកសភាពាណិជ្ជកម្មខេត្តទាំងអស់

-ឧកញ៉ា **ហាន់ ឃាង**

-លោក **គួយ វុច** ម្ចាស់សណ្ឋាគារពោធិ៍សាត់សិនជ្ជឺរី

-លោក **ឌួន សេង** ម្ចាស់សណ្ឋាគារភ្នំពេជ្រ

-លោក **លី សាវុធ** ប្រធានឡូតិ៍នេសាទលេខ១

-លោក **ភោគ ហ៊ួច** ប្រធានឡូតិ៍នេសាទលេខ២

-លោក **សែម រ៉ៃ** ប្រធានឡូតិ៍នៃសាទលេខ៣

-លោក **ធាម ឈុន** ប្រធានឡូតិ៍នៃសាទលេខ៦

-លោក **ឈួរ ងួន** ប្រធានឡូតិ៍នៃសាទលេខ៧

-លោក **ខៀ ហេង** ប្រធានស្ថានីយ៍ប្រេងឥន្ធនៈ និង

-លោក **អៀ នាយងីន** អាជីវករផ្សារថ្មីខេត្ត ។

ខ.អង្គភាពនគរបាលជាតិ :

.ភូមិភាគពិសេស

១-វរៈសេនាតូចព្រំដែនគោក៦០៥ ចងសម្ព័ន្ធមេត្រីភាពជាមួយ ក្រុមហ៊ុនដឹកជញ្ជូន UNION របស់ឯកឧត្តម **លី ផង់** ។

.ភូមិភាគ១

១-វរៈសេនាតូចព្រំដែនគោក៦២៣ ចងសម្ព័ន្ធមេត្រីភាពជាមួយ ក្រុមហ៊ុន Seng Enterprise របស់ឯកឧត្តមឧកញ៉ា **សេង នាយអ៊ួ**

២-វរៈសេនាតូចព្រំដែនគោក២០៣ ចងសម្ព័ន្ធមេត្រីភាពជាមួយ ក្រុមហ៊ុន TI.E.STEEL Coprporation Co.,Ltd. របស់ឯកឧត្តម **ឡុច សារ៉េត** ។

៣-វរៈសេនាតូចព្រំដែនគោក៧០១ ចងសម្ព័ន្ធមេត្រីភាពជាមួយ ឯកឧត្តម **សូត្រ សម្បត្តិ** ។

៤-វរៈសេនាតូចព្រំដែនគោក៣០៣ ចងសម្ព័ន្ធមេត្រីភាពជាមួយ ក្រុមហ៊ុនដឹកជញ្ជូន Golden China Group. ។

៥-វរៈសេនាតូចព្រំដែនគោក៦២១ ចងសម្ព័ន្ធមេត្រីភាពជាមួយ សណ្ឋាគារអប្សរាអង្គរ ខេត្តសៀមរាបរបស់ឯកឧត្តម **ហាក់ ប៊ុនថា** ។

.ភូមិភាគ២

១-វរៈសេនាតូចព្រំដែនគោក៦០៩ ចងសម្ព័ន្ធមេត្រីភាពជាមួយ ក្រុមហ៊ុនលី ហួរ ។

២-វរៈសេនាតូចព្រំដែនគោក៦១១ ចងសម្ព័ន្ធមេត្រីភាពជាមួយ ឯកឧត្តមឧកញ៉ា **ខូវ គឹមបាក់** ។

៣-វរៈសេនាតូចព្រំដែនគោក៦០៧ ចងសម្ព័ន្ធមេត្រីភាពជាមួយ ក្រុមហ៊ុន ខូវ ជូលីគ្រុប របស់ឯកឧត្តមឧកញ៉ា **ខូវ ជូលី** ។

៤-វរៈសេនាតូចព្រំដែនគោក៦១៩ ចងសម្ព័ន្ធមេត្រីភាពជាមួយ ក្រុមហ៊ុន សុណាត្រា របស់ឯកឧត្តមឧកញ៉ា **ស៊ិន សុខណា** ។

៥-វរៈសេនាតូចព្រំដែនគោក៦១៥ ចងសម្ព័ន្ធមេត្រីភាពជាមួយ ក្រុមហ៊ុន ឈុន ហុង របស់ឯកឧត្តមឧកញ៉ា **ទី ពិសិដ្ឋ** ។

៦-វរៈសេនាតូចព្រំដែនគោក៦១៧ ចងសម្ព័ន្ធមេត្រីភាពជាមួយ ក្រុមហ៊ុន H.S.C របស់ឯកឧត្តមឧកញ៉ា **សុខ ហុង** ។

.ភូមិភាគ៣

១-វរៈសេនាតូចព្រំដែនទឹក២០៤ ចងសម្ព័ន្ធមេត្រីភាពជាមួយ ឯកឧត្តមឧកញ៉ា **ប៉ៅ ស៊ុនលី** ។

២-វរៈសេនាតូចព្រំដែនទឹក២៤១ ចងសម្ព័ន្ធមេត្រីភាពជាមួយ ក្រុមហ៊ុន អ៊ី ឆែ របស់ឯកឧត្តមឧកញ៉ា **តែ អ៊ីឆែ** ។

៣-វរៈសេនាតូចព្រំដែនគោក៦០១ ចងសម្ព័ន្ធមេត្រីភាពជាមួយ ក្រុមហ៊ុន I.S.I របស់ឯកឧត្តមឧកញ៉ា **កាំង ម៉េងហុយ** ។

៤-វរៈសេនាតូចព្រំដែនគោក៤៣០ ចងសម្ព័ន្ធមេត្រីភាពជាមួយ ក្រុមហ៊ុន ស៊ូន ស៊ូន របស់ឯកឧត្តមឧកញ៉ា **គី មីតា** ។

៥-វរៈសេនាតូចព្រំដែនគោក៦០៣ ចងសម្ព័ន្ធមេត្រីភាពជាមួយ ក្រុមហ៊ុន P.B.C របស់ឯកឧត្តមឧកញ៉ា **ផាត់ ប៊ុន** ។

.ខេត្តប៉ៃលិន

អង្គភាពកងនគរបាលវរៈការពារព្រំដែនលេខ៨២១ នៃស្នងការនគរបាលខេត្តប៉ៃលិន ចងសម្ព័ន្ធមេត្រីភាព ជាមួយ :

-ក្រុមប្រឹក្សាខេត្តប៉ៃលិន

-មន្ទីរសុខាភិបាលខេត្តប៉ៃលិន

-មន្ទីរឧស្សាហកម្ម រ៉ែ និងថាមពលខេត្ត

-កាំកុងត្រូល

-មន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីខេត្ត

-ប៉ុស្តិ៍នគរបាលអន្តោប្រវេសន៍ប្រចាំច្រកទ្វារព្រំដែន

-លោកស្រី **ឈុន សារីម** (សិប្បកម្មឡសំងួតកសិផល)

-លោកស្រី **ហួរ វណ្ណធី** (ហៅមិុញ) សិប្បកម្មឡសំងួតកសិផល និង

-លោក **ឡុង ស៊ីឡឿន** (ក្រុមហ៊ុនអភិវឌ្ឍន៍អាជីវកម្មចំណតរថយន្ត) ។

ប្រការ ២.-

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ អគ្គមេបញ្ជាការ នៃកងយោធពលខេមរភូមិន្ទ អគ្គស្នងការនគរបាលជាតិ អគ្គនាយកភស្តុភានិងហិរញ្ញវត្ថុនៃក្រសួងមហាផ្ទៃ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួងស្ថាប័នពាក់ព័ន្ធ ប្រធានស្ថាប័ន-អង្គភាព មេបញ្ជាការអង្គភាព និងសាមីខ្លួនដូចមានចែងក្នុងប្រការ ១ ត្រូវអនុវត្តសេចក្តីសម្រេចនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ០៩ ខែ មីនា ឆ្នាំ ២០១០

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល :

-ក្រសួងព្រះបរមរាជវាំង

-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា

-អគ្គលេខាធិការដ្ឋានរដ្ឋសភា

-អគ្គលេខាធិការរាជរដ្ឋាភិបាល

-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី

-ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី

-ដូចប្រការ ២

-រាជកិច្ច

-ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ: ០១ សរ

សារាចរ
ស្តីពី
ការធ្វើជំរឿនមន្ត្រីរាជការស៊ីវិល

ចាប់តាំងពីនីតិកាលទី១ នៃរដ្ឋសភា ឆ្នាំ១៩៩៣ រហូតមកដល់បច្ចុប្បន្ននេះ ក្នុងក្របខ័ណ្ឌនៃការអនុវត្តកម្មវិធីជាតិកំណែទម្រង់រដ្ឋបាលសាធារណៈ រាជរដ្ឋាភិបាលបានដំណើរការធ្វើជំរឿនមន្ត្រីរាជការស៊ីវិលចំនួន២លើករួចមកហើយ គឺលើកទី១ នៅឆ្នាំ ១៩៩៥ និងលើកទី២ នៅឆ្នាំ ១៩៩៩-២០០១។ តាមរយៈលទ្ធផលនៃការធ្វើជំរឿនទាំងពីរលើកនេះ គណៈកម្មការជំរឿនមន្ត្រីរាជការបានរកឃើញមន្ត្រីដែលមានតែឈ្មោះក្នុងក្របខ័ណ្ឌ និងក្នុងបញ្ជីបើកបៀវត្ស(មន្ត្រីខ្មោច) ព្រមទាំងមន្ត្រីមិនប្រក្រតីផ្សេងៗទៀតជាច្រើន ហើយរាជរដ្ឋាភិបាលបានសម្រេចលុបឈ្មោះមន្ត្រីទាំងនោះ ចេញពីក្របខ័ណ្ឌ និងពីតារាងទូទាត់បៀវត្សចំនួន ១៧ ៦៨៥ នាក់ នៅលើកទី១ និង ៩ ៨១៤ នាក់បន្ថែមទៀតនៅលើកទី២ ដែលធ្វើឱ្យរដ្ឋចំណេញថវិកាយ៉ាងច្រើនក្នុងមួយឆ្នាំៗ។ម្យ៉ាងទៀត ផ្តើមចេញពីលទ្ធផលនៃការធ្វើជំរឿនកន្លងមក មូលដ្ឋានទិន្នន័យមន្ត្រីរាជការស៊ីវិលទូទាំងប្រទេសត្រូវបានកសាងឡើង និងប្រើប្រាស់ជាឧបករណ៍សម្រាប់ពង្រឹងការគ្រប់គ្រងរហូតមកដល់សព្វថ្ងៃនេះ ។

ក្នុងគោលបំណងពង្រឹងការគ្រប់គ្រងចំនួនមន្ត្រីរាជការស៊ីវិលឱ្យបានហ្មត់ចត់ និងធានាបានប្រសិទ្ធភាពការងារ និងគណនេយ្យភាពក្នុងរដ្ឋបាលសាធារណៈ រាជរដ្ឋាភិបាលបានសម្រេចឱ្យក្រុមប្រឹក្សាកំណែទម្រង់រដ្ឋបាល រៀបចំធ្វើជំរឿនមន្ត្រីរាជការស៊ីវិលទូទាំងប្រទេស ដែលស្ថិតនៅក្រោមការគ្រប់គ្រងនៃច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា និងមន្ត្រីជាប់កិច្ចសន្យាដែលកំពុងបម្រើការងារនៅតាមក្រសួង ស្ថាប័នរបស់រាជរដ្ឋាភិបាល ។

គណៈកម្មការអន្តរក្រសួងមួយនឹងត្រូវបង្កើតឡើង ដើម្បីអនុវត្តប្រតិបត្តិការជំរឿន ក្រោមការដឹកនាំ និងគ្រប់គ្រងរបស់ក្រុមប្រឹក្សាកំណែទម្រង់រដ្ឋបាល ។ ប្រតិបត្តិការជំរឿនមន្ត្រីរាជការស៊ីវិលមានបីផ្នែក គឺ ៖

ទី១- ការរាប់មន្ត្រីរាជការ: នឹងធ្វើឡើងជាលក្ខណៈរូបវ័ន្ត ហើយតម្រូវឱ្យមន្ត្រីរាជការមានវត្តមានដោយផ្ទាល់ នៅតាមទីកន្លែងកំណត់សម្រាប់ការធ្វើប្រតិបត្តិការជំរឿន ។

ទី២- ការចែកអត្តសញ្ញាណប័ណ្ណមន្ត្រីៈ មន្ត្រីរាជការគ្រប់រូបដែលមានវត្តមានក្នុងពេលរាប់ នឹងទទួលបាន អត្តសញ្ញាណប័ណ្ណមន្ត្រីរាជការថ្មីរបស់ខ្លួន សម្រាប់ប្រើប្រាស់ ។

ទី៣- ការបំពេញព័ត៌មានសម្រាប់ធ្វើបច្ចុប្បន្នភាពទិន្នន័យមន្ត្រីរាជការ ដែលជាផ្នែកមួយនៃការធ្វើជំរឿនៈ

នៅពេលចុះប្រតិបត្តិការជំរឿន មន្ត្រីរាជការស៊ីវិលគ្រប់រូបនឹងត្រូវបានផ្តល់ជូនកម្រងសំណួរដែលរៀបចំឡើង ដោយគណៈកម្មការជំរឿន និងតម្រូវឱ្យបំពេញព័ត៌មានផ្ទាល់ខ្លួនចាំបាច់មួយចំនួន។

ដើម្បីធានាឱ្យបានជោគជ័យនូវប្រតិបត្តិការជំរឿននេះ គ្រប់ក្រសួង ស្ថាប័ន ត្រូវសហការឱ្យបានជិតស្និទ្ធជាមួយគណៈកម្មការជំរឿនមន្ត្រីរាជការស៊ីវិល ដោយត្រូវផ្តល់ព័ត៌មានឱ្យបានគ្រប់គ្រាន់ និងច្បាស់លាស់ដល់មន្ត្រីរាជការក្នុងក្រសួង ស្ថាប័ន និងអង្គភាពក្រោមឱវាទរបស់ខ្លួន អំពីយុទ្ធនាការជំរឿនមន្ត្រីរាជការស៊ីវិល និងត្រូវចាត់តាំងតំណាងជាមន្ត្រីជាន់ខ្ពស់ និងមន្ត្រីជំនាញពាក់ព័ន្ធនឹងការងារគ្រប់គ្រងបុគ្គលិក ឱ្យចូលរួមសម្របសម្រួលក្នុងប្រតិបត្តិការជំរឿន និងចូលរួមទទួលខុសត្រូវក្នុងការចុះហត្ថលេខាលើរបាយការណ៍បូកសរុបលទ្ធផលជំរឿន នៅតាមក្រសួង ស្ថាប័ន និងអង្គភាពរបស់ខ្លួន។

ទទួលបានសារាចរនេះ រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និងជាប្រធានក្រុមប្រឹក្សាកំណែទម្រង់រដ្ឋបាល រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័ន គ្រប់អភិបាលនៃគណៈអភិបាលរាជធានី ខេត្ត និងក្រុមប្រឹក្សារាជធានី ខេត្តទាំងអស់ ត្រូវយកអស់ស្មារតីទទួលខុសត្រូវ និងសហការអនុវត្តការងារនេះឱ្យទទួលបានជោគជ័យ និងមានប្រសិទ្ធភាពខ្ពស់។

រាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែ មីនា ឆ្នាំ ២០១០

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

<u>កន្លែងទទួល ៖</u>

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចតេជោ នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- គ្រប់ក្រសួង ស្ថាប័ន
- គ្រប់សាលារាជធានី-ខេត្ត
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

SECURITIES AND EXCHANGE COMMISSION OF CAMBODIA

គណៈកម្មការមូលបត្រកម្ពុជា

លេខៈ......០១២.........គ.ម.ក.ប្រ.ក

លិខិតចូល

ថ្ងៃទី..០៣...ខែ..មីនា...ឆ្នាំ2010

ប្រកាស

ស្តីពី

ការរៀបចំ និងការប្រព្រឹត្តទៅនៃនាយកដ្ឋានគ្រប់គ្រងការបោះផ្សាយលក់មូលបត្រ នៃគណៈកម្មការមូលបត្រកម្ពុជា

* * * * *

ឧបនាយករដ្ឋមន្ត្រី

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

និងជាប្រធានគណៈកម្មការមូលបត្រកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៧/០០១ ចុះថ្ងៃទី១០ ខែមករា ឆ្នាំ២០០៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីមូលបត្ររដ្ឋ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១០០៧/០២៨ ចុះថ្ងៃទី១៩ ខែតុលា ឆ្នាំ២០០៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន
- បានឃើញអនុក្រឹត្យលេខ ៩៧ អនក្រ/បក ចុះថ្ងៃទី២៣ ខែកក្កដា ឆ្នាំ២០០៨ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មការមូលបត្រកម្ពុជា
- បានឃើញអនុក្រឹត្យលេខ ៥៤ អនក្រ/បក ចុះថ្ងៃទី០៨ ខែមេសា ឆ្នាំ២០០៩ ស្តីពីការអនុវត្តច្បាប់ស្តីពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន
- យោងតាមការអនុម័តនៃសម័យប្រជុំពេញអង្គរបស់គណៈកម្មការមូលបត្រកម្ពុជា នាថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០០៩

សម្រេច

ប្រការ ១.-

ប្រកាសនេះមានគោលដៅកំណត់ពីការរៀបចំ និងការប្រព្រឹត្តទៅរបស់នាយកដ្ឋានគ្រប់គ្រងការបោះផ្សាយលក់មូលបត្រនៃគណៈកម្មការមូលបត្រកម្ពុជាដែលមានតួនាទី និងភារកិច្ចដូចមានចែងក្នុងអនុក្រឹត្យលេខ ៩៧ អនក្រ/បក ចុះថ្ងៃទី ២៣ ខែ កក្កដា ឆ្នាំ ២០០៨ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មការមូលបត្រកម្ពុជា (**គ.ម.ក.**)។

ប្រការ ២.-

នាយកដ្ឋានគ្រប់គ្រងការបោះផ្សាយលក់មូលបត្រ ដឹកនាំដោយប្រធាន ០១ (មួយ) រូប និងមានអនុប្រធានមួយចំនួនជាជំនួយការ តាមការចាំបាច់។

ប្រការ ៣.-

នាយកដ្ឋានគ្រប់គ្រងការបោះផ្សាយលក់មូលបត្រមានការិយាល័យចំណុះចំនួន ០៣ (បី) ដូចខាងក្រោម ÷

១- ការិយាល័យបោះផ្សាយមូលបត្រ និងឯកសារផ្តល់ព័ត៌មាន

២- ការិយាល័យអភិបាលកិច្ចសាជីវកម្ម

៣- ការិយាល័យត្រួតពិនិត្យកិច្ចការគណនេយ្យ

ការិយាល័យនីមួយៗ ដឹកនាំដោយប្រធាន ០១ (មួយ) រូប និងមានអនុប្រធានមួយចំនួនជាជំនួយការ តាមការចាំបាច់។

អង្គការលេខរបស់នាយកដ្ឋានគ្រប់គ្រងការបោះផ្សាយលក់មូលបត្រ ជាឧបសម្ព័ន្ធនៃប្រកាសនេះ។

ប្រការ ៤.-

ការិយាល័យបោះផ្សាយមូលបត្រ និងឯកសារផ្តល់ព័ត៌មាន មានតួនាទី និងភារកិច្ច ដូចខាងក្រោម ÷

- រៀបចំបទប្បញ្ញត្តិ ឬលក្ខខណ្ឌតម្រូវនានា សម្រាប់ផ្តល់ការអនុញ្ញាតឱ្យក្រុមហ៊ុនបោះផ្សាយលក់មូលបត្រជាសាធារណៈ
- រៀបចំបទប្បញ្ញត្តិកំណត់ពីគុណវុឌ្ឍិ ដើម្បីអនុញ្ញាតឱ្យក្រុមហ៊ុនវាយតម្លៃ ចូលរួមក្នុងដំណើរការបោះផ្សាយលក់មូលបត្រជាសាធារណៈ

- ពិនិត្យ និងផ្តល់យោបល់លើគុណវុឌ្ឍិ ដើម្បីអនុញ្ញាតឱ្យក្រុមហ៊ុនវាយតម្លៃចូលរួមក្នុងដំណើរការបោះផ្សាយលក់មូលបត្រជាសាធារណៈ
- រៀបចំបទប្បញ្ញត្តិកំណត់ពីគុណវុឌ្ឍិ ដើម្បីអនុញ្ញាតឱ្យបុគ្គលតំណាងអ្នកកាន់កាប់មូលបត្របំណុល ចូលរួមក្នុងដំណើរការបោះផ្សាយលក់មូលបត្រជាសាធារណៈ
- ពិនិត្យ និងផ្តល់យោបល់លើគុណវុឌ្ឍិ ដើម្បីអនុញ្ញាតឱ្យបុគ្គលតំណាងអ្នកកាន់កាប់មូលបត្របំណុល ចូលរួមក្នុងដំណើរការបោះផ្សាយលក់មូលបត្រជាសាធារណៈ
- រៀបចំសេចក្តីណែនាំ ទម្រង់លិខិតស្នាម និងព័ត៌មានផ្សេងៗពាក់ព័ន្ធនឹងការបោះផ្សាយលក់មូលបត្រជាសាធារណៈ
- រៀបចំនីតិវិធី និងយន្តការសម្រាប់ត្រួតពិនិត្យទ្រព្យសកម្ម ទ្រព្យអកម្ម រួមទាំងកត្តាផ្សេងទៀតដែលមានឥទ្ធិពលលើតម្លៃរបស់ក្រុមហ៊ុនបោះផ្សាយលក់មូលបត្រជាសាធារណៈ
- រៀបចំសេចក្តីណែនាំសម្រាប់វាយតម្លៃទ្រព្យសកម្ម ទ្រព្យអកម្ម រួមទាំងកត្តាផ្សេងទៀតដែលមានឥទ្ធិពលលើតម្លៃរបស់ក្រុមហ៊ុនបោះផ្សាយលក់មូលបត្រជាសាធារណៈ
- ពិនិត្យ និងផ្តល់យោបល់លើការស្នើសុំបោះផ្សាយលក់មូលបត្រជាសាធារណៈ
- ពិនិត្យ និងផ្តល់យោបល់លើលក្ខខណ្ឌនៃសំណើលក់ របស់ក្រុមហ៊ុនស្នើសុំបោះផ្សាយលក់មូលបត្រជាសាធារណៈ
- ពិនិត្យ និងផ្តល់យោបល់លើការស្នើសុំចុះបញ្ជីឯកសារផ្តល់ព័ត៌មាន ឯកសារផ្តល់ព័ត៌មានបន្ថែម ឯកសារផ្តល់ព័ត៌មានជំនួស និងសេចក្តីថ្លែងនានាដែលពាក់ព័ន្ធនឹងមូលបត្រ
- ចុះបញ្ជីឯកសារផ្តល់ព័ត៌មាន ឯកសារផ្តល់ព័ត៌មានបន្ថែម និង/ឬ ឯកសារផ្តល់ព័ត៌មានជំនួស របស់ក្រុមហ៊ុនបោះផ្សាយលក់មូលបត្រជាសាធារណៈ
- ពិនិត្យ និងផ្សព្វផ្សាយឯកសារផ្តល់ព័ត៌មាន ឯកសារផ្តល់ព័ត៌មានបន្ថែម ឯកសារផ្តល់ព័ត៌មានជំនួស និងសេចក្តីថ្លែងនានាដែលពាក់ព័ន្ធនឹងមូលបត្រ តាមប្រព័ន្ធអេឡិចត្រូនិច និង/ឬ តាមប្រព័ន្ធផ្សព្វផ្សាយសាធារណៈ
- ត្រួតពិនិត្យជាក់ស្តែងដល់ទីកន្លែងរបស់ក្រុមហ៊ុនស្នើសុំបោះផ្សាយលក់មូលបត្រជាសាធារណៈ តាមការចាំបាច់
- គ្រប់គ្រងយន្តការបោះផ្សាយលក់មូលបត្រជាសាធារណៈ
- ផ្ទៀងផ្ទាត់ការវាយតម្លៃប្រតិបត្តិការ ទ្រព្យសកម្ម ទ្រព្យអកម្ម រួមទាំងកត្តាផ្សេងទៀតដែលមានឥទ្ធិពលលើតម្លៃរបស់ក្រុមហ៊ុនបោះផ្សាយលក់មូលបត្រជាសាធារណៈ ហើយពិនិត្យដល់ទីកន្លែង ក្នុងករណីចាំបាច់

- រៀបចំករណីសង្ស័យអំពីការប្រព្រឹត្តល្មើសនឹងច្បាប់ និងបទប្បញ្ញត្តិពាក់ព័ន្ធនឹងការបោះផ្សាយលក់មូលបត្រជាសាធារណៈ និងការវាយតម្លៃសាជីវកម្ម ដើម្បីបញ្ជូនទៅនាយកដ្ឋានកិច្ចការគតិយុត្ត
- សិក្សាស្រាវជ្រាវការវិវត្តម៉ូដែល និងយន្តការវាយតម្លៃប្រតិបត្តិការ ទ្រព្យសកម្ម ទ្រព្យអកម្ម រួមទាំងកត្តាផ្សេងទៀតដែលមានឥទ្ធិពលលើតម្លៃរបស់ក្រុមហ៊ុនបោះផ្សាយលក់មូលបត្រជាសាធារណៈ ដោយគិតទាំងបរិការណ៍ជាតិ និងអន្តរជាតិ
- សហការរៀបចំគោលនយោបាយយុទ្ធសាស្ត្រ ដើម្បីជំរុញការបោះផ្សាយលក់មូលបត្រជាសាធារណៈ
- រៀបចំផែនការប្រចាំឆ្នាំស្តីពីការបោះផ្សាយលក់មូលបត្រជាសាធារណៈ
- តាមដានការអនុវត្តគោលនយោបាយ និងលទ្ធផលនៃការបោះផ្សាយលក់មូលបត្រជាសាធារណៈ
- តាមដានការវិវត្តនៃលក្ខខណ្ឌតម្រូវនៃការបោះផ្សាយលក់មូលបត្រជាសាធារណៈ ដោយគិតទាំងបរិការណ៍ជាតិ និងអន្តរជាតិ
- ចងក្រងទិន្នន័យ និងរក្សាទុករាល់ឯកសារផ្តល់ព័ត៌មាន ឯកសារផ្តល់ព័ត៌មានជំនួស ឯកសារផ្តល់ព័ត៌មានបន្ថែម និងឯកសារផ្សេងៗទៀតដែលពាក់ព័ន្ធនឹងក្រុមហ៊ុនបោះផ្សាយលក់មូលបត្រជាសាធារណៈ
- គ្រប់គ្រងទ្រព្យសម្បត្តិ និងរៀបចំបញ្ជីសារពើភណ្ឌរបស់នាយកដ្ឋានដែល **គ.ម.ក.** ប្រគល់ឱ្យ
- រៀបចំផែនការសកម្មភាពសម្រាប់អនុវត្តការងាររបស់ការិយាល័យ
- រៀបចំរបាយការណ៍ជាប្រចាំពាក់ព័ន្ធនឹងការអនុវត្តការងាររបស់ការិយាល័យ
- អនុវត្តការងារផ្សេងទៀតតាមការប្រគល់ជូនរបស់ប្រធាននាយកដ្ឋាន។

ប្រការ ៥.-

ការិយាល័យអភិបាលកិច្ចសាជីវកម្ម មានតួនាទី និងភារកិច្ច ដូចខាងក្រោម ៖

- រៀបចំលក្ខខណ្ឌតម្រូវនានាទាក់ទងនឹងអភិបាលកិច្ចសាជីវកម្មរបស់ក្រុមហ៊ុនបោះផ្សាយលក់មូលបត្រជាសាធារណៈ
- ពិនិត្យ និងផ្តល់យោបល់ពាក់ព័ន្ធនឹងអភិបាលកិច្ចរបស់ក្រុមហ៊ុនបោះផ្សាយលក់មូលបត្រជាសាធារណៈ

- រៀបចំគោលនយោបាយយុទ្ធសាស្ត្រ ដើម្បីជំរុញការអភិវឌ្ឍអភិបាលកិច្ចសាជីវកម្មរបស់ក្រុមហ៊ុនបោះផ្សាយលក់មូលបត្រជាសាធារណៈ
- រៀបចំសេចក្តីណែនាំ ទម្រង់ លិខិតស្នាម និងព័ត៌មានផ្សេងៗស្តីពីអភិបាលកិច្ចសាជីវកម្មរបស់ក្រុមហ៊ុនបោះផ្សាយលក់មូលបត្រជាសាធារណៈ
- ត្រួតពិនិត្យការអនុវត្តលក្ខខណ្ឌតម្រូវនានា ទាក់ទងនឹងអភិបាលកិច្ចសាជីវកម្មរបស់ក្រុមហ៊ុនបោះផ្សាយលក់មូលបត្រជាសាធារណៈ
- តាមដាន និងជំរុញការអនុវត្តគោលនយោបាយយុទ្ធសាស្ត្រអភិវឌ្ឍន៍អភិបាលកិច្ចសាជីវកម្មរបស់ក្រុមហ៊ុនបោះផ្សាយលក់មូលបត្រជាសាធារណៈ
- តាមដានការវិវត្តនៃអភិបាលកិច្ចសាជីវកម្មដោយគិតទាំងបរិការណ៍ជាតិ និងអន្តរជាតិ
- រៀបចំវាយតម្លៃជាប្រចាំ កំរិតអភិបាលកិច្ចសាជីវកម្មនៃក្រុមហ៊ុនបោះផ្សាយលក់មូលបត្រជាសាធារណៈ
- សហការផ្សព្វផ្សាយ និងបណ្តុះបណ្តាលអភិបាលកិច្ចសាជីវកម្មដល់ក្រុមហ៊ុនដែលមានសក្តានុពលក្នុងការបោះផ្សាយលក់មូលបត្រជាសាធារណៈ និងសាធារណជនរួមទាំងសហគ្រាសធុនតូច និងមធ្យម
- រៀបចំករណីសង្ស័យអំពីការប្រព្រឹត្តល្មើសនឹងច្បាប់ និងបទប្បញ្ញត្តិពាក់ព័ន្ធនឹងអភិបាលកិច្ចសាជីវកម្មរបស់ក្រុមហ៊ុនបោះផ្សាយលក់មូលបត្រជាសាធារណៈ ដើម្បីបញ្ជូនទៅនាយកដ្ឋានកិច្ចការគតិយុត្ត
- រៀបចំផែនការសកម្មភាពសម្រាប់អនុវត្តការងាររបស់ការិយាល័យ
- រៀបចំរបាយការណ៍ជាប្រចាំពាក់ព័ន្ធនឹងការអនុវត្តការងាររបស់ការិយាល័យ
- អនុវត្តការងារផ្សេងៗទៀតតាមការប្រគល់ជូនរបស់ប្រធាននាយកដ្ឋាន។

ប្រការ ៦.-

ការិយាល័យត្រួតពិនិត្យកិច្ចការគណនេយ្យ មានតួនាទី និងភារកិច្ច ដូចខាងក្រោម ៖

- ត្រួតពិនិត្យការអនុវត្តតាមស្តង់ដាររបាយការណ៍ហិរញ្ញវត្ថុកម្ពុជា សម្រាប់ក្រុមហ៊ុនបោះផ្សាយលក់មូលបត្រជាសាធារណៈ
- ពិនិត្យ និងផ្តល់យោបល់ពាក់ព័ន្ធនឹងកិច្ចការគណនេយ្យរបស់ក្រុមហ៊ុនស្នើសុំបោះផ្សាយលក់មូលបត្រជាសាធារណៈ

- រៀបចំបទប្បញ្ញត្តិកំណត់ពីគុណវុឌ្ឍិ ដើម្បីអនុញ្ញាតឱ្យក្រុមហ៊ុនគណនេយ្យ ជំនាញ មេធាវី និងបុគ្គលប្រកបវិជ្ជាជីវៈជំនាញផ្សេងទៀតដែលជាប់ពាក់ព័ន្ធ ចូលរួមក្នុងដំណើរការបោះផ្សាយលក់មូលបត្រជាសាធារណៈ
- ពិនិត្យ និងផ្តល់យោបល់លើគុណវុឌ្ឍិ ដើម្បីអនុញ្ញាតឱ្យក្រុមហ៊ុនគណនេយ្យ ជំនាញ មេធាវី និងបុគ្គលប្រកបវិជ្ជាជីវៈជំនាញផ្សេងទៀតដែលជាប់ពាក់ព័ន្ធ ចូលរួមក្នុងដំណើរការបោះផ្សាយលក់មូលបត្រជាសាធារណៈ
- រៀបចំសេចក្តីណែនាំ ទម្រង់ លិខិតស្នាម និងព័ត៌មានផ្សេងៗ ស្តីពីការរៀបចំបញ្ជិកាគណនេយ្យ របាយការណ៍ហិរញ្ញវត្ថុ និងឯកសារគណនេយ្យផ្សេងៗទៀត របស់ក្រុមហ៊ុនបោះផ្សាយលក់មូលបត្រជាសាធារណៈ
- រៀបចំនីតិវិធី និងគោលការណ៍ណែនាំក្នុងការចុះធ្វើការត្រួតពិនិត្យក្រុមហ៊ុនបោះផ្សាយលក់មូលបត្រជាសាធារណៈ រួមទាំងបញ្ជិកាគណនេយ្យ
- ត្រួតពិនិត្យរបាយការណ៍ហិរញ្ញវត្ថុ និង/ឬ របាយការណ៍ធុរកិច្ចរបស់ក្រុមហ៊ុនបោះផ្សាយលក់មូលបត្រជាសាធារណៈ
- ចុះត្រួតពិនិត្យដល់ទីកន្លែងក្រុមហ៊ុនបោះផ្សាយលក់មូលបត្រជាសាធារណៈពាក់ព័ន្ធនឹងបញ្ជិកាគណនេយ្យ របាយការណ៍ហិរញ្ញវត្ថុ និងឯកសារគណនេយ្យផ្សេងៗទៀត
- ធ្វើទំនាក់ទំនងជាមួយក្រុមប្រឹក្សាជាតិគណនេយ្យ ដើម្បីតាមដានការវិវត្ត និងអភិវឌ្ឍន៍ស្តង់ដាររបាយការណ៍ហិរញ្ញវត្ថុកម្ពុជា សម្រាប់ក្រុមហ៊ុនបោះផ្សាយលក់មូលបត្រជាសាធារណៈ ដោយគិតទាំងបរិការណ៍ជាតិ និងអន្តរជាតិ
- រៀបចំករណីសង្ស័យអំពីការប្រព្រឹត្តល្មើសនឹងច្បាប់ និងបទប្បញ្ញត្តិផ្សេងៗពាក់ព័ន្ធនឹងកិច្ចការគណនេយ្យរបស់ក្រុមហ៊ុនបោះផ្សាយលក់មូលបត្រជាសាធារណៈ ដើម្បីបញ្ជូនទៅនាយកដ្ឋានកិច្ចការគតិយុត្ត
- រៀបចំផែនការសកម្មភាពការងារសម្រាប់ការិយាល័យ ដើម្បីជំរុញការអនុវត្តស្តង់ដាររបាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុនបោះផ្សាយលក់មូលបត្រជាសាធារណៈ
- សហការរៀបចំការបណ្តុះបណ្តាលពាក់ព័ន្ធនឹងកិច្ចការគណនេយ្យ ជូនដល់ក្រុមហ៊ុនដែលមានសក្តានុពលក្នុងការបោះផ្សាយលក់មូលបត្រជាសាធារណៈ និងសាធារណជន រួមទាំងសហគ្រាសធុនតូច និងមធ្យម
- រៀបចំរបាយការណ៍ជាប្រចាំពាក់ព័ន្ធនឹងការអនុវត្តការងាររបស់ការិយាល័យ
- អនុវត្តការងារផ្សេងៗទៀតតាមការប្រគល់ជូនរបស់ប្រធាននាយកដ្ឋាន។

ប្រការ ៧.-

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយពីប្រកាសនេះ ត្រូវចាត់ទុកជានិរាករណ៍។

ប្រការ ៨.-

អគ្គនាយក អគ្គនាយករងនៃគណៈកម្មការមូលបត្រកម្ពុជា ប្រធាននាយកដ្ឋានគ្រប់គ្រងការបោះផ្សាយលក់មូលបត្រ ប្រធាននាយកដ្ឋាន និងអង្គភាពពាក់ព័ន្ធចំណុះឱ្យគណៈកម្មការមូលបត្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តតាមប្រកាសនេះ ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី ០១ ខែ ធ្នូ ឆ្នាំ២០០៩

គាត ឈន់

ចម្លងជូន :

- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- ធនាគារជាតិនៃកម្ពុជា
- ក្រសួងពាណិជ្ជកម្ម
- ក្រសួងយុត្តិធម៌
- សមាជិក **គ.ម.ក.**

  "ដើម្បីជូនជ្រាប"
- ដូចប្រការ ៨

  "ដើម្បីអនុវត្ត"
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ឧបសម្ព័ន្ធ ប្រកាសលេខ ០១២ គមក.ប្រ.ក

ចុះថ្ងៃទី ០១ ខែ ធ្នូ ឆ្នាំ ២០០៩

អង្គការលេខរបស់នាយកដ្ឋានគ្រប់គ្រងការបោះផ្សាយលក់មូលបត្រ

នៃគណៈកម្មការមូលបត្រកម្ពុជា



ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

SECURITIES AND EXCHANGE COMMISSION OF CAMBODIA

គណៈកម្មការមូលបត្រកម្ពុជា

លេខ: ...០១៣... គ ម ក.ប្រ.ក

លិខិតចូល

ថ្ងៃទី...១៣...ខែមីនា...ឆ្នាំ2010

ប្រកាស

ស្តីពី

ការរៀបចំ និងការប្រព្រឹត្តទៅនៃនាយកដ្ឋានត្រួតពិនិត្យអន្តរការីមូលបត្រ នៃគណៈកម្មការមូលបត្រកម្ពុជា

* * * * *

ឧបនាយករដ្ឋមន្ត្រី

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

និងជាប្រធានគណៈកម្មការមូលបត្រកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៧/០០១ ចុះថ្ងៃទី១០ ខែមករា ឆ្នាំ ២០០៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីមូលបត្ររដ្ឋ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១០០៧/០២៨ ចុះថ្ងៃទី១៩ ខែតុលា ឆ្នាំ ២០០៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន
- បានឃើញអនុក្រឹត្យលេខ ៩៧ អនក្រ/បក ចុះថ្ងៃទី២៣ ខែកក្កដា ឆ្នាំ២០០៨ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មការមូលបត្រកម្ពុជា
- បានឃើញអនុក្រឹត្យលេខ ៥៤ អនក្រ/បក ចុះថ្ងៃទី០៨ ខែមេសា ឆ្នាំ២០០៩ ស្តីពីការអនុវត្តច្បាប់ស្តីពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន
- យោងតាមការអនុម័តនៃសម័យប្រជុំពេញអង្គរបស់គណៈកម្មការមូលបត្រកម្ពុជា នាថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០០៩

អាសយដ្ឋានបណ្តោះអាសន្ន អគារ ៩៩ ផ្លូវ ៥៩៨ សង្កាត់ភ្នំពេញថ្មី ខណ្ឌសែនសុខ រាជធានីភ្នំពេញ-កម្ពុជា
Temporary Address: # 99, Street 598, Sangkat Phnom Penh Thmey, Khan Sen Sok, Phnom Penh, Cambodia. www.secc.gov.kh
ទូរស័ព្ទ : ៨៥៥-២៣-៨៨៥-៦១១ ទូរសារ : ៨៥៥-២៣-៨៨៥-៦២២
Phone : 855-23-885-611 Fax : 855-23-885-622
E-mail : info@secc.gov.kh

ស ម្រេ ច

ប្រការ ១.-

ប្រកាសនេះមានគោលដៅកំណត់ពីការរៀបចំ និងការប្រព្រឹត្តទៅរបស់នាយកដ្ឋានត្រួតពិនិត្យអន្តរការីមូលបត្រនៃគណៈកម្មការមូលបត្រកម្ពុជា ដែលមានមានតួនាទី និងភារកិច្ចដូចមានចែងក្នុងអនុក្រឹត្យលេខ ៩៧ អនក្រ/បក ចុះថ្ងៃទី ២៣ ខែកក្កដា ឆ្នាំ២០០៨ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មការមូលបត្រកម្ពុជា (**គ.ម.ក.**)។

ប្រការ ២.-

នាយកដ្ឋានត្រួតពិនិត្យអន្តរការីមូលបត្រដឹកនាំដោយប្រធាន ០១ (មួយ) រូប និងមានអនុប្រធានមួយចំនួនជាជំនួយការតាមការចាំបាច់។

ប្រការ ៣.-

នាយកដ្ឋានត្រួតពិនិត្យអន្តរការីមូលបត្រមានការិយាល័យចំណុះចំនួន ០៣ (បី) ដូចខាងក្រោម ÷

- ការិយាល័យសម្របសម្រួល និងអាជ្ញាបណ្ណ
- ការិយាល័យត្រួតពិនិត្យលើឯកសារ
- ការិយាល័យត្រួតពិនិត្យដល់ទីកន្លែង

ការិយាល័យនីមួយៗ ត្រូវដឹកនាំដោយប្រធាន ០១ (មួយ) រូប និងមានអនុប្រធានមួយចំនួនជាជំនួយការ តាមការចាំបាច់។

អង្គការលេខរបស់នាយកដ្ឋានត្រួតពិនិត្យអន្តរការីមូលបត្រជាឧបសម្ព័ន្ធនៃប្រកាសនេះ។

ប្រការ ៤.-

ការិយាល័យសម្របសម្រួល និងអាជ្ញាបណ្ណមានតួនាទី និងភារកិច្ច ដូចខាងក្រោម ÷

- រៀបចំបទប្បញ្ញត្តិ លក្ខខណ្ឌតម្រូវនានា និងនីតិវិធីសម្រាប់ផ្តល់អាជ្ញាបណ្ណដល់ក្រុមហ៊ុនមូលបត្រ ភ្នាក់ងារក្រុមហ៊ុនមូលបត្រ បុគ្គលគ្រប់គ្រងមូលនិធិ ទីប្រឹក្សាវិនិយោគ និងអ្នកចូលរួមដទៃទៀតក្នុងទីផ្សារ
- រៀបចំសេចក្តីណែនាំ ទម្រង់លិខិតស្នាម និងព័ត៌មានផ្សេងៗពាក់ព័ន្ធនឹងការផ្តល់អាជ្ញាបណ្ណដល់ក្រុមហ៊ុនមូលបត្រ ភ្នាក់ងារក្រុមហ៊ុនមូលបត្រ បុគ្គលគ្រប់គ្រងមូលនិធិ ទីប្រឹក្សាវិនិយោគ និងអ្នកចូលរួមដទៃទៀតក្នុងទីផ្សារ

- ពិនិត្យ និងផ្តល់យោបល់លើសំណើសុំអាជ្ញាបណ្ណ ដើម្បីធ្វើជាក្រុមហ៊ុនមូលបត្រ ភ្នាក់ងារក្រុមហ៊ុនមូលបត្រ បុគ្គលគ្រប់គ្រងមូលនិធិ ទីប្រឹក្សាវិនិយោគ និងអ្នកចូលរួមដទៃទៀតក្នុងទីផ្សារ
- ត្រួតពិនិត្យ និងវាយតម្លៃពីភាពសមស្របនៃប្រព័ន្ធបច្ចេកវិទ្យា សម្រាប់ការផ្ញើ-ផ្ញើ និងដំណើរការប្រតិបត្តិការ ធនធានមនុស្ស និងលក្ខខណ្ឌផ្សេងទៀតសម្រាប់ដំណើរការអាជីវកម្មរបស់បុគ្គលស្នើសុំ ដើម្បីធ្វើជាក្រុមហ៊ុនមូលបត្រ ភ្នាក់ងារក្រុមហ៊ុនមូលបត្រ បុគ្គលគ្រប់គ្រងមូលនិធិ ទីប្រឹក្សាវិនិយោគ និងអ្នកចូលរួមដទៃទៀតក្នុងទីផ្សារ
- តាមដានការអនុវត្តតាមលក្ខខណ្ឌនៃអាជ្ញាបណ្ណរបស់ក្រុមហ៊ុនមូលបត្រ ភ្នាក់-ងារក្រុមហ៊ុនមូលបត្រ បុគ្គលគ្រប់គ្រងមូលនិធិ ទីប្រឹក្សាវិនិយោគ និងអ្នកចូលរួមដទៃទៀតក្នុងទីផ្សារ
- ពិនិត្យ និងផ្តល់យោបល់លើសំណើសុំការអនុញ្ញាត ដើម្បីក្លាយជាស្វ័យនិយតករចំពោះក្រុមហ៊ុនមូលបត្រ ឬទីប្រឹក្សាវិនិយោគ ឬបុគ្គលពាក់ព័ន្ធនឹងអាជីវកម្មគម្រោងវិនិយោគរួម
- ពិនិត្យ និងតាមដានការអនុវត្តតាមលក្ខខណ្ឌរបស់ស្ថាប័នស្វ័យនិយតករដែលទទួលបានការអនុញ្ញាត
- សិក្សា និងតាមដានការវិវត្តបទប្បញ្ញត្តិ លក្ខខណ្ឌតម្រូវនានា និងនីតិវិធីសម្រាប់ផ្តល់អាជ្ញាបណ្ណដល់ក្រុមហ៊ុនមូលបត្រ ភ្នាក់ងារក្រុមហ៊ុនមូលបត្រ បុគ្គលគ្រប់គ្រងមូលនិធិ ទីប្រឹក្សាវិនិយោគ និងអ្នកចូលរួមដទៃទៀតក្នុងទីផ្សារ ដោយគិតរួមទាំងបរិការណ៍ជាតិ និងអន្តរជាតិ
- សិក្សាស្រាវជ្រាវ និងរៀបចំយុទ្ធសាស្ត្រក្នុងការគ្រប់គ្រង និងកំណត់អាជ្ញាបណ្ណស្របតាមស្ថានភាព និងការវិវត្តរបស់ទីផ្សារ
- រៀបចំរបាយការណ៍ជាប្រចាំស្តីពីការគ្រប់គ្រង និងដំណើរការរបស់ការិយាល័យ
- រៀបចំចាត់ចែង និងសម្របសម្រួលការងាររដ្ឋបាលរបស់នាយកដ្ឋាន
- អនុវត្តការងារផ្សេងៗទៀតតាមការប្រគល់ជូនរបស់ប្រធាននាយកដ្ឋាន។

ប្រការ ៥.-

ការិយាល័យត្រួតពិនិត្យលើឯកសារ មានតួនាទី និងភារកិច្ច ដូចខាងក្រោម ៖

- រៀបចំបទប្បញ្ញត្តិ លក្ខខណ្ឌតម្រូវនានា និងនីតិវិធីសម្រាប់ត្រួតពិនិត្យ និងតាមដានទូវរបាយការណ៍ប្រតិបត្តិការរបស់ក្រុមហ៊ុនមូលបត្រ ភ្នាក់ងារក្រុមហ៊ុនមូលបត្រ បុគ្គលគ្រប់គ្រងមូលនិធិ ទីប្រឹក្សាវិនិយោគ និងអ្នកចូលរួមដទៃទៀតក្នុងទីផ្សារ
- ចូលរួមរៀបចំសេចក្តីណែនាំ ទម្រង់លិខិតស្នាម និងព័ត៌មានផ្សេងៗដែលពាក់ព័ន្ធនឹងដំណើរការត្រួតពិនិត្យលើឯកសាររបស់ក្រុមហ៊ុនមូលបត្រ ភ្នាក់ងារក្រុមហ៊ុនមូលបត្រ បុគ្គលគ្រប់គ្រងមូលនិធិ ទីប្រឹក្សាវិនិយោគ និងអ្នកចូលរួមដទៃទៀតក្នុងទីផ្សារ
- ត្រួតពិនិត្យ តាមដានជាប្រចាំទូវរបាយការណ៍ហិរញ្ញវត្ថុ ដើម្បីវិភាគលើកម្រិតសាធនភាព អនុបាតហានិភ័យ និងមូលធនសុទ្ធ និងរបាយការណ៍គណនេយ្យផ្សេងទៀតរបស់ក្រុមហ៊ុនមូលបត្រ ភ្នាក់ងារក្រុមហ៊ុនមូលបត្រ បុគ្គលគ្រប់គ្រងមូលនិធិ ទីប្រឹក្សាវិនិយោគ និងអ្នកចូលរួមដទៃទៀតក្នុងទីផ្សារ
- ធ្វើរបាយការណ៍ផ្តល់យោបល់ ដើម្បីដាក់កំហិត ព្យួរ ឬដកហូតអាជ្ញាបណ្ណពីបុគ្គលកាន់អាជ្ញាបណ្ណ ក្នុងក្របខណ្ឌត្រួតពិនិត្យលើឯកសារ
- បញ្ជូនករណីមិនប្រក្រតីដែលពាក់ព័ន្ធនឹងរបាយការណ៍ហិរញ្ញវត្ថុ ឬរបាយការណ៍ផ្សេងទៀតរបស់ក្រុមហ៊ុនមូលបត្រ ភ្នាក់ងារក្រុមហ៊ុនមូលបត្រ បុគ្គលគ្រប់គ្រងមូលនិធិ ទីប្រឹក្សាវិនិយោគ និងអ្នកចូលរួមដទៃទៀតក្នុងទីផ្សារ ទៅការិយាល័យត្រួតពិនិត្យដល់ទីកន្លែង
- សិក្សា និងតាមដានការវិវត្តបទប្បញ្ញត្តិ លក្ខខណ្ឌតម្រូវនានា ដែលពាក់ព័ន្ធនឹងការត្រួតពិនិត្យលើឯកសាររបស់ក្រុមហ៊ុនមូលបត្រ ភ្នាក់ងារក្រុមហ៊ុនមូល-បត្រ បុគ្គលគ្រប់គ្រងមូលនិធិ ទីប្រឹក្សាវិនិយោគ និងអ្នកចូលរួមដទៃទៀតក្នុងទីផ្សារ ដោយគិតរួមទាំងបរិការណ៍ជាតិ និងអន្តរជាតិ
- សិក្សាស្រាវជ្រាវ និងលើកយោបល់ពាក់ព័ន្ធនឹងស្តង់ដាររបាយការណ៍ហិរញ្ញវត្ថុ និងរបាយការណ៍ផ្សេងទៀត សម្រាប់ក្រុមហ៊ុនមូលបត្រ ភ្នាក់ងារក្រុមហ៊ុនមូលបត្រ បុគ្គលគ្រប់គ្រងមូលនិធិ ទីប្រឹក្សាវិនិយោគ និងអ្នកចូលរួមដទៃទៀតក្នុងទីផ្សារ
- រៀបចំធ្វើរបាយការណ៍ និងសរុបទិន្នន័យដែលទទួលពីការត្រួតពិនិត្យលើឯកសារ ដោយធ្វើការវិភាគ និងរាយការណ៍ជូនថ្នាក់ដឹកនាំ
- រៀបចំរបាយការណ៍ជាប្រចាំស្តីពីការគ្រប់គ្រង និងដំណើរការរបស់ការិយាល័យ

- អនុវត្តការងារផ្សេងៗទៀតតាមការប្រគល់ជូនរបស់ប្រធាននាយកដ្ឋាន។

ប្រការ ៦.-

ការិយាល័យត្រួតពិនិត្យដល់ទីកន្លែង មានតួនាទី និងភារកិច្ច ដូចខាងក្រោម ÷

- រៀបចំបទប្បញ្ញត្តិ និងនីតិវិធីសម្រាប់ត្រួតពិនិត្យ និងតាមដានដល់ទីកន្លែងនូវប្រតិបត្តិការធុរកិច្ចរបស់ក្រុមហ៊ុនមូលបត្រ ភ្នាក់ងារក្រុមហ៊ុនមូលបត្រ បុគ្គលគ្រប់គ្រងមូលនិធិ ទីប្រឹក្សាវិនិយោគ និងអ្នកចូលរួមដទៃទៀតក្នុងទីផ្សារ
- រៀបចំផែនការត្រួតពិនិត្យដល់ទីកន្លែង ដើម្បីការពារផលប្រយោជន៍វិនិយោគិនមូលបត្រ និងប្រសិទ្ធភាពប្រតិបត្តិការរបស់ក្រុមហ៊ុនមូលបត្រ ភ្នាក់ងារក្រុមហ៊ុនមូលបត្រ បុគ្គលគ្រប់គ្រងមូលនិធិ ទីប្រឹក្សាវិនិយោគ និងអ្នកចូលរួមដទៃទៀតក្នុងទីផ្សារ
- ត្រួតពិនិត្យ និងតាមដានដល់ទីកន្លែងនូវការអនុវត្តតាមលក្ខខណ្ឌនៃអាជ្ញាបណ្ណរបស់ក្រុមហ៊ុនមូលបត្រ ភ្នាក់ងារក្រុមហ៊ុនមូលបត្រ បុគ្គលគ្រប់គ្រងមូលនិធិ ទីប្រឹក្សាវិនិយោគ និងអ្នកចូលរួមដទៃទៀតក្នុងទីផ្សារ
- ត្រួតពិនិត្យ និងតាមដានដល់ទីកន្លែងនូវប្រតិបត្តិការរបស់ក្រុមហ៊ុនមូលបត្រ ភ្នាក់ងារក្រុមហ៊ុនមូលបត្រ បុគ្គលគ្រប់គ្រងមូលនិធិ ទីប្រឹក្សាវិនិយោគ និងអ្នកចូលរួមដទៃទៀតក្នុងទីផ្សារ
- ត្រួតពិនិត្យ និងតាមដានការអនុវត្តតាមក្រមសីលធម៌វិជ្ជាជីវៈ និងវិធាននានារបស់ក្រុមហ៊ុនមូលបត្រ ភ្នាក់ងារក្រុមហ៊ុនមូលបត្រ បុគ្គលគ្រប់គ្រងមូលនិធិ ទីប្រឹក្សាវិនិយោគ និងអ្នកចូលរួមដទៃទៀតក្នុងទីផ្សារ
- ធ្វើរបាយការណ៍ផ្តល់យោបល់ ដើម្បីដាក់កំហិត ព្យួរ ឬដកហូតអាជ្ញា-បណ្ណពីបុគ្គលកាន់អាជ្ញាបណ្ណ ក្នុងក្របខណ្ឌត្រួតពិនិត្យដល់ទីកន្លែង
- ចុះត្រួតពិនិត្យដល់ទីកន្លែង បន្ទាប់ពីទទួលករណីមិនប្រក្រតីពីការិយាល័យត្រួតពិនិត្យលើឯកសារ
- រៀបចំករណីសង្ស័យប្រព្រឹត្តល្មើសនឹងច្បាប់ និងបទប្បញ្ញត្តិ ពាក់ព័ន្ធនឹងក្រុមហ៊ុនមូលបត្រ ភ្នាក់ងារក្រុមហ៊ុនមូលបត្រ បុគ្គលគ្រប់គ្រងមូលនិធិ ទីប្រឹក្សាវិនិយោគ និងអ្នកចូលរួមដទៃទៀតក្នុងទីផ្សារ ដើម្បីបញ្ជូនទៅនាយកដ្ឋានកិច្ចការគតិយុត្ត

- សិក្សា និងតាមដានការវិវត្តបទប្បញ្ញត្តិ លក្ខខណ្ឌតម្រូវនានា និងនីតិវិធីសម្រាប់ត្រួតពិនិត្យ និងតាមដានដល់ទីកន្លែងនូវប្រតិបត្តិការរបស់ក្រុមហ៊ុនមូលបត្រ ភ្នាក់ងារក្រុមហ៊ុនមូលបត្រ បុគ្គលគ្រប់គ្រងមូលនិធិ ទីប្រឹក្សា-វិនិយោគ និងអ្នកចូលរួមដទៃទៀតក្នុងទីផ្សារ ដោយគិតរួមទាំងបរិការណ៍ជាតិ និងអន្តរជាតិ
- រៀបចំធ្វើរបាយការណ៍ និងសរុបទិន្នន័យដែលទទួលពីការត្រួតពិនិត្យដល់ទីកន្លែង ដោយធ្វើការវិភាគ និងរាយការណ៍ជូនថ្នាក់ដឹកនាំ
- រៀបចំរបាយការណ៍ជាប្រចាំស្តីពីការគ្រប់គ្រង និងដំណើរការរបស់ការិយាល័យ
- អនុវត្តការងារផ្សេងៗទៀតតាមការប្រគល់ជូនរបស់ប្រធាននាយកដ្ឋាន។

ប្រការ ៧.-

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយពីប្រកាសនេះ ត្រូវចាត់ទុកជានិរាករណ៍។

ប្រការ ៨.-

អគ្គនាយក អគ្គនាយករងនៃគណៈកម្មការមូលបត្រកម្ពុជា ប្រធាននាយកដ្ឋានត្រួតពិនិត្យអន្តរការីមូលបត្រ និងប្រធាននាយកដ្ឋាន និងអង្គភាពពាក់ព័ន្ធចំណុះឱ្យគណៈកម្មការមូលបត្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តតាមប្រកាសនេះ ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី ០១ ខែ ធ្នូ ឆ្នាំ២០០៩

គាត ឈន់

ចម្លងជូន :

- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- ធនាគារជាតិនៃកម្ពុជា
- ក្រសួងពាណិជ្ជកម្ម
- ក្រសួងយុត្តិធម៌
- សមាជិក គ.ម.ក.

  "ដើម្បីជូនជ្រាប"
- ដូចប្រការ ៨

  "ដើម្បីអនុវត្ត"
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ឧបសម្ព័ន្ធប្រកាសលេខ.០១៣ គមក.ប្រ.ក

ចុះថ្ងៃទី ០៧ ខែ ធ្នូ ឆ្នាំ ២០០៩

អង្គការលេខរបស់នាយកដ្ឋានត្រួតពិនិត្យអន្តរការីមូលបត្រ

នៃគណៈកម្មការមូលបត្រកម្ពុជា



ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងព័ត៌មាន
MINISTRY OF INFORMATION
លេខ......០៥៣......ព.ម

លិខិតចូល
ថ្ងៃទី០១....ខែ៣....ឆ្នាំ២០១០

រាជធានីភ្នំពេញ, ថ្ងៃទី...០១...ខែ...ឆ្នាំ២០១០

ប្រកាស

ស្ដីពី

ការគ្រប់គ្រងការផ្សព្វផ្សាយអាហ្វីស ផាំណូ ប័ណ្ណប្រកាស ស្លាកសញ្ញា តាមទីសាធារណៈ ដែលមានលក្ខណៈឃោសនាមហាជន និងការផ្សព្វផ្សាយដំណឹងពាណិជ្ជកម្ម

១✻៧

រដ្ឋមន្ត្រីក្រសួងព័ត៌មាន

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស.រកត ០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស.រកម ០១៩៦/១៤ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការបង្កើតក្រសួងព័ត៌មាន
- បានឃើញអនុក្រឹត្យលេខ ៧០ អនក្រ.បក ចុះថ្ងៃទី ០៩ ខែ សីហា ឆ្នាំ ១៩៩៩ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងព័ត៌មាន
- បានឃើញអនុក្រឹត្យលេខ ៧១ អនក្រ.បក ចុះថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ ២០០៧ ស្ដីពីការកែសម្រួល អគ្គនាយកដ្ឋានរដ្ឋបាល និងសោតទស្សន៍ ជាអគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ និងអគ្គនាយកដ្ឋានព័ត៌មាន និងសោតទស្សន៍របស់ក្រសួងព័ត៌មាន។
- បានឃើញលិខិតលេខ ៩៨០ ព.ម.ប្រក ចុះថ្ងៃទី ២៣ ខែ កញ្ញា ឆ្នាំ ២០០៩ ស្ដីពីការបង្កើតគណៈកម្មាធិការគ្រប់គ្រងការផ្សព្វផ្សាយអាហ្វីស ផាំណូ ប័ណ្ណប្រកាស ស្លាកសញ្ញា តាមទីសាធារណៈដែលមានលក្ខណៈឃោសនាមហាជន និងការផ្សព្វផ្សាយដំណឹងពាណិជ្ជកម្ម។

ស ម្រេ ច

ប្រការ១ : ប្រកាសនេះមានគោលបំណងគ្រប់គ្រងការផ្សព្វផ្សាយអាហ្វីស ផាំណូ ប័ណ្ណប្រកាស ស្លាកសញ្ញា តាមទីសាធារណៈដែលមានលក្ខណៈឃោសនាមហាជន និងការផ្សព្វផ្សាយដំណឹងពាណិជ្ជកម្ម នៅក្នុងព្រះរាជាណាចក្រកម្ពុជា។ រាល់ការផ្សព្វផ្សាយអាហ្វីស ផាំណូ ប័ណ្ណប្រកាស ស្លាកសញ្ញា តាមទីសាធារណៈ ដែលមានលក្ខណៈឃោសនាមហាជន និងការផ្សព្វផ្សាយដំណឹងពាណិជ្ជកម្ម ត្រូវសុំការអនុញ្ញាតពីក្រសួងព័ត៌មាន។

ប្រការ២ : អ្នកផ្សព្វផ្សាយត្រូវបំពេញសំណុំបែបបទនៅអគ្គនាយកដ្ឋានព័ត៌មាន និងសោតទស្សន៍ដូចខាងក្រោម :

១. ពាក្យសុំអនុញ្ញាតផ្សព្វផ្សាយ

២. ប្រវត្តិរូបសង្ខេបមានបិទរូបថត

៣. កិច្ចសន្យា

ក្រសួងព័ត៌មាន

ប្រការ៣ : ការអនុញ្ញាតឱ្យផ្សព្វផ្សាយ អាហ្វីស ប៉ាណូ ប័ណ្ណប្រកាស ស្លាកសញ្ញា តាមទីសាធារណៈ ដែលមានលក្ខណៈឃោសនាមហាជន និង ការផ្សព្វផ្សាយដំណឹងពាណិជ្ជកម្ម មានសុពលភាពរយៈពេលកំណត់ទៅតាមការស្នើសុំរបស់អ្នកផ្សព្វផ្សាយ រយៈពេល បីខែ ប្រាំមួយខែ និង មួយឆ្នាំ។

ប្រការ៤ : ប្រកាសនេះមានប្រសិទ្ធភាព អនុវត្តន៍ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

ប្រការ៥ : អគ្គនាយកដ្ឋានព័ត៌មាន និងសោតទស្សន៍ អគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ ខុទ្ទកាល័យ មន្ទីរព័ត៌មាន ខេត្ត-រាជធានី ត្រូវទទួលអនុវត្តតាមប្រកាសនេះឱ្យមានប្រសិទ្ធភាពខ្ពស់ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រដ្ឋមន្ត្រី

ខៀវ កាញារីទ្ធ

ចម្លងជូន :

-លោកជំទាវ ម៉ែន សំអន ឧបនាយករដ្ឋមន្ត្រី ប្រចាំការ

-ខុទ្ទកាល័យសម្តេចតេជោនាយករដ្ឋមន្ត្រី

-ខុទ្ទកាល័យឯកឧត្តម ឧបនាយករដ្ឋមន្ត្រី សុខ អាន

- ខុទ្ទកាល័យលោកជំទាវ ឧបនាយករដ្ឋមន្ត្រី ប្រចាំការ

"ដើម្បីជូនជ្រាបជាព័ត៌មាន"

-ក្រសួងមហាផ្ទៃ

-គ្រប់ក្រសួង-ស្ថាប័ន

-សាលាខេត្ត -រាជធានី

"ដើម្បីរួមសហការអនុវត្ត"

-ដូចប្រការ ៥ "ដើម្បីអនុវត្ត"

-រាជកិច្ច

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

CAMBODIA

ក្រសួងទេសចរណ៍

លេខ ០៤៩ ប.ក

រាជធានីភ្នំពេញ, ថ្ងៃទី ១៦ ខែ កុម្ភៈ ឆ្នាំ២០១០

លិខិតចូល
ថ្ងៃទី ១១ ខែមីនា ឆ្នាំ2010

ប្រកាស
ស្តីពី
ការរៀបចំ និង ការប្រព្រឹត្តទៅរបស់ នាយកដ្ឋានសវនកម្មផ្ទៃក្នុង នៃក្រសួងទេសចរណ៍

រដ្ឋមន្ត្រីក្រសួងទេសចរណ៍

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២/នស/៩៤ចុះថ្ងៃទី២០ខែកក្កដាឆ្នាំ១៩៩៤ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពី ការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញាឆ្នាំ ២០០៨ ស្តីពី ការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៥ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពី ការបង្កើតក្រសួងទេសចរណ៍
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦០៩/០០៧ចុះថ្ងៃទី១០ខែមិថុនាឆ្នាំ២០០៩ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពី ទេសចរណ៍
- បានឃើញព្រះរាជក្រមលេខ ជស/រកម/០៣០០/១០ចុះថ្ងៃទី ០៣ ខែមីនាឆ្នាំ ២០០០ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពី សវនកម្មនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញអនុក្រឹត្យលេខ៣៤ អនក្រ.បក ចុះថ្ងៃទី០៥ ខែសីហា ឆ្នាំ១៩៩៧ ស្តីពី ការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងទេសចរណ៍
- បានឃើញអនុក្រឹត្យលេខ២៦អនក្រ.បកចុះថ្ងៃទី០៣ខែឧសភាឆ្នាំ២០០០ ស្តីពី ការកែសម្រួលមុខងារ និងភារកិច្ច និងការបង្កើតក្រុមអ្នកច្បាប់ និងនាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ និងអាស៊ាននៃក្រសួងទេសចរណ៍
- បានឃើញអនុក្រឹត្យលេខ១០៧អនក្រ.បក ចុះថ្ងៃទី ២២ ខែតុលា ឆ្នាំ២០០២ ស្តីពី ការតម្លើងនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ របស់ក្រសួងទេសចរណ៍ទៅជា អគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ

- បានឃើញអនុក្រឹត្យលេខ០៩អនក្រ.បកចុះថ្ងៃទី០៦ខែមេសាឆ្នាំ២០០៤ ស្តីពី ការបង្កើតនាយកដ្ឋានស្ថិតិ និងព័ត៌មានទេសចរណ៍ នៃក្រសួងទេសចរណ៍
- បានឃើញអនុក្រឹត្យលេខ៤០អនក្រ.បកចុះថ្ងៃទី១៥ខែកុម្ភៈឆ្នាំ២០០៥ ស្តីពី ការរៀបចំ និងការប្រព្រឹត្តទៅនៃសវនកម្មផ្ទៃក្នុងនៅតាមបណ្តាស្ថាប័ន ក្រសួង និងសហគ្រាសសាធារណៈ
- បានឃើញអនុក្រឹត្យលេខ៦៧ អនក្រ.បក ចុះថ្ងៃទី ១៩ ខែកក្កដា ឆ្នាំ ២០០៦ ស្តីពី ការបង្កើតនាយកដ្ឋានសវនកម្មផ្ទៃក្នុងនៃក្រសួងទេសចរណ៍
- បានឃើញប្រកាសលេខ៤០៥ សហវ ចុះថ្ងៃទី ៣១ ខែឧសភា ឆ្នាំ ២០០៦ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ស្តីពី ការដាក់ឲ្យប្រើប្រាស់ឯកសារក្រមសីលធម៌សម្រាប់សវនករផ្ទៃក្នុង និងស្តង់ដារវិជ្ជាជីវៈសវនកម្មផ្ទៃក្នុង
- តាមសំណូមពរការងារចាំបាច់

ស ម្រេ ច

ប្រការ ១ :

ប្រកាសនេះមានគោលដៅកំណត់ ការរៀបចំ និងការប្រព្រឹត្តទៅរបស់នាយកដ្ឋានសវនកម្មផ្ទៃក្នុងនៃក្រសួងទេចរណ៍ សំដៅបង្កើនប្រសិទ្ធិភាពការងារនៅតាមនាយកដ្ឋាន អង្គភាពក្រោមឱវាទក្រសួង និងមន្ទីរទេសចរណ៍រាជធានី-ខេត្តនៃរដ្ឋបាលថ្នាក់ក្រោមជាតិ។

ប្រការ ២ :

នាយកដ្ឋានសវនកម្មផ្ទៃក្នុងក្រសួងទេសចរណ៍ត្រូវអនុវត្ត មុខងារឯករាជ្យ ដើម្បីពិនិត្យវិភាគវាយតម្លៃលើសកម្មភាពរបស់នាយកដ្ឋាន អង្គភាពក្រោមឱវាទក្រសួង និងមន្ទីរទេសចរណ៍រាជធានី-ខេត្តនៃរដ្ឋបាលថ្នាក់ក្រោមជាតិដោយផ្តល់នូវអនុសាសន៍មតិយោបល់កែលម្អសំដៅជួយឲ្យអង្គភាពទាំងនោះបំពេញភារកិច្ចប្រកបដោយប្រសិទ្ធិភាពខ្ពស់ ។

មន្ត្រីរបស់នាយកដ្ឋានសវនកម្មផ្ទៃក្នុង ត្រូវមានសិទ្ធិពេញលេញសេរីភាពគ្រប់គ្រាន់ និងគ្មានការរាំង ការហាមឃាត់លើការចូលត្រួតពិនិត្យនូវគ្រប់សកម្មភាព រាល់បញ្ជីកត់ត្រារាល់ទ្រព្យសម្បត្តិ និងបុគ្គលិករបស់អង្គភាព។

មន្ត្រីសវនកម្មផ្ទៃក្នុងត្រូវមានភាពស្ទាត់ជំនាញនៃវិជ្ជាជីវៈ សុច្ចរិត ស្មោះត្រង់ និងមិនអនុញ្ញាតឲ្យមានការផ្សព្វផ្សាយនាំយកព័ត៌មាន ស្តីពី សវនកម្មទៅខាងក្រៅ ។

នាយកដ្ឋានសវនកម្មផ្ទៃក្នុង ត្រូវបញ្ជូនរាល់របាយការណ៍ និងសេចក្តីសន្និដ្ឋានទៅថ្នាក់ដឹកនាំអង្គភាពរបស់ខ្លួន និងផ្ញើជូនអាជ្ញាធរសវនកម្មជាតិ ។

នាយកដ្ឋានសវនកម្មផ្ទៃក្នុង ត្រូវធ្វើការសម្របសម្រួលការងារជាមួយ អាជ្ញាធរសវនកម្មជាតិដើម្បីធានាទំហំការងារឲ្យបានគ្រប់គ្រាន់ កាត់បន្ថយ និងជៀសវាងការងារធ្វើសវនកម្មស្ទួនគ្នា ។

ប្រការ ៣ :

នាយកដ្ឋានសវនកម្មផ្ទៃក្នុងមានតួនាទី និងភារកិច្ចអនុវត្តឲ្យបានត្រឹមត្រូវតាមខ្លឹមសារនៃ

អនុក្រឹត្យលេខ ៤០អនក្រ.បក ចុះថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០០៥ ស្តីពី ការរៀបចំ និងការប្រព្រឹត្តទៅនៃសវនកម្មផ្ទៃក្នុងនៅតាមបណ្តាស្ថាប័ន ក្រសួង និងសហគ្រាសសាធារណៈ ។

ប្រការ ៤ :

នាយកដ្ឋានសវនកម្មផ្ទៃក្នុងដឹកនាំដោយប្រធានមួយរូប និងអនុប្រធានមួយចំនួនជាជំនួយការតាមការចាំបាច់ ។ នាយកដ្ឋានសវនកម្មផ្ទៃក្នុង អនុវត្តរាល់ការងារ និងភារកិច្ចផ្សេងៗដែលប្រធានស្ថាប័នប្រគល់ឲ្យ និងត្រូវរាយការណ៍ដោយផ្ទាល់ជូនប្រធានស្ថាប័ន ។

ប្រការ ៥ :

នាយកដ្ឋានសវនកម្មផ្ទៃក្នុងមាន ០៣ ការិយាល័យរួមមាន :

១.ការិយាល័យបូកសរុបសវនកម្ម

២.ការិយាល័យបច្ចេកទេសសវនកម្ម

៣.ការិយាល័យសវនកម្មគណនេយ្យ និងហិរញ្ញវត្ថុ

ប្រការ ៦ :

តួនាទី និងភារកិច្ចរបស់ការិយាល័យនីមួយៗមាន:

១- ការិយាល័យបូកសរុបសវនកម្មមានភារកិច្ច :

- គ្រប់គ្រងទ្រព្យសម្បត្តិ និងបញ្ជីសារពើភ័ណ្ឌរបស់នាយកដ្ឋាន ។
- គ្រប់គ្រង និងចរាចរឯកសារផ្សេងៗរបស់នាយកដ្ឋាន ។
- រៀបចំផែនការសវនកម្មប្រចាំឆ្នាំជូននាយកដ្ឋានដើម្បីដាក់ឆ្លងថ្នាក់ដឹកនាំក្រសួង ពិនិត្យសម្រេច
- រៀបចំគម្រោងចំណាយថវិកាប្រចាំឆ្នាំសម្រាប់ការអនុវត្តភារកិច្ចរបស់នាយកដ្ឋាន និងតាមដានការអនុវត្តផែនការសវនកម្មផ្ទៃក្នុងប្រចាំឆ្នាំ ។
- គ្រប់គ្រងមន្ត្រី ការស្នើរៀបចំតួនាទី ការបណ្តុះបណ្តាលមន្ត្រីរាជការ និងការងារសង្គមកិច្ចនៅក្នុងនាយកដ្ឋាន ។
- ធ្វើរបាយការណ៍ និងសេចក្តីសន្និដ្ឋាននៃសវនកម្ម រួចផ្ញើជូនដល់ផ្នែកនីមួយៗដែលទទួលបន្ទុកកែលម្អតាមអនុសាសន៍ ។
- ផ្តល់លទ្ធភាពសមស្រប គ្រប់គ្រាន់ ក្នុងការតាមដានសកម្មភាពកែលម្អលើអនុសាសន៍ ។
- តាក់តែងលិខិតស្នាម ថែរក្សាសំណុំឯកសារពាក់ព័ន្ធ នឹងការងារជំនាញដោយសម្ងាត់ ។
- អនុវត្តរាល់ការងារ និងភារកិច្ចផ្សេងៗទៀតដែលនាយកដ្ឋានប្រគល់ឲ្យ ។

២- ការិយាល័យបច្ចេកទេសសវនកម្មមានភារកិច្ច :

- ពិនិត្យឡើងវិញលើប្រព័ន្ធដែលបានបង្កើត ដើម្បីធានាបានតាមគោលនយោបាយ ផែនការ នីតិវិធីច្បាប់ បទបញ្ជាទាំងឡាយដែលមានឥទ្ធិពលសំខាន់ក្នុងកិច្ចប្រតិបត្តិការ និងរបាយការណ៍។ ក្នុងករណីអង្គភាពរងសវនកម្មអនុវត្តពុំបានសមស្រប ចាំបាច់សំណូមពរឲ្យមានការកែលម្អ និងផ្លាស់ប្តូរ ។

- ពិនិត្យឡើងវិញមុខងារសកម្មភាពប្រតិបត្តិការ និងកម្មវិធីរបស់អង្គភាពក្នុងការិយបរិច្ឆេទសមស្របរបស់ថ្នាក់ដឹកនាំក្នុងការអនុវត្តឲ្យបានត្រឹមត្រូវលើការបង្កើតផែនការ ការតម្រង់ទិស ការគ្រប់គ្រងឲ្យបានត្រឹមត្រូវតាមគោលការណ៍របស់អង្គភាព ។
- ពិនិត្យឡើងវិញនូវភាពដែលអាចជឿទុកចិត្តបាន ភាពទាន់ពេលវេលា និងភាពច្បាស់លាស់នៃព័ត៌មានហិរញ្ញវត្ថុ និងកិច្ចប្រតិបត្តិការព្រមទាំងវិធីសាស្ត្រដែលបានប្រើប្រាស់ដើម្បីកំណត់អត្តសញ្ញាណវាស់វែងចំណាត់ថ្នាក់ និងរាយការណ៍អំពីព័ត៌មានទាំងនោះ ។
- ពិនិត្យឡើងវិញលើកិច្ចប្រតិបត្តិការ កម្មវិធី និងគម្រោងចំណាយមូលធន លើលទ្ធផលការងារវិជ្ជមាន ឬអវិជ្ជមានតាមគោលបំណង គោលដៅដែលបានដាក់ចេញ និងតាមផែនការដែលបានកំណត់ ។
- លើកយោបល់ជូននាយកដ្ឋានលើការងារសវនកម្មដើម្បីធានាឲ្យការងារធ្វើសវនកម្មប្រព្រឹត្តទៅបានល្អប្រសើរ ។
- ជំរុញការអភិវឌ្ឍន៍ជំនាញសវនកម្មតាមរយៈការស្រាវជ្រាវ ការផ្លាស់ប្តូរបទពិសោធន៍ ការផ្សព្វផ្សាយ ការបណ្តុះបណ្តាលក្នុង និងក្រៅប្រទេស និងធ្វើការទាក់ទាញជំនួយបច្ចេកទេសដែលទាក់ទងលើវិស័យសវនកម្ម ។
- ធ្វើសវនកម្មលើប្រព័ន្ធកំព្យូទ័រតាមការិយបរិច្ឆេទ និងធ្វើការវាយតម្លៃលើប្រព័ន្ធដំណើរការ ទិន្នន័យសំខាន់ៗ ។
- ចូលរួមបង្កើតផែនការ ការអភិវឌ្ឍន៍ ការអនុវត្ត និងកិច្ចប្រតិបត្តិការលើប្រព័ន្ធកំព្យូទ័រសំខាន់ៗ
- ពិនិត្យឡើងវិញលើការអនុវត្ត តាមគោលការណ៍ណែនាំ និងការគ្រប់គ្រងរបស់រាជរដ្ឋាភិបាលស្តីពី ឥរិយាបថ និងក្រមសីលធម៌ចំពោះមន្ត្រីរាជការ ។
- តាក់តែងលិខិតស្នាម ថែរក្សាសំណុំឯកសារដែលពាក់ព័ន្ធនឹងការងារជំនាញដោយសម្ងាត់ ។
- អនុវត្តរាល់ការងារ និងភារកិច្ចផ្សេងៗទៀតដែលនាយកដ្ឋានប្រគល់ឲ្យ ។

៣- ការិយាល័យសវនកម្មគណនេយ្យ និងហិរញ្ញវត្ថុ មានភារកិច្ច :

- ធ្វើសវនកម្មលើការទូទាត់ និងការអនុវត្តរបបចំណូល ចំណាយថវិកាជាតិ ។
- ធ្វើសវនកម្មលើការអនុវត្តរបបគណនេយ្យ និងហិរញ្ញវត្ថុ ប្រាក់សោធ និងបេឡា ។
- ធ្វើសវនកម្មលើការងារគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ ការប្រើប្រាស់សម្ភារៈ និងថវិកា ។
- ធ្វើសវនកម្មលើការងារលទ្ធកម្មសាធារណៈនានា ដែលទាក់ទងដល់កិច្ចប្រតិបត្តិការ របស់ក្រសួងទេសចរណ៍ ។
- កំណត់នូវភាពសមស្រប គ្រប់គ្រាន់ និងការផ្តល់លទ្ធផលល្អលើប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុង ផ្នែកគណនេយ្យ រដ្ឋបាល និងកិច្ចប្រតិបត្តិការរបស់អង្គភាព ។
- ពិនិត្យឡើងវិញលើ ការគ្រប់គ្រងថែទាំការពារ និងផ្ទៀងផ្ទាត់ទ្រព្យសម្បត្តិរដ្ឋដែលមានឲ្យបានត្រឹមត្រូវ ។
- វាយតម្លៃលើភាពសន្សំសំចៃ និងប្រសិទ្ធិភាពលើការប្រើប្រាស់ធនធាន និងការកំណត់ការកែលម្អលើការអនុវត្តកិច្ចប្រតិបត្តិការ និងផ្តល់អនុសាសន៍ ។

- ពិនិត្យឡើងវិញលើនីតិវិធី និងការអនុវត្តដើម្បីធានាថា វិធានការដែលបានដាក់ចេញក្នុងគោលបំណងការពារការកេងបន្លំ ប្រសិនបើមានការកេងបន្លំកើតឡើងប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុងអាចរកឃើញបានទាន់ពេលវេលា ។
- វាយតម្លៃលើផែនការ ឬសកម្មភាពកែលម្អរលើចំណុចរកឃើញរបស់សវនករផ្ទៃក្នុង ។ ប្រសិនបើសកម្មភាពកែលម្អរនេះ មិនមានលក្ខណៈសមស្របទេនោះត្រូវលើកយកមកពិភាក្សាបន្តដើម្បីឲ្យសម្រេចបានតាមសំណូមពរដែលអាចទទួលយកបាន ។
- តាក់តែងលិខិតស្នាម ថែរក្សាសំណុំឯកសារដែលពាក់ព័ន្ធនឹងការងារជំនាញដោយសម្ងាត់ ។
- អនុវត្តរាល់ការងារ និងភារកិច្ចផ្សេងៗទៀតដែលនាយកដ្ឋានប្រគល់ឲ្យ ។

ប្រការ ៧ :

ការិយាល័យនីមួយៗមានប្រធានមួយរូប និងអនុប្រធានមួយចំនួនជាជំនួយការតាមការចាំបាច់ ។

ប្រការ ៨ :

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងខ្លឹមសារនៃប្រកាសនេះត្រូវចាត់ទុកជានិរាករណ៍។

ប្រការ ៩ :

អគ្គនាយករដ្ឋបាល និងហិរញ្ញវត្ថុ អគ្គនាយកទេសចរណ៍ នាយខុទ្ទកាល័យ ប្រធានក្រុមអ្នកច្បាប់ អធិការ ប្រធានគ្រប់នាយកដ្ឋាន អង្គភាពក្រោមឱវាទក្រសួងទេសចរណ៍ និងប្រធានមន្ទីរទេសចរណ៍រាជធានី-ខេត្តនៃរដ្ឋបាលថ្នាក់ក្រោមជាតិ មានភារកិច្ចអនុវត្តក្នុងក្របខ័ណ្ឌសមត្ថកិច្ចរៀងៗខ្លួនតាមប្រកាសនេះ ។

ប្រការ ១០ :

ប្រកាសនេះមានប្រសិទ្ធិភាពអនុវត្តចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

ថោង ខុន

ចម្លងជូន :

- ទីស្តីការគណៈរដ្ឋមន្ត្រី
- អាជ្ញាធរសវនកម្មជាតិ
- ក្រសួងមហាផ្ទៃ
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា ព្រឹទ្ធសភា និងអធិការកិច្ច
- រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ
- សាលារាជធានី-ខេត្ត " ដើម្បីជូនជ្រាប "
- ដូចប្រការ ៩ ដើម្បីអនុវត្ត
- ឯកសារ- កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ទីស្តីការក្រសួងយុត្តិធម៌

លេខ: ៣៨...ក.យ.ប្រ.ក/១០

លិខិតចូល
ថ្ងៃទី..១១...ខែ..មីនា..ឆ្នាំ២០១០

ប្រកាស
ស្តីពី
ការបង្កើតមណ្ឌលសេវាកម្មយុត្តិធម៌ក្រុង ខណ្ឌ ចំនួន ១០

រដ្ឋមន្ត្រីក្រសួងយុត្តិធម៌

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/០១៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៤ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងយុត្តិធម៌
- បានឃើញអនុក្រឹត្យលេខ ៤៧ អនក្រ.បក ចុះថ្ងៃទី ១១ ខែ ឧសភា ឆ្នាំ ២០០៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងយុត្តិធម៌
- យោងយុទ្ធសាស្ត្រនៃកំណែទម្រង់ច្បាប់ និងប្រព័ន្ធតុលាការរបស់រាជរដ្ឋាភិបាល ដែលបានអនុម័ត កាលពីថ្ងៃទី ២០ ខែ មិថុនា ឆ្នាំ ២០០៣
- យោងតាមកម្មវិធីសកម្មភាពដើម្បីអនុវត្តយុទ្ធសាស្ត្រនៃកំណែទម្រង់ច្បាប់ និងប្រព័ន្ធតុលាការរបស់រាជរដ្ឋាភិបាល ដែលបានអនុម័ត កាលពីថ្ងៃទី ២៩ ខែ មេសា ឆ្នាំ ២០០៥
- យោងតាមអនុកម្មវិធី ស្តីពីការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ របស់ក្រសួងយុត្តិធម៌ សម្រាប់ឆ្នាំ២០១០
- យោងតាមការចាំបាច់

សម្រេច

ប្រការ ១: ត្រូវបានបង្កើតមណ្ឌលសេវាកម្មយុត្តិធម៌ថ្នាក់ក្រុង ខណ្ឌ ចំនួន១០ សម្រាប់ក្រុងកំពតនៃខេត្តកំពត ក្រុងព្រៃវែង នៃខេត្តព្រៃវែង ខណ្ឌឫស្សីកែវ ខណ្ឌមានជ័យ ខណ្ឌសែនសុខ ខណ្ឌដង្កោ ខណ្ឌដូនពេញ ខណ្ឌ៧មករា ខណ្ឌទួលគោក និងខណ្ឌចំការមន នៃរាជធានីភ្នំពេញ។

ប្រការ ២: មណ្ឌលសេវាកម្មយុត្តិធម៌ក្រុង ខណ្ឌនីមួយៗ ត្រូវបានដឹកនាំដោយប្រធានមួយរូប អនុប្រធានមួយរូប និងមានជំនួយការមួយចំនួនតាមការចាំបាច់ ។

ប្រការ ៣: មណ្ឌលសេវាកម្មយុត្តិធម៌ មានបេសកកម្មដូចខាងក្រោម :

- ធ្វើការប៉ាន់ប្រមាណអំពីតម្រូវការព័ត៌មានផ្នែកច្បាប់នៅថ្នាក់ក្រុង និងខណ្ឌ។
- ផ្សព្វផ្សាយព័ត៌មានផ្នែកច្បាប់ដែលចាំបាច់ដល់មន្ត្រីមូលដ្ឋាន និងសាធារណជននៅក្នុងក្រុង និងខណ្ឌ របស់ខ្លួន។
- ធ្វើការសម្រុះសម្រួល និងផ្សះផ្សាវិវាទ ក្នុងករណីមានការព្រមព្រៀងពីភាគីវិវាទ ។
- ផ្តល់សេវាពិគ្រោះយោបល់ច្បាប់ និងបង្ហាញផ្លូវដល់ភាគីវិវាទ ដើម្បីបញ្ជូនរឿងក្តីទៅតាមនីតិវិធីច្បាប់ ក្នុងករណីវិវាទមិនអាចដោះស្រាយបាន ឬភាគីវិវាទមិនមានបំណងដោះស្រាយនៅថ្នាក់មូលដ្ឋាន។

ប្រការ ៤: ប្រធានមណ្ឌលសេវាកម្មយុត្តិធម៌ ក្រុង ខណ្ឌ មានតួនាទីដូចខាងក្រោម :

- ពិនិត្យ ពិចារណា និងជ្រើសរើស បច្ចេកទេសក្នុងការសម្រុះសម្រួល ហើយកំណត់ចំណុចល្អ និងចំណុចខ្វះខាតនៃដំណើរការសម្រុះសម្រួល ដើម្បីកត់ត្រាទុកជាមេរៀនពិសោធន៍
- ផ្តល់អនុសាសន៍ដើម្បីកែលំអរដំណើរការសម្រុះសម្រួល និងចែករំលែកបទពិសោធន៍ល្អៗដល់ក្រុមប្រឹក្សាសង្កាត់
- ធ្វើការប៉ាន់ប្រមាណពីតម្រូវការផ្នែកច្បាប់នៅក្នុងតំបន់
- ផ្តល់ការប្រឹក្សាយោបល់ផ្នែកច្បាប់ដល់សារធារណៈជនទូទៅ
- ដឹកនាំការសម្រុះសម្រួល និងផ្សះផ្សាវិវាទ ក្នុងករណីមានការព្រមព្រៀងពីភាគីវិវាទ
- បង្កើតបណ្ណាល័យច្បាប់មួយនៅក្នុងសាលាក្រុង ខណ្ឌ និងផ្សព្វផ្សាយព័ត៌មានផ្នែកច្បាប់ដែលទាក់ទងនឹងជីវភាពរស់នៅប្រចាំថ្ងៃរបស់ប្រជាពលរដ្ឋ
- រៀបចំយុទ្ធសាស្ត្រនៃការផ្សព្វផ្សាយព័ត៌មាន ផ្នែកច្បាប់ដល់ប្រជាពលរដ្ឋ
- ផ្តល់យោបល់ និងពត៌មានអំពីនីតិវិធីច្បាប់ ដើម្បីចង្អុលទិសដៅដែលត្រូវបញ្ជូនរឿងក្តី
- ចងក្រងបណ្តាញ ដើម្បីធ្វើការទំនាក់ទំនងជាមួយសាលាដំបូងខេត្ត-រាជធានី និងផ្លាស់ប្តូរព័ត៌មានដែលចាំបាច់
- គ្រប់គ្រងឯកសារហិរញ្ញវត្ថុ។
- គ្រប់គ្រងឯកសារទាក់ទងនឹងការងារដែលចេញមកពីបេសកកម្ម និងសមិទ្ធិផលនានា ។
- ធ្វើរបាយការណ៍តាមកាលកំណត់ស្តីពីហិរញ្ញវត្ថុ និងបញ្ហានានាដើម្បីដាក់ជូនក្រសួងយុត្តិ-ធម៌ និងក្រុមពិគ្រោះយោបល់ថ្នាក់ខេត្ត-រាជធានី តាមរយៈអភិបាលក្រុង ខណ្ឌ។

ប្រការ ៥: អនុប្រធានមានភារកិច្ចជួយដល់ ប្រធានមណ្ឌលសេវាកម្មយុត្តិធម៌ ដើម្បីអនុវត្តឱ្យមានប្រសិទ្ធិភាពនូវភារកិច្ចដូចមានចែងនៅក្នុងប្រការ ៤ ខាងលើ។

ប្រការ ៦: ជំនួយការមានភារកិច្ចជួយដល់ ប្រធាន អនុប្រធានមណ្ឌលសេវាកម្មយុត្តិធម៌ ដើម្បីអនុវត្តឱ្យមានប្រសិទ្ធិភាពនូវភារកិច្ចដូចមានចែងនៅក្នុងប្រការ ៤ និងប្រការ ៥ ខាងលើ ។

ប្រការ ៧: ត្រូវបានតែងតាំងមន្ត្រីក្របខណ្ឌក្រសួងយុត្តិធម៌ ដែលមានគុណសម្បត្តិ និងសមត្ថភាពជំនាញគ្រប់គ្រាន់ ឱ្យទៅបម្រើការងារនៅមណ្ឌលសេវាកម្មយុត្តិធម៌ក្នុងឋានៈជា ប្រធាន

អនុប្រធាន និងជំនួយការមណ្ឌល។ លក្ខណៈវិនិច្ឆ័យសម្រាប់ការជ្រើសតាំងប្រធានមណ្ឌល អនុប្រធាន និងជំនួយការមណ្ឌល ត្រូវកំណត់ដោយប្រកាសក្រសួងយុត្តិធម៌ ។

ប្រការ ៨៖ មណ្ឌលសេវាកម្មយុត្តិធម៌អាចមានទីតាំងនៅក្នុងសាលាក្រុង ខណ្ឌ ឬទីតាំងផ្សេងទៀតទៅតាមការកំណត់ និងស្ថិតនៅក្រោមការគ្រប់គ្រងរបស់ក្រសួងយុត្តិធម៌។

ប្រការ ៩៖ អគ្គនាយកដ្ឋានស្រាវជ្រាវ និងអភិវឌ្ឍន៍លើវិស័យយុត្តិធម៌នៃក្រសួងយុត្តិធម៌ ត្រូវសហការជាមួយសាលាខេត្ត និងសាលារាជធានី រៀបចំអោយមានកិច្ច ប្រជុំក្រុមពិគ្រោះយោបល់ថ្នាក់ខេត្ត-រាជធានីរៀងរាល់ ៦ខែម្ដង ដើម្បីពិនិត្យតាមដានលើ ប្រសិទ្ធិភាពការងាររបស់មណ្ឌលសេវាកម្មយុត្តិធម៌ ។ ក្រុមពិគ្រោះយោបល់នេះត្រូវដឹកនាំ ដោយអភិបាល ឬអភិបាលរងខេត្ត-រាជធានី ហើយមានសមាជិកជាតំណាងមកពីតុលាការ អយ្យការ នគរបាល កងរាជអាវុធហត្ថ គណៈកម្មការសុរិយោដី មន្ទីរកិច្ចការនារី អង្គការមិនមែនរដ្ឋាភិបាល និងស្ថាប័នជំនាញផ្សេងៗទៀតដែលពាក់ព័ន្ធ ។

ប្រការ ១០៖ ខុទ្ទកាល័យ អគ្គាធិការដ្ឋានកិច្ចការតុលាការ គ្រប់អគ្គនាយកដ្ឋាន និងអង្គភាពពាក់ព័ន្ធក្រោមឱវាទក្រសួងយុត្តិធម៌ សាលាដំបូងខេត្តកំពត អយ្យការអមសាលាដំបូងខេត្តកំពត សាលាដំបូងខេត្តព្រៃវែង អយ្យការអមសាលាដំបូងខេត្តព្រៃវែង សាលាដំបូងរាជធានីភ្នំពេញ អយ្យការអមសាលាដំបូងរាជធានីភ្នំពេញ និងស្ថាប័នពាក់ព័ន្ធត្រូវអនុវត្តប្រកាសនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ,ថ្ងៃទី ២៥ ខែ កុម្ភៈ ឆ្នាំ ២០១០

រដ្ឋមន្ត្រី

អង្គ វង្សវឌ្ឍានា

<u>**កន្លែងទទួល**</u> :

- ទីស្ដីការគណៈរដ្ឋមន្ត្រី
- ទីស្ដីការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ខុទ្ទកាល័យសម្ដេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន**
- ខុទ្ទកាល័យឯកឧត្ដម **ស ខេង** ឧបនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្ដម **ប៊ិន ឈិន** ឧបនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យលោកជំទាវ **ម៉ែនសំអន** ឧបនាយករដ្ឋមន្ត្រីប្រចាំការ
- សាលាខេត្តកំពត
- សាលាខេត្តព្រៃវែង
- សាលារាជធានីភ្នំពេញ
- សាលាក្រុង ខណ្ឌពាក់ព័ន្ធ
- នាយកគ្រប់គ្រងគំរោងថ្នាក់ជាតិ

  "ដើម្បីជូនជ្រាប"
- ដូចប្រការ ១០ "ដើម្បីអនុវត្ត"
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងអប់រំ យុវជន និងកីឡា
លេខ : ០១ អយក.ណែណ

លិខិតចូល
ថ្ងៃទី..២១..ខែ.មីនា..ឆ្នាំ2010

សេចក្តីណែនាំ
ស្តីពី
ការប្រឡងសញ្ញាបត្រមធ្យមសិក្សាចំណេះទូទៅ និងបំពេញវិជ្ជា

យោង :
- ព្រះរាជក្រឹត្យ លេខ នស/ រកត/ ០៧៩៦ / ៩២ ចុះថ្ងៃទី ២៦ ខែ កក្កដា ឆ្នាំ ១៩៩៦ ស្តីពីប្រព័ន្ធអប់រំចំណេះទូទៅ ១២ ឆ្នាំ។
- ប្រកាសលេខ ៣២៨៨ អយក.ប្រក ចុះថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០១០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃការប្រឡងសញ្ញាបត្រមធ្យមសិក្សាបឋមភូមិ។
- ប្រកាសលេខ ៣១៩៤ អយក.ប្រក ចុះថ្ងៃទី ២៩ ខែ ធ្នូ ឆ្នាំ ២០១០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃការប្រឡងសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ។
- ប្រកាសលេខ ៣២៨៧ អយក.ប្រក ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃការប្រឡងសញ្ញាបត្រមធ្យមសិក្សាសម្រាប់គ្រឹះស្ថានមធ្យមសិក្សាឯកជន ដែលបង្រៀនគ្រប់មុខវិជ្ជាជាភាសាអង់គ្លេស (លើកលែងមុខវិជ្ជាភាសាខ្មែរ)។

ដើម្បីឱ្យការប្រឡងសញ្ញាបត្រមធ្យមសិក្សាចំណេះទូទៅ និងបំពេញវិជ្ជា មានលក្ខណៈល្អប្រសើរ ក្រសួងអប់រំ យុវជន និងកីឡា សូមធ្វើការណែនាំដូចតទៅ :

I. កាលបរិច្ឆេទប្រឡង និងការទទួលពាក្យសុំប្រឡង :

1. កាលបរិច្ឆេទប្រឡងសញ្ញាបត្រមធ្យមសិក្សាបឋមភូមិ : **ថ្ងៃទី ០៥ កក្កដា ២០១០។**
2. កាលបរិច្ឆេទប្រឡងសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ : **ថ្ងៃទី ២៦ កក្កដា ២០១០។**
3. កាលបរិច្ឆេទនៃការទទួលពាក្យសុំប្រឡងសញ្ញាបត្រមធ្យមសិក្សាបឋមភូមិ និងទុតិយភូមិ : **ថ្ងៃទី ០១ មីនា ២០១០ ដល់ថ្ងៃទី ២២ មីនា ២០១០។**

II. វិញ្ញាសា រយៈពេល និងពិន្ទុនៃការប្រឡង :

II.1 សម្រាប់ការប្រឡងសញ្ញាបត្រមធ្យមសិក្សាបឋមភូមិ :

១_ ភាសាខ្មែរ	រយៈពេល ១២០នាទី	ពិន្ទុពី 0 ដល់ ១០០
២_ គណិតវិទ្យា	រយៈពេល ១២០នាទី	ពិន្ទុពី 0 ដល់ ១០០
៣_ រូបវិទ្យា	រយៈពេល ៤០នាទី	ពិន្ទុពី 0 ដល់ ៣០
៤_ គីមីវិទ្យា	រយៈពេល ៤០នាទី	ពិន្ទុពី 0 ដល់ ២៨
៥_ ជីវវិទ្យា	រយៈពេល ៤០នាទី	ពិន្ទុពី 0 ដល់ ២៨
៦_ ផែនដីវិទ្យា	រយៈពេល ៤០នាទី	ពិន្ទុពី 0 ដល់ ២៨
៧_ ប្រវត្តិវិទ្យា	រយៈពេល ៤០នាទី	ពិន្ទុពី 0 ដល់ ២៨

៨_ ភូមិវិទ្យា	រយៈពេល ៤០នាទី	ពិន្ទុពី 0 ដល់	២៨
៩_ សីលធម៌_ពលរដ្ឋវិជ្ជា	រយៈពេល ៤០នាទី	ពិន្ទុពី 0 ដល់	៣០
១០_ ភាសាបរទេស	រយៈពេល ៤៥នាទី	ពិន្ទុពី 0 ដល់	៥០

ជាវិញ្ញាសាតាមស្ម័គ្រ

* ពិន្ទុ 0 បើសិស្សធ្វើបាន ពិន្ទុក្រោម ២៦ ។

* ពិន្ទុ ជាផលសង រវាងពិន្ទុដែលសិស្សធ្វើបាន នឹង ២៥ បើសិស្សធ្វើបានលើសពី ២៥ ។

II.2 សម្រាប់ការប្រឡងសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ :

១_ ភាសាខ្មែរ	រយៈពេល ១២០នាទី	ពិន្ទុពី 0 ដល់	១០០
២_ គណិតវិទ្យា	រយៈពេល ១៥០នាទី	ពិន្ទុពី 0 ដល់	១២៥
៣_ រូបវិទ្យា	រយៈពេល ៩០នាទី	ពិន្ទុពី 0 ដល់	៧៥
៤_ គីមីវិទ្យា	រយៈពេល ៦០នាទី	ពិន្ទុពី 0 ដល់	៥០
៥_ ជីវវិទ្យា	រយៈពេល ៦០នាទី	ពិន្ទុពី 0 ដល់	៥០
៦_ ផែនដីវិទ្យា	រយៈពេល ៣០នាទី	ពិន្ទុពី 0 ដល់	២៥
៧_ ប្រវត្តិវិទ្យា	រយៈពេល ៤៥នាទី	ពិន្ទុពី 0 ដល់	៣៧
៨_ ភូមិវិទ្យា	រយៈពេល ៤៥នាទី	ពិន្ទុពី 0 ដល់	៣៨
៩_ សីលធម៌_ពលរដ្ឋវិជ្ជា	រយៈពេល ៦០នាទី	ពិន្ទុពី 0 ដល់	៥០
១០_ ភាសាបរទេស	រយៈពេល ៦០នាទី	ពិន្ទុពី 0 ដល់	៥០

ជាវិញ្ញាសាតាមស្ម័គ្រ

* ពិន្ទុ 0 បើសិស្សធ្វើបាន ពិន្ទុក្រោម ២៦ ។

* ពិន្ទុ ជាផលសង រវាងពិន្ទុដែលសិស្សធ្វើបាន នឹង ២៥ បើសិស្សធ្វើបានលើសពី ២៥ ។

* សិស្សណាដែលបានជ្រើសរើសយកភាសាណាមួយនៅពេលប្រឡងឆមាសទី១ ត្រូវជ្រើសរើសយកភាសាដដែលនោះសម្រាប់ការប្រឡងឆមាសទី២ និងប្រឡងថ្នាក់ជាតិ ហើយចាំបាច់ត្រូវចុះភាសាដែលបានជ្រើសរើសនោះ ក្នុងពាក្យសុំប្រឡង ដើម្បីងាយស្រួលក្នុងការរៀបចំធ្វើប្រធានវិញ្ញាសាភាសាបរទេស។

II.3 សម្រាប់គ្រឹះស្ថានមធ្យមសិក្សាឯកជនបង្រៀនគ្រប់មុខវិជ្ជា ជាភាសាអង់គ្លេស :

១. ការប្រឡងសញ្ញាបត្រមធ្យមសិក្សាបឋមភូមិ និងទុតិយភូមិ បេក្ខជនពុំមានកិច្ចការសម្រាប់ភាសាបរទេសទេ (ប្រកាសលេខ ៣២៨៧ អយក.ប្រក ចុះថ្ងៃទី ៣១ ធ្នូ ២០០៩)។

២. វិញ្ញាសាទាំងអស់ជាភាសាអង់គ្លេស លើកលែងតែវិញ្ញាសាភាសាខ្មែរ។

៣. លោកគ្រូ អ្នកគ្រូបង្រៀនថ្នាក់ទី១២ និងទី៩ ត្រូវផ្ញើសំណើប្រធានវិញ្ញាសាប្រឡង ៣វិញ្ញាសា ក្នុងមួយមុខវិជ្ជាសម្រាប់អ្នកបង្រៀនម្នាក់ ដោយភ្ជាប់អត្រាកំណែមកជាមួយផង ដើម្បីជាទុនសម្រាប់ក្រសួងពិចារណា និងជ្រើសរើស។ លោកគ្រូ អ្នកគ្រូដែលជាអ្នកស្នើប្រធានវិញ្ញាសាត្រូវរក្សាការសម្ងាត់ និងតម្លៃមុខវិជ្ជារបស់ខ្លួនដោយស្មារតីទទួលខុសត្រូវខ្ពស់ចំពោះមុខក្រសួងអប់រំ យុវជន និងកីឡា។ សំណើប្រធានវិញ្ញាសានីមួយៗ ត្រូវដាក់ក្នុងស្រោមសម្ងាត់ដោយបញ្ជាក់មុខវិជ្ជាលើស្រោមនោះផង។ គ្រឹះស្ថានមធ្យមសិក្សានីមួយៗ ត្រូវប្រមូលស្រោមសំណើប្រធានវិញ្ញាសាទាំងអស់ដាក់ក្នុងស្រោមសម្ងាត់រួម រួចផ្ញើទៅនាយកដ្ឋានមធ្យមសិក្សាចំណេះទូទៅឱ្យបាន**មុនថ្ងៃទី ២០ ខែឧសភា ឆ្នាំ ២០១០**។ វិញ្ញាសានីមួយៗត្រូវដាក់រយៈពេល ពិន្ទុសរុប និងពិន្ទុលំអិតតាមសំណួរនីមួយៗ។

III. សំណុំលិខិតដាក់ពាក្យសុំប្រឡង និងបេក្ខភាពប្រឡង :

1. សំណុំលិខិតដាក់ពាក្យសុំប្រឡងរបស់បេក្ខជន ត្រូវបំពេញដោយដៃបេក្ខជនផ្ទាល់(គំរូជូនភ្ជាប់) បិទតែម ៣០០៛ និង មានភ្ជាប់បង្កាន់ដៃបង់សិទ្ធិសុំប្រឡងដូចខាងក្រោម :

- បេក្ខជនប្រឡងសញ្ញាបត្រមធ្យមសិក្សាបឋមភូមិ បង់ថ្លៃសិទ្ធិប្រឡង ១០០០រៀល ។
- បេក្ខជនប្រឡងសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ បង់ថ្លៃសិទ្ធិប្រឡង ១៥០០រៀល ។

១- ពាក្យសុំប្រឡងសញ្ញាបត្រមធ្យមសិក្សាបឋមភូមិ ត្រូវភ្ជាប់ :

- សលាកបត្រឯកត្តជនទំហំ១៥ស.ម គុណនឹង ២១ស.ម មានបិទរូបថតថ្មីថតចំពីមុខទំហំ ៤ស.ម គុណនឹង ៦ស.ម ចំនួន ២សន្លឹក។
- បង្កាន់ដៃបង់សិទ្ធិប្រឡង ១សន្លឹក។
- រូបថត ថតថ្មី ថតចំពីមុខ ទំហំ៤ស.ម គុណនឹង ៦ស.ម“រូបថតដែលបានបិទលើសលាកបត្រឯកត្តជន” ចំនួន ២សន្លឹក។
- សេចក្តីចម្លងសំបុត្របញ្ជាក់កំណើត ឬសំបុត្របញ្ជាក់កំណើត ចំនួន ១សន្លឹក (ថតចម្លង)
- សៀវភៅសិក្ខាគារិក “ចំពោះសិស្សសាលារៀនឯកជន ”

២- ពាក្យសុំប្រឡងសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ ត្រូវភ្ជាប់ :

- វិញ្ញាបនបត្របណ្តោះអាសន្នមធ្យមសិក្សាបឋមភូមិ ១សន្លឹក (ថតចម្លង)
- សេចក្តីចម្លងសំបុត្របញ្ជាក់កំណើត ឬសំបុត្របញ្ជាក់កំណើតចំនួន ១សន្លឹក (ថតចម្លង)
- បង្កាន់ដៃបង់សិទ្ធិប្រឡង ១ សន្លឹក
- សៀវភៅសិក្ខាគារិក “ចំពោះសិស្សសាលាឯកជន ”
- វិញ្ញាបនបត្របញ្ចប់ការសិក្សាថ្នាក់ទី ១២ (ចំពោះបេក្ខជនស្វ័យរិន) ១ សន្លឹក

៣- ការភ្ជាប់សេចក្តីចម្លងសំបុត្របញ្ជាក់កំណើត ឬសំបុត្របញ្ជាក់កំណើត បេក្ខជនត្រូវថតចម្លងដោយពុំចាំបាច់ ធ្វើនិត្យានុកូលភាព។ ចំពោះមន្ត្រីទទួលសំណុំលិខិតដាក់ពាក្យសុំប្រឡង គ្រាន់តែយកឯកសារថតចម្លង និង ឯកសារច្បាប់ដើម មកផ្ទៀងផ្ទាត់ឱ្យបានត្រឹមត្រូវដើម្បីចៀសវាងការកោសលុប ឬលុបកែខុសពីលំនាំច្បាប់ដើម នឹងត្រូវបញ្ជាក់អ្នកទទួលខុសត្រូវពិនិត្យផ្ទៀងផ្ទាត់ឯកសារ “ពិតជាត្រឹមត្រូវតាមច្បាប់ដើម ”ដោយចុះហត្ថលេខា និងឈ្មោះអ្នកពិនិត្យជាសម្គាល់។

សម្គាល់ : ការចំណាយរបស់សិស្សម្នាក់ លើថ្លៃសិទ្ធិប្រឡង ថ្លៃតែម និងសំណុំឯកសារសម្រាប់ដាក់ពាក្យសុំប្រឡងយ៉ាង ច្រើន២៥០០រៀល សម្រាប់ការប្រឡងសញ្ញាបត្រមធ្យមសិក្សាបឋមភូមិ និង៣០០០រៀលសម្រាប់ការប្រឡង សញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ។

2. បេក្ខភាពប្រឡង :

ក- **បេក្ខភាពប្រឡងសញ្ញាបត្រមធ្យមសិក្សាបឋមភូមិ :**

សិស្សសាលារៀនចំណេះទូទៅសាធារណៈ និងឯកជន ដែល ÷

- បានរៀននៅមធ្យមសិក្សាបឋមភូមិគ្រប់កម្រិតថ្នាក់។
- បានរៀនចប់កម្មវិធីសិក្សាថ្នាក់ទី៩។
- បានគោរពត្រឹមត្រូវតាមបទបញ្ជាផ្ទៃក្នុង សម្រាប់គ្រឹះស្ថានមធ្យមសិក្សា។
- បានត្រូវវាយតម្លៃផ្នែកសីលធម៌ប្រចាំឆ្នាំ ចាប់ពីមធ្យមឡើងទៅ។

អាចដាក់ពាក្យសុំប្រឡងសញ្ញាបត្រមធ្យមសិក្សាបឋមភូមិ នៅតាមគ្រឹះស្ថានសិក្សារបស់ខ្លួនបាន។

ខ- **បេក្ខភាពប្រឡងសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ :**

សិស្សសាលារៀនចំណេះទូទៅសាធារណៈ និងឯកជន ដែល ÷

- បានប្រឡងជាប់សញ្ញាបត្រមធ្យមសិក្សាបឋមភូមិ។
- បានរៀននៅមធ្យមសិក្សាទុតិយភូមិគ្រប់កម្រិតថ្នាក់។
- បានរៀនចប់កម្មវិធីសិក្សាថ្នាក់ទី១២ ។
- បានគោរពត្រឹមត្រូវតាមបទបញ្ជាផ្ទៃក្នុង សម្រាប់គ្រឹះស្ថានមធ្យមសិក្សា។
- បានត្រូវវាយតម្លៃផ្នែកសីលធម៌ប្រចាំឆ្នាំចាប់ពីមធ្យមឡើងទៅ។

អាចដាក់ពាក្យសុំប្រឡងសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ នៅតាមគ្រឹះស្ថានសិក្សារបស់ខ្លួនបាន។

គ- សិស្សសាលារៀនចំណេះទូទៅសាធារណៈ និងឯកជន ពុំអាចទទួលស្គាល់ជាបេក្ខភាពបានគឺ ÷

- សិស្សដែលឈប់ដោយមានច្បាប់ **ចាប់ពី ៥៥ ដងឡើងទៅ**។
- សិស្សដែលឈប់ឥតច្បាប់ និងមានច្បាប់ **ចាប់ពី ៤០ ដងឡើងទៅ**។
- សិស្សដែលឈប់ឥតច្បាប់ **ចាប់ពី ៣០ ដងឡើងទៅ**។
- សិស្សដែលគ្មានមធ្យមភាគពិន្ទុឆមាសទី១ ឬឆមាសទី២។

ឃ- អតីតបេក្ខជនដែលបានប្រឡងធ្លាក់សញ្ញាបត្រមធ្យមសិក្សាបឋមភូមិ អាចដាក់ពាក្យសុំប្រឡងសញ្ញាបត្រមធ្យមសិក្សាបឋមភូមិនៅតាមមន្ទីរអប់រំ យុវជន និងកីឡារាជធានីភ្នំពេញ និងខេត្ត ដែលសាមីខ្លួនបានសុំប្រឡងពីមុន ឬអាចដាក់ពាក្យសុំប្រឡងនៅតាមមន្ទីរអប់រំ យុវជន និងកីឡារាជធានីភ្នំពេញ និងខេត្តផ្សេងទៀត ដោយគ្រាន់តែធ្វើសេចក្ដីបញ្ជាក់ពីការប្រឡងធ្លាក់លើពាក្យសុំប្រឡង ពីមន្ទីរអប់រំ យុវជន និងកីឡារាជធានីភ្នំពេញ និងខេត្ត ដែលសាមីខ្លួនបានប្រឡងធ្លាក់ពីមុន។

ង- អតីតបេក្ខជនដែលបានប្រឡងធ្លាក់សញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ អាចដាក់ពាក្យសុំប្រឡងសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ នៅតាមមន្ទីរអប់រំ យុវជន និងកីឡារាជធានីភ្នំពេញ និងខេត្ត ដែលសាមីខ្លួនបានសុំប្រឡងពីមុន ឬនៅនាយកដ្ឋានមធ្យមសិក្សាចំណេះទូទៅ នៃក្រសួងអប់រំ យុវជន និងកីឡា ដោយមានភ្ជាប់វិញ្ញាបនបត្របញ្ចប់ការសិក្សាថ្នាក់ទី១២។

ច- ចំនួនអវត្តមានត្រូវគិតចាប់ពីបើកសាលារហូតដល់ថ្ងៃទី **០១ មិថុនា ២០១០** សម្រាប់**សិស្សថ្នាក់ទី ៩** និងដល់ថ្ងៃទី **១៨ មិថុនា ២០១០** សម្រាប់**សិស្សថ្នាក់ទី ១២**។

IV. **ការរៀបចំបញ្ជីរាយនាមសិស្សថ្នាក់ទី ១២ :**

មន្ទីរអប់រំ យុវជន និងកីឡារាជធានីភ្នំពេញ និងខេត្ត ត្រូវទទួលខុសត្រូវក្នុងការរៀបចំ

- បញ្ជីបេក្ខភាពប្រឡង
- បញ្ជីរាយនាមសិស្សប្រឡងឆមាសលើកទី១ លើកទី២
- តារាងស្រង់ពិន្ទុប្រឡងឆមាសលើកទី១ លើកទី២ និងតារាងស្រង់ពិន្ទុប្រចាំឆ្នាំ ។

បើសាលាមានកុំព្យូទ័រ មន្ទីរអប់រំ យុវជន និងកីឡារាជធានីភ្នំពេញ និងខេត្ត ត្រូវប្រគល់ឱ្យសាលារៀបចំបញ្ជីខាងលើ ដូចតទៅ :

១- ត្រូវវាយបញ្ជីរាយនាមសិស្សថ្នាក់ទី១២ តាមថ្នាក់ (គំរូទី១១) ហើយធ្វើការផ្ទៀងផ្ទាត់គោត្តនាម និងនាមខ្លួន ភេទ ថ្ងៃ ខែ ឆ្នាំកំណើត ខេត្ត-ក្រុងកំណើត ឈ្មោះឪពុក ឈ្មោះម្ដាយ និងបោះពុម្ពបញ្ជីរាយនាមសិស្សថ្នាក់ទី១២ តាម

ថ្នាក់ទាំងនោះ យកឱ្យសិស្សតាមថ្នាក់ធ្វើការពិនិត្យ និងកែតម្រូវដោយផ្ទាល់ តាមរយៈគ្រូទទួលបន្ទុកថ្នាក់។ តាមរយៈបញ្ជីនេះ សិស្សម្នាក់ៗត្រូវពិនិត្យផ្ទៀងផ្ទាត់គោត្តនាម និងនាមខ្លួន ភេទ ថ្ងៃ ខែ ឆ្នាំកំណើត ខេត្ត-ក្រុងកំណើត ឈ្មោះឪពុក ឈ្មោះម្តាយរបស់ខ្លួនដោយយកវិញ្ញាបនបត្របណ្តោះអាសន្នមធ្យមសិក្សាបឋមភូមិជាគោល[1] រួចកែតម្រូវចំណុចខុសនឹងប៊ិចពណ៌ក្រហមដោយខ្លួនឯងផ្ទាល់។ បន្ទាប់ពីបានពិនិត្យ ផ្ទៀងផ្ទាត់ដោយហ្មត់ចត់និងកែតម្រូវរួចហើយសិស្សម្នាក់ៗ ត្រូវចុះហត្ថលេខានិងឈ្មោះ ទោះជាសិស្សខ្លះពុំមាន ចំណុចអ្វីត្រូវកែក៏ដោយ។ ក្រោយពីសិស្សបានកែតម្រូវ និងចុះហត្ថលេខានិងឈ្មោះ លើបញ្ជីនេះគ្រប់គ្នាហើយ នាយកសាលាត្រូវថតចម្លង ១ច្បាប់ទុកជាឯកសារគោល និងផ្ញើបញ្ជីនេះ (ច្បាប់ដើម) មកនាយកដ្ឋានមធ្យមសិក្សាចំណេះទូទៅ (ការិយាល័យប្រឡង)តាមរយៈមន្ទីរអប់រំ យុវជន និងកីឡារាជធានីភ្នំពេញ និងខេត្ត (បញ្ជីគំរូទី២១)។ បញ្ជីនេះជាបញ្ជីគោល សម្រាប់ប្រើប្រាស់ក្នុងការរៀបចំធ្វើវិញ្ញាបនបត្រ ឬសញ្ញាបត្រ នៅពេលសិស្សថ្នាក់ទី១២ទាំងនោះបានប្រឡងសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិរួច។ ក្រសួងអប់រំ យុវជន និងកីឡា ពុំទទួលខុសត្រូវចំពោះការតវ៉ាទាំងឡាយណាខុសពីទិន្នន័យដែលមានក្នុងបញ្ជីនេះឡើយ។

២- ត្រូវធ្វើការកែតម្រូវជាចុងក្រោយ ដោយផ្អែកលើបញ្ជី (គំរូទី ០២១)ខាងលើ ឱ្យបានត្រឹមត្រូវទើបបោះពុម្ព :

- បញ្ជីរាយនាមសិស្សប្រឡងឆមាសទី១ (ថតចម្លងសម្រាប់សាលាទុកប្រើប្រាស់ប្រឡងឆមាសទី២)
- បញ្ជីបេក្ខភាពប្រឡង
- តារាងស្រង់ពិន្ទុឆមាសទី១ ទី២
- តារាងស្រង់ពិន្ទុប្រចាំឆ្នាំ (បញ្ជីទាំងនោះមានលំដាប់អក្ខរក្រម និងលំដាប់លេខរៀងដូចគ្នា ហើយលេខរៀងរូបថតក៏ដូចនឹងលេខរៀងក្នុងបញ្ជីទាំងនោះដែរ)។

បញ្ជីទាំងនោះ ត្រូវបានចាត់ទុកជាបញ្ជីផ្លូវការ ដែលពុំអាចធ្វើការកែតម្រូវណាមួយក្នុងកុំព្យូទ័របានទៀតឡើយ បានន័យថាការកែតម្រូវក្នុងកុំព្យូទ័រត្រូវបានបញ្ចប់។ **ការកែតម្រូវផ្សេងៗ ក្នុងកុំព្យូទ័រនាំឱ្យអក្ខរក្រម ព្យញ្ជនៈនិងស្រៈត្រូវផ្លាស់ប្តូរខុសភាពដើម ហើយរូបថត Digital ពិន្ទុឆមាស និងពិន្ទុប្រចាំឆ្នាំរេលខុសពីឈ្មោះដើមរបស់បេក្ខជន។ បើមានអ្វីដែលត្រូវកែតម្រូវចាំបាច់គ្រាន់តែកែតម្រូវលើបញ្ជីបេក្ខភាព ដោយប៊ិចពណ៌ក្រហមបានហើយ។**

៣- ត្រូវគូសឈ្មោះសិស្ស (សិស្សផ្ទេរចេញ ឬដកបេក្ខភាព) នៅក្នុងតារាងស្រង់ពិន្ទុប្រចាំឆ្នាំ ដោយប៊ិចពណ៌ក្រហម និងដាក់មូលហេតុច្បាស់លាស់ត្រង់ខ្ទង់ផ្សេងៗ ដោយផ្ញើភ្ជាប់បញ្ជីផ្ទេរ ឬបញ្ជីដកបេក្ខភាពមកជាមួយ។

៤- ត្រូវសរសេរឈ្មោះសិស្សបន្ថែមដោយដៃ (សិស្សផ្ទេរចូលនៅឆមាសទី២)តាមលេខរៀងខាងក្រោយគេបង្អស់នៃបញ្ជីតារាងស្រង់ពិន្ទុប្រចាំឆ្នាំ និងបញ្ជាក់ពីអតីតដ្ឋាននៃការផ្ទេរមក។

V. ការទទួលសំណុំលិខិតដាក់ពាក្យសុំប្រឡង :

១- ការប្រឡងសញ្ញាបត្រមធ្យមសិក្សាបឋមភូមិ : លោកនាយក នាយិកាសាលា :

- ត្រូវរាប់ចំនួនសិស្សដាក់ពាក្យសុំប្រឡង ទៅតាមបញ្ជីសុំបេក្ខភាពប្រឡងសញ្ញាបត្រមធ្យមសិក្សាបឋមភូមិ ផ្ញើមកមន្ទីរអប់រំ យុវជន និងកីឡារាជធានីភ្នំពេញ និងខេត្ត **មុនថ្ងៃទី ០១ ខែ មេសា ឆ្នាំ ២០១០** បន្ទាប់ពីឈប់ទទួលពាក្យសុំប្រឡង។
- ត្រូវពិនិត្យសំណុំលិខិតដាក់ពាក្យសុំប្រឡងរបស់សិស្ស ដោយផ្ទៀងផ្ទាត់ឱ្យបានត្រឹមត្រូវនូវ ឈ្មោះថ្ងៃខែឆ្នាំកំណើត ទីកន្លែងកំណើត ឈ្មោះឪពុក ម្តាយរបស់សិស្ស ដែលសរសេរក្នុងពាក្យសុំប្រឡង និងសលាកបត្រឯកត្តជន និង

[1] (វិញ្ញាបនបត្របណ្តោះអាសន្នមធ្យមសិក្សាបឋមភូមិ ត្រូវមានគោត្តនាមនិងនាមខ្លួន ភេទ ថ្ងៃ ខែ ឆ្នាំកំណើត ខេត្ត-ក្រុងកំណើត ឈ្មោះឪពុក ឈ្មោះម្តាយដូចគ្នាទាំងស្រុង)

សេចក្តីចម្លងសំបុត្របញ្ជាក់កំណើត ឬសំបុត្របញ្ជាក់កំណើត ធ្វើជាគោល។ ពាក្យសុំប្រឡង និងសលាកបត្រឯកត្តជនរបស់សិស្សត្រូវសរសេរឱ្យច្បាស់។

- ត្រូវណែនាំឱ្យសិស្សសរសេរសំណុំលិខិតដាក់ពាក្យសុំប្រឡងដោយខ្លួនឯង ចៀសវាងប្រមូលយកទៅឱ្យគ្រូទទួលបន្ទុកថ្នាក់ ឬមិត្តភក្តិ ឬអ្នកដទៃសរសេរជំនួស។
- ត្រូវចុះហត្ថលេខា និងបោះត្រាលើសលាកបត្រពិន្ទុប្រចាំឆ្នាំ របស់សិស្សថ្នាក់ទី៩ (បេក្ខជនម្នាក់ៗ បំពេញជា ២ច្បាប់) ដែលសរសេរបំពេញដោយផ្ទាល់ដៃសិស្ស ចៀសវាងការកោសលុប ឬសរសេរត្រួត។

២- ការប្រឡងសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ លោកនាយក នាយិកាសាលា : ត្រូវយកបញ្ជីបេក្ខភាពប្រឡង ផ្ទៀងផ្ទាត់ឱ្យបានត្រឹមត្រូវជាមួយពាក្យសុំប្រឡង ដោយយកវិញ្ញាបនបត្របណ្តោះអាសន្នមធ្យមសិក្សាបឋមភូមិធ្វើជាគោល។ បើពិនិត្យទៅឃើញពុំត្រឹមត្រូវ (ដូចជាឈ្មោះ ភេទ ថ្ងៃ ខែ ឆ្នាំកំណើត ឈ្មោះឪពុកម្តាយ) ត្រូវកែដោយបិចក្រហមនៅលើបញ្ជីបេក្ខភាព និងតារាងស្រង់ពិន្ទុប្រចាំឆ្នាំ។ ពាក្យសុំប្រឡងត្រូវភ្ជាប់វិញ្ញាបនបត្របណ្តោះអាសន្នមធ្យមសិក្សាបឋមភូមិ (សម័យប្រឡងត្រឹមឆ្នាំ២០០៧ ឬមុនឆ្នាំ ២០០៧)។

VI. ការថតរូប Digital និងបញ្ជីឯកបេក្ខភាពប្រឡងសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ :

១- ការថតរូប Digital

លោកនាយក នាយិកាសាលា :

ក- ត្រូវប្រមូលសិស្សថ្នាក់ទី ១២ មកថតរូបដោយប្រើ Digital Camera តាមលំដាប់លេខរៀងនៃបញ្ជីសំណើសុំបេក្ខភាពប្រឡង តាមវិទ្យាល័យរបស់ខ្លួន **ចាប់ពីថ្ងៃទី ១៥ ដល់ ២២ ខែ មីនា ឆ្នាំ ២០១០** ។

ខ- ករណីសិស្សអវត្តមានដោយមូលហេតុផ្សេងៗ (យឺតយ៉ាវ បោះបង់) ត្រូវសរសេរឈ្មោះសិស្ស និងមូលហេតុដាក់លើក្រដាស (A4) រួចថត ១ប៉ុស្តិ៍ តាមលំដាប់លេខរៀងនៃបញ្ជីបេក្ខភាពដែលសិស្សនោះអវត្តមាន មិនអាចថតរូបរំលងលេខរៀងនៃបញ្ជីបេក្ខភាពបានទេ នាំឱ្យរលំខុសឈ្មោះរបស់បេក្ខជន។

គ- ត្រូវធ្វើបញ្ជីរាយនាមសិស្សដែលអវត្តមានមិនបានមកថតរូប ធ្វើការផ្សព្វផ្សាយកំណត់ពេលថតជាថ្មី ដើម្បីថតរូបដាក់បំពេញជំនួសឱ្យបានទាន់កាលកំណត់របស់ក្រសួង។ ករណីសិស្សទាំងឡាយណាដែលគ្មានរូបថតក្នុងទិន្នន័យ (មិនចូលខ្លួនមកថតរូប)ត្រូវធ្វើលិខិតផ្តល់ព័ត៌មានដល់មាតាបិតា ឬអាណាព្យាបាល។ សិស្សដែលមិនចូលមកថតរូប ចាត់ទុកដូចជាសិស្សនោះ ពុំបានដាក់ពាក្យសុំប្រឡង។

ឃ- ទំហំរូបថត ៤៨០ × ៦៤០ pixel ចម្ងាយថត ១,៥០ម៉ែត្រ ទៅ ២ម៉ែត្រពីសិស្សអង្គុយ ប្រើ Zoom ថតខាងក្រៅអគារដែលមានពន្លឺថ្ងៃគ្រប់គ្រាន់។

២- បញ្ជីឯកបេក្ខភាពប្រឡង

លោកនាយក នាយិកាសាលា :

ក- ត្រូវមានការទទួលខុសត្រូវខ្ពស់ ក្នុងការធ្វើបញ្ជីឯកបេក្ខភាពសិស្សក្នុងវិទ្យាល័យរបស់ខ្លួន ចៀសវាងការដកបេក្ខភាពដោយភ័ន្តច្រឡំ ខ្វះការពិនិត្យតាមដាន ខ្វះការប្រុងប្រយ័ត្នខ្ពស់ នាំឱ្យមានផលវិបាកនៅពេលប្រឡង។

ខ- ត្រូវពិនិត្យតាមដាន ស្រាវជ្រាវ ផ្ទៀងផ្ទាត់ឯកសាររបស់សិស្សដូចជា សិស្សដាក់ពាក្យសុំប្រឡងយឺតយ៉ាវ សិស្សមិនបានមកថតរូប សិស្សមានបញ្ហាផ្សេងៗ វិញ្ញាបនបត្របណ្តោះអាសន្នមធ្យមសិក្សាបឋមភូមិ សំបុត្របញ្ជាក់កំណើត ចំនួនវត្តមាន និងអវត្តមាន ពិន្ទុប្រឡងឆមាសទី១ ឆមាសទី២ ពិន្ទុប្រចាំឆ្នាំ។

គ- ត្រូវផាស់តឿន ក្រើនរំលឹកសិស្សឱ្យដាក់ពាក្យសុំប្រឡង ថតរូប តាមកាលកំណត់ បង្កលក្ខណៈងាយស្រួលដល់សិស្ស យកចិត្តទុកដាក់ចំពោះសិស្សក្រីក្រ។ សិស្សមានបញ្ហាត្រូវធ្វើទំនាក់ទំនងអាណាព្យាបាល ឬឪពុកម្តាយ ឬមិត្តភក្តិ ឬតាមរយៈក្រុមប្រឹក្សាឃុំ-សង្កាត់ ដើម្បីដោះស្រាយ។

ឃ- ត្រូវបិទផ្សាយបញ្ជីផកបេក្ខភាពប្រឡង ដើម្បីផ្សព្វផ្សាយប្រាប់សិស្ស និងអាណាព្យាបាលបានទទួលស្គាល់កំហុសឆ្គង។

ង- នាយក នាយិកាសាលា ត្រូវផ្ញើបញ្ជីផកបេក្ខភាពប្រឡងនេះមកក្រសួង នាយកដ្ឋានមធ្យមសិក្សាចំណេះទូទៅ ការិយាល័យប្រឡង តាមរយៈមន្ទីរអប់រំ យុវជន និងកីឡារាជធានីភ្នំពេញ និងខេត្ត តាមកាលកំណត់ជាកំហិត សម្រាប់ធ្វើការបន្ត។

VII. ការកំណត់មណ្ឌលប្រឡង :

លោក លោកស្រីប្រធានមន្ទីរអប់រំ យុវជន និងកីឡារាជធានីភ្នំពេញ និងខេត្ត ត្រូវរៀបចំកំណត់មណ្ឌលប្រឡង មានលក្ខណៈដូចខាងក្រោម :

១- មណ្ឌលប្រឡងត្រូវរៀបចំដាក់តាមគ្រឹះស្ថានសិក្សានៅរាជធានីភ្នំពេញ និងទីរួមខេត្តឱ្យអស់លទ្ធភាព ទើបរៀបចំដាក់នៅតាម គ្រឹះស្ថានសិក្សានៅទីរួមខណ្ឌ-ស្រុក ដែលនៅជិតទីរួមខេត្ត។ មិនត្រូវយកសាលាបឋមសិក្សាធ្វើជាមណ្ឌលប្រឡង។

២- ក្នុងការរៀបចំមណ្ឌលប្រឡងត្រូវប្រមូលផ្តុំសិស្សឱ្យបានពីរមណ្ឌលយ៉ាងតិច ចំពោះរាជធានីភ្នំពេញ និងខេត្ត ដើម្បីងាយស្រួលរៀបចំមេប្រយោគកុំឱ្យគ្រូនិងសិស្សមានអគតដ្ឋានដូចគ្នា។ សិស្សមួយវិទ្យាល័យ មិនអាចដាក់តែមួយមណ្ឌលប្រឡងបានទេ លើកលែងតែខេត្តដែលមានវិទ្យាល័យតែមួយ។

៣- មណ្ឌលប្រឡងត្រូវមានទិដ្ឋភាពល្អ បរិយាកាសស្ងប់ស្ងាត់ដល់បេក្ខជន ងាយស្រួលការពារ និងរក្សាសុវត្ថិភាពមណ្ឌលប្រឡងបានល្អ ពេលដំណើរការសរសេរ និងងាយស្រួលក្នុងការផ្ញើហឹបប្រធានវិញ្ញាសានិងកិច្ចការបេក្ខជននៅអាជ្ញាធរដែនដីមានសមត្ថកិច្ច។

៤- មណ្ឌលប្រឡងត្រូវយកគ្រឹះស្ថានណាដែលមានដំបូលគត់មត់ល្អ មានទ្វារ បង្អួចសមរម្យ មានតុ កៅអីគ្រប់គ្រាន់ មានរបងព័ទ្ធជុំវិញ មានមាត់ទ្វារច្រកចេញចូល មានសោរចាក់ត្រឹមត្រូវ ណែនាំនាយក នាយិកាសាលា សំអាតទីធ្លាអគារ បន្ទប់ប្រឡង និងបន្ទប់អនាម័យឱ្យបានស្អាតហើយស្រេច មុនដំណើរការប្រឡង។

៥- មណ្ឌលប្រឡងមិនត្រូវយកតុសិស្សទាបៗ សម្រាប់សិស្សបឋមសិក្សាមកប្រើដែលនាំឱ្យបេក្ខជនពិបាកធ្វើកិច្ចការដោយសារអង្គុយទើសជង្គង់ និងអង្គុយប្រជ្រៀតគ្នា។

៦- បន្ទប់ប្រឡងនីមួយៗត្រូវរៀបចំតុ ២៥យ៉ាងតិច គឺតុសម្រាប់សិស្សអង្គុយរៀនធម្មតាពីរនាក់ និងតុ ១៣យ៉ាងតិច គឺតុសម្រាប់សិស្សអង្គុយធម្មតាបួននាក់ បើតុ ជើងម៉ាពុំមាំទាំត្រូវជួសជុល ឬរកតុ ជើងម៉ាថ្មីមកប្តូរ ដើម្បីឱ្យបេក្ខជនងាយស្រួលអង្គុយធ្វើកិច្ចការ។

មណ្ឌលប្រឡងនីមួយៗ ត្រូវមានប្រដាប់បំពងសំឡេង ដែលអាចប្រើប្រាស់បាន នៅពេលដំណើរការប្រឡង។ សាលាដែលត្រូវយកធ្វើមណ្ឌលប្រឡងត្រូវរក្សាទុកបុគ្គលិក ២ឬ៣នាក់ ទៅតាមទំហំមណ្ឌលប្រឡង។ បុគ្គលិករក្សាទុកនេះត្រូវជ្រើសរើសអ្នកដែលចេះប្រើប្រាស់ និងរៀបចំប្រដាប់បំពងសំឡេងហើយឈ្លាសវៃក្នុងការដោះស្រាយកង្វះខាតសម្ភារផ្សេងៗ ជាពិសេសដោះស្រាយចំពោះសិស្សបាត់ឈ្មោះប្រឡង។ ហាមដាច់ខាតការលក់ដូរនៅក្នុងមណ្ឌលប្រឡងក្នុងរយៈពេលដំណើរការការងារប្រឡង។ ត្រូវផ្ញើកំណត់មណ្ឌលប្រឡងទៅក្រសួង នាយកដ្ឋានមធ្យមសិក្សាចំណេះទូទៅឱ្យបាន**មុនថ្ងៃទី ១៥ មេសា ២០១០** ដើម្បីងាយស្រួលនាយកដ្ឋានចុះទៅពិនិត្យស្ថានភាពមណ្ឌលប្រឡងតាមការស្នើសុំ។

VIII. ការផ្តល់សំណុំឯកសារមកនាយកដ្ឋានមធ្យមសិក្សាចំណេះទូទៅ :

មន្ទីរអប់រំ យុវជន និងកីឡារាជធានីភ្នំពេញ និងខេត្ត ត្រូវផ្តល់ឯកសារមកក្រសួង នាយកដ្ឋានមធ្យមសិក្សាចំណេះទូទៅ ការិយាល័យប្រឡង តាមកាលកំណត់ដូចខាងក្រោម :

ក- **មុនថ្ងៃទី ០១ មេសា ឆ្នាំ ២០១០**

១- បញ្ជីរាយនាមសិស្សរៀនថ្នាក់ទី១២ តាមថ្នាក់ដែលសិស្សបានកែតម្រូវចំនួន ១ច្បាប់(ច្បាប់ដើម)(គំរូទី ០២ខ)។

២- បញ្ជីរាយនាមសិស្សរៀនថ្នាក់ទី១២ តាមវិទ្យាល័យ ចំនួន ១ច្បាប់ (ច្បាប់ដើម) (គំរូទី ០៣ខ)។

៣- សំណើសុំបេក្ខភាពបេក្ខជនប្រឡងសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ ចំនួន ០១ច្បាប់ (ច្បាប់ដើម) និង Soft Copy (គំរូទី ០៩ខ)។

៤- សំណើសុំបេក្ខភាពបេក្ខជនស្វ័យរិនប្រឡងសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ ចំនួន ០២ច្បាប់ (ច្បាប់ដើម) និង Soft Copy (គំរូទី ១០ខ)។

៥- រូបថត Digital ទំហំ (480 × 640 pixel) យក (Soft Copy) ។

ខ-**មុនថ្ងៃទី ១៥ មេសា ២០១០**

១- តារាងស្រង់ពិន្ទុឆមាសលើកទី១ ថ្នាក់ទី១២ ចំនួន ០១ច្បាប់ (ច្បាប់ដើម) និង Soft Copy (គំរូទី ០៧ខ)។

២- តារាងសំណើមណ្ឌលប្រឡងសញ្ញាបត្រមធ្យមសិក្សាបឋមភូមិ ចំនួន ០៤ច្បាប់ (គំរូទី ០៧ប)។

៣- តារាងសំណើមណ្ឌលប្រឡងសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ ចំនួន ០៤ច្បាប់ (គំរូទី ០៨ខ)។

គ- **មុនថ្ងៃទី ១០ កក្កដា ឆ្នាំ ២០១០**

១- បញ្ជីដកបេក្ខភាពប្រឡងសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ ចំនួន ០២ច្បាប់ (គំរូទី ១១ខ)។

២- តារាងស្រង់ពិន្ទុឆមាសលើកទី២ ថ្នាក់ទី១២ ចំនួន ០១ច្បាប់ (ច្បាប់ដើម) និង Soft Copy (គំរូទី ១២ខ)។

៣- តារាងស្រង់ពិន្ទុប្រចាំឆ្នាំ សម្រាប់ថ្នាក់ទី១២ ចំនួន ០១ច្បាប់ (ច្បាប់ដើម) (គំរូទី ១៣ខ)។

លោក-លោកស្រីប្រធានមន្ទីរអប់រំ យុវជន និងកីឡារាជធានីភ្នំពេញ និងខេត្ត ត្រូវផ្សព្វផ្សាយសារាចរណែនាំនេះដល់គ្រប់គ្រឹះស្ថានមធ្យមសិក្សា ព្រមទាំងអនុវត្តការណែនាំនេះឱ្យមានប្រសិទ្ធភាពខ្ពស់។

សូមលោក លោកស្រីប្រធានមន្ទីរអប់រំ យុវជន និងកីឡា ទទួលនូវការរាប់អានអំពីខ្ញុំ។

រាជធានីភ្នំពេញ ថ្ងៃទី២២ ខែ កុម្ភៈ ឆ្នាំ ២០១០

រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា

អ៊ឹម សេទ្ធី

កន្លែងទទួល :

- ទីស្តីការគណៈរដ្ឋមន្ត្រី
  «ដើម្បីសូមជ្រាបជាព័ត៌មាន»
- គ្រប់សាលារាជធានីភ្នំពេញ និងខេត្ត
  «ដើម្បីជូនជ្រាបជាព័ត៌មាន»
- គ្រប់អង្គភាពនៃទីស្តីការក្រសួងអយក
  «ដើម្បីជាព័ត៌មាន»
- មន្ទីរអយក. រាជធានីភ្នំពេញ និងខេត្ត
  «ដើម្បីអនុវត្ត»
- កាលប្បវត្តិ-ឯកសារ-នា. មចទ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
ក្រសួងមហាផ្ទៃ

លេខ : ០០៤ សជណ

បរិវិតចូល
ថ្ងៃទី ១១ ខែ ៣ ឆ្នាំ 2010

សេចក្តីណែនាំ

ស្តីពី

ការធ្វើសមាហរណកម្មរចនាសម្ព័ន្ធ និងមន្ត្រីរាជការ ដែលមានបច្ចុប្បន្ន នៅតាមសាលារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ទៅក្នុងរចនាសម្ព័ន្ធថ្មី

អនុលោមតាម**ច្បាប់** ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ **អនុក្រឹត្យ**លេខ ២១៥ អនក្រ.បក ចុះថ្ងៃទី ១៤ ខែ ធ្នូ ឆ្នាំ២០០៩ ស្តីពីតួនាទី ភារកិច្ច និង ទំនាក់ទំនងការងាររបស់ក្រុមប្រឹក្សា គណៈអភិបាលរាជធានីភ្នំពេញ និងក្រុមប្រឹក្សា គណៈអភិបាលខណ្ឌនៃរាជធានីភ្នំពេញ **អនុក្រឹត្យ**លេខ ២១៦ អនក្រ.បក ចុះថ្ងៃទី ១៤ ខែ ធ្នូ ឆ្នាំ២០០៩ ស្តីពីតួនាទី ភារកិច្ច និង ទំនាក់ទំនងការងាររបស់ក្រុមប្រឹក្សា គណៈអភិបាលខេត្ត ក្រុមប្រឹក្សា គណៈអភិបាលក្រុង និងក្រុមប្រឹក្សា គណៈអភិបាលស្រុក **ប្រកាស**លេខ ៤២៧៣ ប្រ.ក ចុះថ្ងៃទី ៣០ ខែ ធ្នូ ឆ្នាំ២០០៩ ស្តីពីការបង្កើតការិយាល័យចំណុះទីចាត់ការនៃសាលារាជធានីភ្នំពេញ ការបង្កើតការិយាល័យនៃសាលាខណ្ឌ និងការកំណត់តួនាទី ភារកិច្ច របៀបរបបការងារនៃការិយាល័យទាំងនោះ និង**ប្រកាស**លេខ ៤២៧៤ប្រ.ក ចុះថ្ងៃទី ៣០ ខែ ធ្នូ ឆ្នាំ២០០៩ ស្តីពីការបង្កើតការិយាល័យចំណុះទីចាត់ការ នៃសាលាខេត្ត ការបង្កើតការិយាល័យនៃសាលាក្រុង ការបង្កើតការិយាល័យនៃសាលាស្រុក និងការកំណត់តួនាទី ភារកិច្ច របៀបរបបការងារ នៃការិយាល័យទាំងនោះ ក្រសួងមហាផ្ទៃសូមធ្វើការណែនាំអំពីគោលការណ៍ និងកិច្ចដំណើរការនៃការធ្វើសមាហរណកម្មមន្ត្រីរាជការ ដែលកំពុងបម្រើការងារនៅតាមសាលារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ទៅក្នុងរចនាសម្ព័ន្ធថ្មី ដូចខាងក្រោម :

I. អំពីគោលការណ៍នៃការធ្វើសមាហរណកម្មមន្ត្រីរាជការ

ការធ្វើសមាហរណកម្មមន្ត្រីរាជការទៅក្នុងរចនាសម្ព័ន្ធថ្មីនៃរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌនីមួយៗ ត្រូវធានា និងគោរពឱ្យបាននូវគោលការណ៍សំខាន់ៗ ដូចខាងក្រោម :

- ធានាឱ្យបាននូវនិរន្តរភាពដំណើរការរដ្ឋបាលរបស់សាលារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ដោយការធ្វើសមាហរណកម្មត្រូវធ្វើទៅតាមផែនការ និងមានកម្មវិធីច្បាស់លាស់ ។
- ធានានូវផលប្រយោជន៍របស់មន្ត្រីរាជការដូចជា ក្របខ័ណ្ឌ ឋានន្តរសក្តិ និងមុខតំណែង លើមូលដ្ឋាននៃការពិចារណាទៅលើមុខងារ ដែលត្រូវផ្ទេរទៅឱ្យរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ នាពេលខាងមុខ ។

II. អំពីដំណើរការនៃការធ្វើសមាហរណកម្មមន្ត្រីរាជការនៅក្នុងរចនាសម្ព័ន្ធថ្មី

១. ការផ្ទេររចនាសម្ព័ន្ធបច្ចុប្បន្ន នៅក្នុងរចនាសម្ព័ន្ធថ្មី

ក. សម្រាប់សាលាខេត្តនីមួយៗ

ខេត្តនីមួយៗ ត្រូវពិនិត្យ សិក្សាទៅលើអង្គភាព និងការិយាល័យដែលមានក្នុងរចនាសម្ព័ន្ធបច្ចុប្បន្ន និងរចនាសម្ព័ន្ធថ្មី ដែលបានកំណត់តាមស្មារតីអនុក្រឹត្យ និងប្រកាសរបស់ក្រសួងមហាផ្ទៃ ដើម្បីពិនិត្យ ពិចារណារៀបចំធ្វើសមាហរណកម្មអង្គភាព និងការិយាល័យទាំងនោះ ទៅក្នុងរចនាសម្ព័ន្ធទីចាត់ការ និងការិយាល័យថ្មី ដូចតទៅ :

ក.១-ខុទ្ទកាល័យសាលាខេត្ត

ខុទ្ទកាល័យសាលាខេត្តបច្ចុប្បន្ន ត្រូវបានធ្វើសមាហរណកម្មទៅក្នុងទីចាត់ការរដ្ឋបាលនៃរចនាសម្ព័ន្ធថ្មី ។ ជាគោលការណ៍រួម នាយខុទ្ទកាល័យសាលាខេត្ត អាចត្រូវបានរៀបចំមុខតំណែងជានាយករដ្ឋបាលសាលាខេត្ត លើកលែងតែមានការវាយតំលៃថា សាមីខ្លួនមិនមានសមត្ថភាព មិនមានបទពិសោធន៍ និងមិនមានលក្ខណសម្បត្តិគ្រប់គ្រាន់សម្រាប់កាន់មុខតំណែងនេះ ។ នាយរងខុទ្ទកាល័យសាលាខេត្ត អាចត្រូវបានរៀបចំសម្រាប់មុខតំណែងជានាយករងរដ្ឋបាលសាលាខេត្ត ឬនាយកទីចាត់ការរដ្ឋបាល ។

ការិយាល័យនានាចំណុះខុទ្ទកាល័យសាលាខេត្ត ដែលនឹងត្រូវសមាហរណកម្មទៅក្នុងទីចាត់ការរដ្ឋបាលនៃរចនាសម្ព័ន្ធថ្មី រួមមាន :

- ការិយាល័យរបៀប និងឯកសារ ទៅក្នុងការិយាល័យរបៀប និងឯកសារ
- ការិយាល័យសរុបនិងការិយាល័យសារព័ត៌មាន ទៅក្នុងការិយាល័យសរុប និងព័ត៌មាន
- ការិយាល័យទំនាក់ទំនងសាធារណៈ និងសហប្រតិបត្តិការអន្តរជាតិ ទៅក្នុងការិយាល័យទំនាក់ទំនងសាធារណៈ និងសហប្រតិបត្តិការអន្តរជាតិ
- ការិយាល័យស្ថិតិ និងអគ្រានុកូលដ្ឋាន ទៅក្នុងការិយាល័យស្ថិតិ និងអគ្រានុកូលដ្ឋាន ។

ដោយឡែក**ការិយាល័យបុគ្គលិក** នឹងត្រូវសមារណកម្មទៅក្នុង**ទីចាត់ការគ្រប់គ្រងធនធានមនុស្ស** ហើយ**ការិយាល័យសង្គមកិច្ច** នឹងត្រូវធ្វើសមាហរណកម្មទៅក្នុង **ការិយាល័យកិច្ចការសេដ្ឋកិច្ច និងសង្គមកិច្ច** នៃ **ទីចាត់ការអន្តរវិស័យ** ក្នុងរចនាសម្ព័ន្ធថ្មី ។

ក.២-អគ្គលេខាធិការដ្ឋានសាលាខេត្ត

អគ្គលេខាធិការដ្ឋានសាលាខេត្តបច្ចុប្បន្ន ត្រូវបានធ្វើសមាហរណកម្មទៅក្នុងទីចាត់ការអន្តរវិស័យ នៃរចនាសម្ព័ន្ធថ្មី ។ ដូចនេះ អគ្គលេខាធិការ និងអគ្គលេខាធិការរងសាលាខេត្ត អាចត្រូវបានរៀបចំមុខតំណែងជានាយកទីចាត់ការ និងនាយករងទីចាត់ការអន្តរវិស័យ ។

ការិយាល័យចំណុះអគ្គលេខាធិការដ្ឋានសាលាខេត្ត នឹងត្រូវធ្វើសមាហរណកម្មទៅក្នុងការិយាល័យនីមួយៗនៃទីចាត់ការអន្តរវិស័យ ដូចខាងក្រោម :

- ការិយាល័យកិច្ចការសុរិយោដី ទៅក្នុងការិយាល័យគ្រប់គ្រងការអភិវឌ្ឍ និងសំណង់
- ការិយាល័យកិច្ចការសេដ្ឋកិច្ច ទៅក្នុងការិយាល័យកិច្ចការសេដ្ឋកិច្ច និងសង្គមកិច្ច
- ការិយាល័យកិច្ចការតុលាការ និងពន្ធនាគារ និងការិយាល័យកិច្ចការនយោបាយ រួមទាំងភារកិច្ចនានានៃក្រុមអធិការកិច្ច ទៅក្នុងការិយាល័យកិច្ចការច្បាប់ និងសុវត្ថិភាពសាធារណៈ ។

ក.៣-ក្រុមហិរញ្ញវត្ថុសាលាខេត្ត

ក្រុមហិរញ្ញវត្ថុសាលាខេត្តបច្ចុប្បន្ន ត្រូវបានធ្វើសមាហរណកម្មទៅក្នុងទីចាត់ការហិរញ្ញវត្ថុ នៃរចនាសម្ព័ន្ធថ្មី។ ដូចនេះ នាយក្រុមហិរញ្ញវត្ថុ និងនាយរងក្រុមហិរញ្ញវត្ថុសាលាខេត្ត អាចត្រូវបានរៀបចំមុខតំណែងជា នាយកទីចាត់ការ និងនាយករងទីចាត់ការហិរញ្ញវត្ថុ។

ការិយាល័យចំណុះក្រុមហិរញ្ញវត្ថុសាលាខេត្ត នឹងត្រូវធ្វើសមាហរណកម្មទៅក្នុងការិយាល័យនីមួយៗ នៃទីចាត់ការហិរញ្ញវត្ថុ ដូចខាងក្រោម :

- ការិយាល័យចំណូល និង ការិយាល័យចំណាយ ទៅក្នុងការិយាល័យហិរញ្ញកិច្ច
- ការិយាល័យគណនេយ្យ ទៅក្នុងការិយាល័យគណនេយ្យ ។

ក.៤-អង្គភាពរដ្ឋបាលមូលដ្ឋានខេត្ត

អង្គភាពរដ្ឋបាលមូលដ្ឋានខេត្ត អាចត្រូវបានធ្វើសមាហរណកម្មទៅក្នុងទីចាត់ការផែនការ និងវិនិយោគ នៃរចនាសម្ព័ន្ធថ្មី ។ ដូចនេះ ប្រធាន និងអនុប្រធានអង្គភាពរដ្ឋបាលមូលដ្ឋាន អាចត្រូវបានរៀបចំមុខតំណែងជានាយក និងនាយករងទីចាត់ការផែនការ និងវិនិយោគ ។

ការិយាល័យចំណុះអង្គភាពរដ្ឋបាលមូលដ្ឋានខេត្ត នឹងត្រូវសមាហរណកម្មទៅក្នុងការិយាល័យនីមួយៗ នៃទីចាត់ការផែនការ និងវិនិយោគ ដូចខាងក្រោម :

- ការិយាល័យផែនការ ទិន្នន័យ និងហិរញ្ញវត្ថុ ទៅក្នុងការិយាល័យផែនការ
- ការិយាល័យរដ្ឋបាល តាមដាន ត្រួតពិនិត្យ និងអន្តរាគមន៍ ទៅក្នុងការិយាល័យគាំទ្រមូលដ្ឋាន

ដោយឡែកការិយាល័យបណ្តុះបណ្តាល អប់រំ និងកសាងសមត្ថភាព អាចធ្វើសមាហរណកម្មទៅក្នុងការិយាល័យកសាងសមត្ថភាព នៃទីចាត់ការគ្រប់គ្រងធនធានមនុស្ស ។

ក.៥-ក្រុមអធិការកិច្ចសាលាខេត្ត

ផ្អែកតាមតួនាទី និងភារកិច្ចរបស់ទីចាត់ការអន្តរវិស័យនៃរចនាសម្ព័ន្ធថ្មី ក្រុមអធិការកិច្ចសាលាខេត្តនីមួយៗ ត្រូវធ្វើសមាហរណកម្មទៅក្នុងទីចាត់ការនោះ ពិសេសការិយាល័យកិច្ចការច្បាប់ និងសុវត្ថិភាពសាធារណៈ ។

ខ. សម្រាប់សាលារាជធានីភ្នំពេញ

ដោយផ្អែកតាមរចនាសម្ព័ន្ធជាក់ស្តែងនាពេលបច្ចុប្បន្នរបស់សាលារាជធានីភ្នំពេញ ការរៀបចំផ្ទេរបញ្ចូលទៅក្នុងរចនាសម្ព័ន្ធថ្មី រាជធានីភ្នំពេញ ត្រូវសិក្សាទៅលើតួនាទី ភារកិច្ចរបស់អង្គភាព និងការិយាល័យនីមួយៗ ដើម្បីផ្ទេរទៅក្នុងទីចាត់ការ ឬ ការិយាល័យសមស្របណាមួយនៃរចនាសម្ព័ន្ធថ្មី ដូចខាងក្រោម :

ខ.១-ខុទ្ទកាល័យសាលារាជធានី

ការិយាល័យចំណុះខុទ្ទកាល័យសាលារាជធានី ដែលនឹងត្រូវសមាហរណកម្មទៅក្នុងទីចាត់ការនីមួយៗ នៃរចនាសម្ព័ន្ធថ្មី រួមមាន :

- ការិយាល័យរដ្ឋបាល ទៅក្នុងការិយាល័យរបៀប និងឯកសារ នៃទីចាត់ការរដ្ឋបាល
- ការិយាល័យសរុប ទៅក្នុងការិយាល័យសរុប និងព័ត៌មាន នៃទីចាត់ការរដ្ឋបាល
- ការិយាល័យទំនាក់ទំនងសាធារណៈ និងការិយាល័យពិធីការ ទៅក្នុងការិយាល័យទំនាក់ទំនងសាធារណៈ និងសហប្រតិបត្តិការអន្តរជាតិ នៃទីចាត់ការរដ្ឋបាល
- ការិយាល័យអគ្រានុកូលដ្ឋាន ទៅក្នុងការិយាល័យស្ថិតិ និងអគ្រានុកូលដ្ឋាននៃទីចាត់ការរដ្ឋបាល
- ការិយាល័យគណនេយ្យ ទៅក្នុងទីចាត់ការហិរញ្ញវត្ថុ
- ការិយាល័យវិនិយោគ ទៅក្នុងទីចាត់ការផែនការ និងវិនិយោគ
- ការិយាល័យផ្សព្វផ្សាយពាណិជ្ជកម្ម ទៅក្នុងការិយាល័យផ្សព្វផ្សាយពាណិជ្ជកម្ម នៃទីចាត់ការអន្តរវិស័យ
- ការិយាល័យកិច្ចការនគរូបនីយកម្ម ទៅក្នុងទីចាត់ការរៀបចំក្រុង
- ការិយាល័យបុគ្គលិក ទៅក្នុងទីចាត់ការគ្រប់គ្រងធនធានមនុស្ស
- ការិយាល័យអធិការកិច្ច ទៅក្នុងការិយាល័យកិច្ចការច្បាប់ និងការដោះស្រាយវិវាទនៅមូលដ្ឋាន ។

ខ.២-អង្គភាពរដ្ឋបាលមូលដ្ឋានរាជធានី

អង្គភាពរដ្ឋបាលមូលដ្ឋានរាជធានី អាចត្រូវបានធ្វើសមាហរណកម្មទៅក្នុងទីចាត់ការផែនការ និងវិនិយោគនៃរចនាសម្ព័ន្ធថ្មី ។ ដូចនេះ ប្រធាន និងអនុប្រធានអង្គភាពរដ្ឋបាលមូលដ្ឋាន អាចត្រូវបានរៀបចំមុខតំណែងជានាយក និងនាយករងទីចាត់ការផែនការ និងវិនិយោគ ។

ការិយាល័យចំណុះអង្គភាពរដ្ឋបាលមូលដ្ឋានរាជធានី នឹងត្រូវសមាហរណកម្មទៅក្នុងការិយាល័យនីមួយៗនៃទីចាត់ការផែនការ និងវិនិយោគ ដូចខាងក្រោម :

- ការិយាល័យផែនការ ទិន្នន័យ និងហិរញ្ញវត្ថុ ទៅក្នុងការិយាល័យផែនការ
- ការិយាល័យរដ្ឋបាល តាមដាន ត្រួតពិនិត្យ និងអន្តរាគមន៍ ទៅក្នុងការិយាល័យគាំទ្រមូលដ្ឋាន

ដោយឡែកការិយាល័យបណ្តុះបណ្តាល អប់រំ និងកសាងសមត្ថភាព អាចធ្វើសមាហរណកម្មទៅក្នុងការិយាល័យកសាងសមត្ថភាព នៃទីចាត់ការគ្រប់គ្រងធនធានមនុស្ស ។

គ.សម្រាប់សាលាក្រុង ស្រុក ខណ្ឌ

ក្រុង ស្រុក ខណ្ឌ ត្រូវពិនិត្យ សិក្សារៀបចំផ្ទេរការិយាល័យដែលមានក្នុងរចនាសម្ព័ន្ធចាស់ទៅក្នុងរចនាសម្ព័ន្ធថ្មីដែលបានកំណត់តាមស្មារតីប្រកាសក្រសួងមហាផ្ទៃ ស្តីពីការបង្កើតការិយាល័យចំណុះទីចាត់ការនៃសាលារាជធានីភ្នំពេញ ការបង្កើតការិយាល័យនៃសាលាខណ្ឌ និងការកំណត់តួនាទី ភារកិច្ច របៀបរបបការងារនៃការិយាល័យ

ទាំងនោះ ឬប្រកាស ស្តីពីការបង្កើតការិយាល័យចំណុះទីចាត់ការនៃសាលាខេត្ត ការបង្កើតការិយាល័យ នៃសាលាក្រុង ការបង្កើតការិយាល័យនៃសាលាស្រុក និងការកំណត់តួនាទី ភារកិច្ច របៀបរបបការងារនៃការិយាល័យទាំងនោះ ។ ការពិនិត្យ ពិចារណារៀបចំធ្វើសមាហរណកម្មការិយាល័យ និងមន្ត្រីរាជការ ត្រូវឈរលើមូលដ្ឋាននៃឧបនិស្ស័យ និងភារកិច្ចកំពុងអនុវត្តជាក់ស្តែងរបស់មន្ត្រីម្នាក់ៗ ទៅនឹងរចនាសម្ព័ន្ធ តួនាទី ភារកិច្ចរបស់ការិយាល័យនីមួយៗ ដូចតទៅ :

ល.រ	រចនាសម្ព័ន្ធសាលាក្រុង ស្រុក ខណ្ឌបច្ចុប្បន្ន	ផ្ទេរទៅក្នុងរចនាសម្ព័ន្ធថ្មី
១-	ការិយាល័យរដ្ឋបាលទូទៅ	ការិយាល័យរដ្ឋបាល និងហិរញ្ញវត្ថុ
២-	ការិយាល័យសេដ្ឋកិច្ច ការិយាល័យសង្គមកិច្ច	ការិយាល័យអភិវឌ្ឍក្រុង ឬការិយាល័យអន្តរវិស័យ

២.ការរៀបចំ និងតែងតាំងមន្ត្រីរាជការក្នុងរចនាសម្ព័ន្ធថ្មី

ក.សាលាខេត្ត

ផ្អែកតាមរចនាសម្ព័ន្ធថ្មី ទីចាត់ការ និងការិយាល័យបង្កើតថ្មី នៅតាមសាលាខេត្តនីមួយៗ ហើយដែលមិនមានក្នុងរចនាសម្ព័ន្ធបច្ចុប្បន្នរួមមាន :

១- ការិយាល័យលេខាធិការក្រុមប្រឹក្សា នៃទីចាត់ការរដ្ឋបាល

២- ការិយាល័យលទ្ធកម្ម ការិយាល័យគ្រប់គ្រងទ្រព្យសម្បត្តិ នៃទីចាត់ការហិរញ្ញវត្ថុ

៣- ការិយាល័យវិនិយោគ នៃទីចាត់ការផែនការ និងវិនិយោគ ។

ការិយាល័យខាងលើនេះ ត្រូវពិចារណាចំពោះប្រធាន ឬអនុប្រធានការិយាល័យ ឬមន្ត្រីដែលទទួលបន្ទុកការងារទាំងនេះ ឬមន្ត្រីដែលកំពុងអនុវត្តការងារទាំងនេះ។ ក្នុងករណីដែលមិនមានអ្នកទទួលបន្ទុក ឬអ្នកកំពុងអនុវត្តការងារទាំងនេះ ត្រូវពិចារណាជ្រើសយកប្រធាន អនុប្រធានការិយាល័យដែលមានស្រាប់ និងមន្ត្រីដែលមានសមត្ថភាព ឬបទពិសោធន៍ការងារទាំងនេះ ដើម្បីធ្វើសមាហរណកម្មទៅក្នុងរចនាសម្ព័ន្ធដែលបានបង្កើតថ្មីទាំងនេះ ។

ខ.សាលារាជធានីភ្នំពេញ

ផ្អែកតាមរចនាសម្ព័ន្ធថ្មី ទីចាត់ការ និងការិយាល័យដែលបង្កើតថ្មី នៅសាលារាជធានីភ្នំពេញ ហើយដែលមិនមានក្នុងរចនាសម្ព័ន្ធបច្ចុប្បន្នរួមមាន :

១- ទីចាត់ការរដ្ឋបាល រួមមាន ការិយាល័យលេខាធិការក្រុមប្រឹក្សា

២- ទីចាត់ការផែនការ និងវិនិយោគ រួមមាន ការិយាល័យអភិវឌ្ឍសហគមន៍អ្នកក្រីក្រ

៣- ទីចាត់ការហិរញ្ញវត្ថុ រួមមាន ការិយាល័យលទ្ធកម្ម និងការិយាល័យគ្រប់គ្រងទ្រព្យសម្បត្តិ

៤- ទីចាត់ការរៀបចំក្រុង រួមមាន ការិយាល័យនគរូបនីយកម្ម និងការិយាល័យគ្រប់គ្រងការអភិវឌ្ឍ និងសំណង់

៥- ទីចាត់ការអន្តរវិស័យ រួមមាន ការិយាល័យសេដ្ឋកិច្ច និងសង្គមកិច្ច

៦- ទីចាត់ការកិច្ចការច្បាប់ និងសិទ្ធិមនុស្ស រួមមាន ការិយាល័យសុវត្ថិភាពសាធារណៈ

៧- ទីចាត់ការគ្រប់គ្រងកាកសំណល់ រួមមាន ការិយាល័យបច្ចេកទេសនិងត្រួតពិនិត្យផលប៉ះពាល់បរិស្ថាន និងការិយាល័យរដ្ឋាករគ្រប់គ្រងកាកសំណល់ ។

ការិយាល័យខាងលើនេះ ត្រូវពិចារណាចំពោះប្រធាន ឬអនុប្រធានការិយាល័យ ឬមន្ត្រីដែលទទួលបន្ទុកការងារទាំងនេះ ឬមន្ត្រីដែលកំពុងអនុវត្តការងារទាំងនេះ។ ក្នុងករណីដែលមិនមានអ្នកទទួលបន្ទុក ឬអ្នកកំពុងអនុវត្តការងារទាំងនេះ ត្រូវពិចារណាជ្រើសយកប្រធាន អនុប្រធានការិយាល័យដែលមានស្រាប់ និងមន្ត្រីដែលមានសមត្ថភាព ឬបទពិសោធន៍ការងារទាំងនេះ ដើម្បីធ្វើសមាហរណកម្មទៅក្នុងរចនាសម្ព័ន្ធដែលបានបង្កើតថ្មីទាំងនេះ ។

គ.សាលាក្រុង ស្រុក ខណ្ឌ

ការិយាល័យដែលបង្កើតថ្មីនៅក្នុងរចនាសម្ព័ន្ធសាលាក្រុង ស្រុក ខណ្ឌ ហើយដែលមិនមានរចនាសម្ព័ន្ធបច្ចុប្បន្ន រួមមាន :

១- ការិយាល័យផែនការ និងអភិវឌ្ឍ របស់សាលាខណ្ឌនីមួយៗនៃរាជធានីភ្នំពេញ

២- ការិយាល័យផែនការ និងគាំទ្រសង្កាត់ របស់សាលាក្រុងនីមួយៗ

៣- ការិយាល័យផែនការ និងគាំទ្រឃុំ សង្កាត់របស់សាលាស្រុកនីមួយៗ ។

ការិយាល័យខាងលើនេះ ត្រូវពិចារណាចំពោះប្រធាន ឬអនុប្រធានការិយាល័យ ឬមន្ត្រីដែលទទួលបន្ទុកការងារទាំងនេះ ឬមន្ត្រីដែលកំពុងអនុវត្តការងារទាំងនេះ។ ក្នុងករណីដែលមិនមានអ្នកទទួលបន្ទុក ឬអ្នកកំពុងអនុវត្តការងារទាំងនេះ ត្រូវពិចារណាជ្រើសយកប្រធាន អនុប្រធានការិយាល័យដែលមានស្រាប់ និងមន្ត្រីដែលមានសមត្ថភាព ឬបទពិសោធន៍ការងារទាំងនេះ ដើម្បីធ្វើសមាហរណកម្មទៅក្នុងរចនាសម្ព័ន្ធដែលបានបង្កើតថ្មីទាំងនេះ ។

ឃ.ការរៀបចំមន្ត្រីរាជការនៅក្នុងរចនាសម្ព័ន្ធថ្មី

ការរៀបចំធ្វើសមាហរណកម្មមន្ត្រីរាជការទៅក្នុងទីចាត់ការ និងការិយាល័យបង្កើតថ្មីខាងលើ រាជធានី ខេត្តនីមួយៗ ត្រូវខិតខំពិនិត្យទៅលើជំនាញ បទពិសោធន៍ជាក់ស្តែងរបស់មន្ត្រីរាជការម្នាក់ៗ ក៏ដូចជាភារកិច្ចដែលមន្ត្រីម្នាក់ៗកំពុងទទួលខុសត្រូវ ដើម្បីធ្វើសមាហរណកម្មឱ្យបានស្របទៅតាមតួនាទីរបស់ទីចាត់ការ និងការិយាល័យដែលមានក្នុងរចនាសម្ព័ន្ធថ្មីរបស់រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ សំដៅធានានិរន្តរភាពការងារ និងការលើកកម្ពស់ប្រសិទ្ធភាពនៃកិច្ចដំណើរការការងារក្នុងរចនាសម្ព័ន្ធថ្មី ។

ជាគោលការណ៍រួម ប្រធានមន្ទីរក្រុង ស្រុក ខណ្ឌបច្ចុប្បន្ន នឹងអាចត្រូវបានរៀបចំមុខតំណែងជានាយករដ្ឋបាលសាលាក្រុង ស្រុក ខណ្ឌ លើកលែងតែមានការវាយតំលៃថា សាមីខ្លួនមិនមានសមត្ថភាព មិនមានបទពិសោធន៍ និងមិនមានលក្ខណសម្បត្តិគ្រប់គ្រាន់សម្រាប់កាន់មុខតំណែងនេះ ។ អនុប្រធានមន្ទីរក្រុង ស្រុក ខណ្ឌ អាចត្រូវបានរៀបចំសម្រាប់មុខតំណែងជា នាយករងរដ្ឋបាលសាលាក្រុង ស្រុក ខណ្ឌ ។

សម្រាប់ការិយាល័យនៃសាលាក្រុង ស្រុក ខណ្ឌនីមួយៗ ត្រូវខិតខំពិនិត្យលទ្ធភាពជ្រើសរើស និង សមាហរណកម្មមន្ត្រីដែលធ្លាប់បំពេញភារកិច្ចជាមន្ត្រីសម្របសម្រួលថ្នាក់ក្រុង ស្រុក ខណ្ឌ ដែលគាំទ្រដល់ឃុំ សង្កាត់ ទៅក្នុងការិយាល័យផែនការ និងអភិវឌ្ឍ (សម្រាប់ខណ្ឌនៃរាជធានីភ្នំពេញ) ឬការិយាល័យផែនការ និង គាំទ្រ សង្កាត់ របស់សាលាក្រុង ឬការិយាល័យផែនការ និងគាំទ្រឃុំ សង្កាត់របស់សាលាស្រុកនីមួយៗ ។

ចំពោះមន្ត្រីរាជការដែលកំពុងបម្រើការងារនៅតាមមន្ទីរក្រុង ស្រុក ខណ្ឌនានា ត្រូវធ្វើសមាហរណកម្មមន្ត្រី ទាំងនោះ ទៅក្នុងការិយាល័យរដ្ឋបាល និងហិរញ្ញវត្ថុក្រុង ស្រុក ខណ្ឌនៃរចនាសម្ព័ន្ធថ្មី ។ ក្រុង ស្រុក ខណ្ឌនីមួយៗ ត្រូវខិតខំពិនិត្យលទ្ធភាពជ្រើសរើសស្មៀនឃុំ សង្កាត់ដែលមានជំនាញ បទពិសោធន៍ សមត្ថភាពរីកចំរើន និងមាន អតីតភាពការងារច្រើនឆ្នាំនៅតាមឃុំ សង្កាត់ ដើម្បីមកបំពេញការងារនៅក្នុងរចនាសម្ព័ន្ធថ្មីនៃសាលាក្រុង ស្រុក ខណ្ឌ ឬអាចពិចារណាស្នើតែងតាំងមុខតំណែងជាប្រធាន និង អនុប្រធានការិយាល័យនៃរចនាសម្ព័ន្ធថ្មីរបស់ក្រុង ស្រុក ខណ្ឌ ក្នុងករណីដែលក្រុង ស្រុក ខណ្ឌ ខ្វះធនធានមនុស្ស និងមិនបណ្តាលឱ្យប៉ះពាល់ដល់និរន្តរភាពកិច្ចការរដ្ឋបាល របស់ឃុំ សង្កាត់។ ទន្ទឹមនោះ ដើម្បីធានានិរន្តរភាពការងារនៅតាមរដ្ឋបាលឃុំ សង្កាត់ ក្រុង ស្រុក ខណ្ឌត្រូវពិគ្រោះ ពិភាក្សាជាមួយឃុំ សង្កាត់ ដើម្បីចាត់មន្ត្រីរាជការស្ថិតក្នុងក្របខ័ណ្ឌលេខាធិការរដ្ឋបាល ដែលកំពុងបំពេញការងារ នៅសាលាក្រុង ស្រុក ខណ្ឌ ដែលទទួលបានការបណ្តុះបណ្តាលនាពេលកន្លងមក ឱ្យទៅបំពេញភារកិច្ចជាស្មៀនឃុំ សង្កាត់បន្តជំនួសវិញ ។

ជាគោលការណ៍ រាជធានី ខេត្តនីមួយៗត្រូវរៀបចំផ្ទេរ និងធ្វើសមាហរណកម្មពីរចនាសម្ព័ន្ធបច្ចុប្បន្នទៅក្នុង រចនាសម្ព័ន្ធថ្មី ដោយខិតខំប្រើប្រាស់មន្ត្រីរាជការដែលកំពុងបម្រើការងារ ឬមន្ត្រីដែលមានស្រាប់ ដោយពុំត្រូវជ្រើស រើសមន្ត្រីថ្មីបន្ថែម ដែលនាំឱ្យប៉ោងក្របខ័ណ្ឌមន្ត្រី និងធ្វើឱ្យប៉ះពាល់ដល់គោលនយោបាយរបស់រាជរដ្ឋាភិបាល ។

ការរៀបចំធ្វើសមាហរណកម្ម និងតែងតាំងមន្ត្រីរាជការ ដែលកំពុងបម្រើការងារក្នុងរចនាសម្ព័ន្ធបច្ចុប្បន្ន ទៅក្នុងរចនាសម្ព័ន្ធថ្មីក្នុងសាលារាជធានី ខេត្ត ឬសាលាក្រុង ស្រុក ខណ្ឌនីមួយៗ ត្រូវដំណើរការរៀបចំព្រមគ្នានៅ តាមអង្គភាពនីមួយៗ សម្រាប់មុខតំណែងនាយករដ្ឋបាល នាយករងរដ្ឋបាល នាយក នាយករងទីចាត់ការ ប្រធាន និងអនុប្រធានការិយាល័យ ចំណុះសាលារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ។

ចំពោះការរៀបចំធ្វើសមាហរណកម្មខាងលើនេះ រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌនីមួយៗត្រូវគោរពឱ្យបាន នូវគោលការណ៍ជាមូលដ្ឋានដូចបានកំណត់នៅក្នុង**ចំណុច I** ខាងលើ ។

៦.អំពីមុខតំណែងដែលនៅទំនេរក្នុងរចនាសម្ព័ន្ធថ្មី

ក្នុងដំណើរការនៃការធ្វើសមាហរណកម្ម និងតែងតាំងមន្ត្រីរាជការនៅតាមសាលារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ចំពោះមុខតំណែងអង្គភាពណាដែលមានប្រធាន និងអនុប្រធានម្នាក់រួចហើយ ប៉ុន្តែនៅមានមុខតំណែង អនុប្រធានដែលនៅទំនេរ សាលារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌនីមួយៗ ត្រូវរក្សាទុកមុខតំណែងអនុប្រធានដែល នៅទំនេរនោះ ដោយពុំអនុញ្ញាតឱ្យមានការបំពេញបន្ថែមឡើយ។ ទន្ទឹមនោះ ត្រូវធ្វើរបាយការណ៍បូកសរុបអំពីមុខ តំណែងដែលនៅទំនេរនោះ មកក្រសួងមហាផ្ទៃ ដើម្បីពិនិត្យ និងមានការណែនាំជាក្រោយ ។

៣. អំពីបែបបទ នីតិវិធី និងលក្ខណសម្បត្តិនៃការតែងតាំងមន្ត្រីរាជការក្នុងរចនាសម្ព័ន្ធថ្មី

ដើម្បីឱ្យដំណើរការនៃការធ្វើសមាហរណកម្មនេះ ប្រព្រឹត្តទៅមានតម្លាភាពស្របតាមគោលការណ៍ ដែលបានកំណត់ក្នុងសេចក្តីណែនាំនេះ អង្គភាព ឬមន្ត្រីទទួលការងារបុគ្គលិក នៃសាលារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ត្រូវធ្វើជាសេនាធិការជូនគណៈអភិបាលរបស់ខ្លួន ធ្វើការផ្ទៀងផ្ទាត់ និង រៀបចំបញ្ជីស្នើសុំតែងតាំងមុខតំណែងមន្ត្រីរាជការនៅក្នុងរចនាសម្ព័ន្ធសាលារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ។ បញ្ជីផ្ទៀងផ្ទាត់នេះ បន្ទាប់ពីមានការឯកភាពពីអភិបាល ត្រូវដាក់ជូនកិច្ចប្រជុំគណៈអភិបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ដោយមានកំណត់ហេតុប្រជុំឱ្យបានច្បាស់លាស់។ សំណើរៀបចំសមាហរណកម្មនេះ ត្រូវភ្ជាប់មកជាមួយឯកសារដូចខាងក្រោម :

- តារាងគំរូ "**ក**"
- តារាងគំរូ "**ខ**"
- ប្រវត្តិរូបសង្ខេបរបស់សាមីខ្លួន
- កំណត់ហេតុប្រជុំគណៈអភិបាល ។

ចំពោះក្រុង ស្រុក ខណ្ឌ ត្រូវអនុវត្តតាមនីតិវិធីដូចបានណែនាំនេះដែរ ។ សំណើរៀបចំសមាហរណកម្មសំរាប់ថ្នាក់ក្រុង ស្រុក ខណ្ឌ ត្រូវភ្ជាប់មកជាមួយឯកសារ ដូចបានណែនាំខាងលើ ។ សំណើនេះ ត្រូវដាក់ជូនថ្នាក់រាជធានី ខេត្ត ពិនិត្យ ដើម្បីរៀបចំសំណើមកក្រសួងមហាផ្ទៃ ។ សំណើធ្វើសមាហរណកម្មមន្ត្រីនៅថ្នាក់ក្រុង ស្រុក ខណ្ឌ ត្រូវភ្ជាប់មកជាមួយនូវសំណើរបស់អភិបាលក្រុង ស្រុក ខណ្ឌ តារាង**ក** តារាង**ខ** និងកំណត់ហេតុប្រជុំគណៈអភិបាល ។

ផ្អែកលើសំណើរបស់រាជធានី និងខេត្តនីមួយៗ អគ្គនាយកដ្ឋានរដ្ឋបាលមូលដ្ឋាន មានភារកិច្ចរៀបចំកម្មវិធីលំអិតជាក់ស្តែង និងធ្វើការសម្របសម្រួល ដើម្បីពិនិត្យ ពិភាក្សាជាក់ស្តែងជាមួយអភិបាលរាជធានី ខេត្ត សំដៅធានាឱ្យបាននូវគោលការណ៍ជាមូលដ្ឋាន ដូចបានកំណត់នៅក្នុង**ចំណុច I** ខាងលើ ។

ដោយឡែកចំពោះការរៀបចំមុខតំណែង**នាយករដ្ឋបាល**សាលារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ក្រសួងមហាផ្ទៃ នឹងពិនិត្យ សម្រេចទៅលើសំណើរបស់រាជធានី ខេត្ត ដែលបានស្នើរៀបចំកាលពី**ខែ ឧសភា ឆ្នាំ២០០៩** កន្លងមក លើកលែងតែខេត្តមួយចំនួន ដែលក្រសួងនឹងធ្វើការពិនិត្យ និងវាយតំលៃឡើងវិញ សម្រាប់មុខតំណែង**នាយករដ្ឋបាលខេត្ត** ។

នៅពេលមិនទាន់មានលក្ខន្តិកៈដោយឡែកសម្រាប់បុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិ លក្ខណសម្បត្តិនៃការតែងតាំងមន្ត្រីរាជការត្រូវបានកំណត់ដូចខាងក្រោម :

- មានបទពិសោធន៍ សមត្ថភាព និងចំណេះដឹង
- មានគំនិតផ្តួចផ្តើមក្នុងការងារ
- មានគុណធម៌ សីលធម៌ និង មនសិការវិជ្ជាជីវៈ
- មានសាមគ្គីភាពល្អ និងមានស្មារតីទទួលខុសត្រូវក្នុងការងារ
- មានសុខភាពល្អ ។

ឋានន្តរសក្តិរបស់មន្ត្រីរាជការ ដែលមានឧបនិស្ស័យសម្រាប់តែងតាំងមុខតំណែងនីមួយៗ ស្ថិតក្នុងរចនាសម្ព័ន្ធសាលារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ត្រូវកំណត់ដូចខាងក្រោម :

- **សាលារាជធានី ខេត្ត**
  - នាយករដ្ឋបាលសាលារាជធានី ខេត្ត មានឋានន្តរសក្តិចាប់ពី អនុមន្ត្រី
  - នាយករងរដ្ឋបាលសាលារាជធានី ខេត្ត មានឋានន្តរសក្តិចាប់ពី នាយក្រមការ
  - នាយកទីចាត់ការ មានឋានន្តរសក្តិចាប់ពី នាយក្រមការ
  - នាយករងទីចាត់ការ មានឋានន្តរសក្តិចាប់ពី ក្រមការដើមខ្សែ
  - ប្រធានការិយាល័យ មានឋានន្តរសក្តិចាប់ពី ក្រមការដើមខ្សែ
  - អនុប្រធានការិយាល័យ មានឋានន្តរសក្តិចាប់ពី ក្រមការ ។

- **សាលាក្រុង ស្រុក ខណ្ឌ**
  - នាយករដ្ឋបាលសាលាក្រុង ស្រុក ខណ្ឌ មានឋានន្តរសក្តិចាប់ពី ក្រមការដើមខ្សែ
  - នាយករងរដ្ឋបាលសាលាក្រុង ស្រុក ខណ្ឌ មានឋានន្តរសក្តិចាប់ពី ក្រមការ
  - ប្រធានការិយាល័យ មានឋានន្តរសក្តិចាប់ពី ក្រមការ
  - អនុប្រធានការិយាល័យ មានឋានន្តរសក្តិចាប់ពី នាយលេខាធិការរដ្ឋបាល ។

ចំពោះការធ្វើសមាហរណកម្ម និងការរៀបចំតែងតាំងមុខតំណែងមន្ត្រីរាជការនៅក្នុងរចនាសម្ព័ន្ធសាលារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌថ្មី ចាំបាច់ត្រូវអនុវត្តឱ្យបានស្របទៅតាមលក្ខណសម្បត្តិ ឧបនិស្ស័យ និងឋានន្តរសក្តិសម្រាប់មុខតំណែងនីមួយៗ ។ ការរៀបចំមុខតំណែងនេះ មិនតម្រូវឱ្យមានការប្រែប្រួលស្ថានភាពបៀវត្សរបស់មន្ត្រីរាជការម្នាក់ៗដែលរៀបចំមុខតំណែងឡើយ ពោលគឺរក្សាស្ថានភាពបៀវត្សចាស់របស់មន្ត្រី ដោយមិនធ្វើការកែសម្រួលបៀវត្សមូលដ្ឋាន និងប្រាក់បន្ទាប់បន្សំនៃបៀវត្សរបស់សាមីខ្លួន ។ ការកែសម្រួលប្រាក់បៀវត្សរបស់មន្ត្រីរាជការម្នាក់ៗ ត្រូវរក្សាទុករហូតដល់ឆ្នាំ២០១១ ឬរហូតដល់មានការសម្រេចជាថ្មីពីរាជរដ្ឋាភិបាល ។ ទន្ទឹមនោះការរៀបចំកែសម្រួលបៀវត្សជាថ្មីឡើងវិញ មិនតម្រូវឱ្យ មានការរំលឹកប្រាក់បៀវត្សជូនសាមីខ្លួនឡើយ ។

ដោយឡែក ចំពោះការរៀបចំប្រាក់បំណាច់មុខងារសម្រាប់មុខតំណែងនាយករដ្ឋបាលសាលារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌនោះ ក៏មិនត្រូវបានរៀបចំកែសម្រួលជូនឡើយ។ លើមូលដ្ឋាននេះ មន្ត្រីរាជការដែលរៀបចំមុខតំណែងជានាយករដ្ឋបាល ត្រូវទទួលបានប្រាក់បំណាច់មុខងារដែលខ្លួនមានពីមុនមក ។ ការរៀបចំកែសម្រួលឡើងវិញ នូវប្រាក់បំណាច់មុខងាររបស់នាយករដ្ឋបាលសាលារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ គឺត្រូវអនុវត្តដូចគោលការណ៍ខាងលើ ដោយត្រូវរក្សាស្ថានភាពរហូតដល់ឆ្នាំ២០១១ ឬរហូតដល់រាជរដ្ឋាភិបាលសម្រេចជាថ្មី ។

III. អំពីកិច្ចការសំខាន់ៗ ក្នុងដំណើរការអនុវត្តសេចក្តីណែនាំ

ដើម្បីគាំទ្រ និងអនុវត្តនូវដំណើរការសមាហរណកម្មមន្ត្រីរាជការទៅក្នុងរចនាសម្ព័ន្ធថ្មី ទទួលបានជោគជ័យ និងមានលទ្ធផលល្អប្រសើរ រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌនីមួយៗ ត្រូវយកចិត្តទុកដាក់អនុវត្តនូវកិច្ចការចាំបាច់មួយចំនួន ដូចតទៅ :

- ធ្វើបច្ចុប្បន្នភាពមន្ត្រីរាជការ តាមរយៈការរៀបចំបញ្ជីរាយនាមមន្ត្រីរាជការដែលកំពុងបម្រើការងារនៅក្នុងរចនាសម្ព័ន្ធបច្ចុប្បន្ន ដូចតារាងដែលបានណែនាំរៀបចំកន្លងមក (**តារាង ក**) ។
- រៀបចំបញ្ជីរាយនាមមន្ត្រីរាជការ ដើម្បីស្នើសុំធ្វើសមាហរណកម្មទៅក្នុងរចនាសម្ព័ន្ធថ្មី (**តារាង ខ**)
- ធ្វើបញ្ជីកិច្ចការលំអិតនៅតាមអង្គភាព និងការិយាល័យនីមួយៗ ដើម្បីផ្ទេរកិច្ចការទាំងនោះ ទៅឱ្យទីចាត់ការ និងការិយាល័យដែលមានការពាក់ព័ន្ធ រួមទាំងការផ្ទេរនូវឯកសារពាក់ព័ន្ធទាំងឡាយផងដែរ ។
- ចំពោះកិច្ចការណាដែលកំពុងចាត់ចែងអនុវត្ត ហើយដែលពុំទាន់បានចប់ជាស្ថាពរនោះ ត្រូវផ្ទេរការងារនោះ រួមទាំងឯកសារ លិខិតស្នាមនានា ទៅឱ្យទីចាត់ការ ឬការិយាល័យថ្មី អនុវត្តបន្ត ។
- ធ្វើបញ្ជីទ្រព្យសម្បត្តិ និងសំភារៈ ឯកសារ ដែលស្ថិតក្នុងអង្គភាពបច្ចុប្បន្ន ដើម្បីផ្ទេរទៅឱ្យអង្គភាពរចនាសម្ព័ន្ធថ្មី ចាត់ចែង និងប្រើប្រាស់បន្ត ។

- **ការរៀបចំផ្ទេរ និងសមាហរណកម្មមន្ត្រីរាជការនៅក្នុងរចនាសម្ព័ន្ធថ្មីនេះ ត្រូវធ្វើតាមដំណាក់កាលដូចខាងក្រោម :**

- រាជធានី ខេត្តត្រូវរៀបចំធ្វើសមាហរណកម្មមុន ។
- បន្ទាប់ពីរាជធានី ខេត្ត ធ្វើសំណើសមាហរណកម្មមកក្រសួងមហាផ្ទៃរួចហើយ រាជធានី ខេត្តនីមួយៗ ត្រូវបន្តគាំទ្រដល់ក្រុង ស្រុក ខណ្ឌ ក្នុងការរៀបចំធ្វើសមាហរណកម្មផ្ទេរមន្ត្រីរាជការ រួមទាំងការពិគ្រោះយោបល់ជាមួយក្រុង ស្រុក ខណ្ឌ ដើម្បីរៀបចំមុខតំណែងមន្ត្រីដែលកំពុងបម្រើការងារនៅក្នុងរចនាសម្ព័ន្ធក្រុង ស្រុក ខណ្ឌបច្ចុប្បន្ន ទៅក្នុងរចនាសម្ព័ន្ធថ្មីរបស់ក្រុង ស្រុក ខណ្ឌនីមួយៗ ស្របតាមគោលការណ៍ និងនីតិវិធី ដូចបានកំណត់ក្នុងសេចក្តីណែនាំនេះ ។
- ដោយសារដំណើរការនៃការធ្វើសមាហរណកម្មនេះ នឹងត្រូវធ្វើឡើងនៅរាជធានី និងគ្រប់ខេត្ត ក្រុង ស្រុក ខណ្ឌ ហេតុនេះ ក្រសួងមហាផ្ទៃកំណត់យក **រាជធានីភ្នំពេញ** និង **ខេត្តតាកែវ** ដើម្បីរៀបចំធ្វើសមាហរណកម្មមុន បន្ទាប់មកនឹងធ្វើនៅខេត្ត ក្រុង ស្រុក ខណ្ឌផ្សេងៗទៀត ។ ក្រសួងមហាផ្ទៃ នឹងចាត់តាំងមន្ត្រីពីអគ្គនាយកដ្ឋានរដ្ឋបាលមូលដ្ឋាន ដើម្បីជួយគាំទ្រដល់រាជធានី និងខេត្ត ក្នុងដំណើរការរៀបចំសមាហរណកម្មនេះ ។

ការណែនាំខាងលើនេះ ត្រូវបានអនុវត្តសម្រាប់ការធ្វើសមាហរណកម្ម និងតែងតាំងមុខតំណែងមន្ត្រីរាជការ ក្នុងរចនាសម្ព័ន្ធទីចាត់ការ និងការិយាល័យនានា នៃរចនាសម្ព័ន្ធថ្មីរបស់រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ដែលត្រូវបានកំណត់ដោយអនុក្រឹត្យ និងប្រកាសខាងលើ ។ ដោយឡែកចំពោះការស្នើសុំបង្កើត ឬកែសម្រួល

ឬលុបចោលទីចាត់ការឬការិយាល័យក្នុងរចនាសម្ព័ន្ធសាលារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ នឹងមានសេចក្ដីណែនាំរបស់ក្រសួងមហាផ្ទៃ ដែលកំណត់អំពីបញ្ហានេះ នៅពេលក្រោយ ។

ទទួលបានសេចក្ដីណែនាំនេះ ក្រុមប្រឹក្សា គណៈអភិបាលរាជធានី ក្រុមប្រឹក្សា គណៈអភិបាលខេត្ត ក្រុមប្រឹក្សា គណៈអភិបាលក្រុង ក្រុមប្រឹក្សា គណៈអភិបាលស្រុក ក្រុមប្រឹក្សា គណៈអភិបាលខណ្ឌ និង អង្គភាពដែលពាក់ព័ន្ធ ចំណុះទីស្ដីការក្រសួងមហាផ្ទៃ ត្រូវចាត់ចែងផ្សព្វផ្សាយ និងអនុវត្តឱ្យមានប្រសិទ្ធភាពខ្ពស់ ។

រាជធានីភ្នំពេញ ថ្ងៃទី ២១ ខែ កុម្ភៈ ឆ្នាំ២០១០

ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

ស ខេង

ចម្លងជូន :

- ទីស្ដីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ
- គ្រប់ក្រសួង ស្ថាប័ននៃរាជរដ្ឋាភិបាលកម្ពុជា
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែប
ប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ (គ.ជ.អ.ប)

លេខ ០១៧ [illegible] /គ.ជ.អ.ប

រាជធានីភ្នំពេញ, ថ្ងៃទី ១៧ ខែ កុម្ភៈ ឆ្នាំ២០១០

លិខិតចូល
ថ្ងៃទី ១១ ខែមីនា ឆ្នាំ២០១០

សេចក្តីសម្រេច

ស្តីពី

ការបង្កើតក្រុមការងារសមាហរណកម្មមន្ត្រីរាជការនៃរចនាសម្ព័ន្ធ សាលារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌបច្ចុប្បន្ន នៅក្នុងរចនាសម្ព័ន្ធថ្មី

ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធាន គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២ នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៦ នស/៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈ មន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/ ០១៩៦/ ០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពី ការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពី ការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២០៨/១៤២៩ ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០០៨ ស្តីពីការបង្កើតគណៈកម្មាធិការជាតិ សម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោជាតិ
- យោងសេចក្តីណែនាំលេខ ០០៥ សណន ចុះថ្ងៃទី ១១ ខែ កុម្ភៈ ឆ្នាំ ២០១០ របស់ក្រសួងមហាផ្ទៃ ស្តីពីការធ្វើសមាហរណកម្ម រចនាសម្ព័ន្ធ និងមន្ត្រីរាជការដែលមានបច្ចុប្បន្ន នៅតាមសាលារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ទៅក្នុងរចនាសម្ព័ន្ធថ្មី

ស ម្រេ ច

ប្រការ ១ : ត្រូវបានបង្កើត**ក្រុមការងារ**សមាហរណកម្មមន្ត្រីរាជការនៃរចនាសម្ព័ន្ធសាលារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌបច្ចុប្បន្ន ទៅក្នុងរចនាសម្ព័ន្ធថ្មី ស្របទៅតាមគោលការណ៍ បែបបទ និងនីតិវិធី ដែលបានកំណត់ ។ ក្រុមការងារនេះ មាន សមាសភាពមកពីក្រសួង ស្ថាប័ន ដូចខាងក្រោម:

១-តំណាងលេខាធិការដ្ឋាន គ.ជ.អ.ប	ប្រធាន
២-តំណាងរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ	អនុប្រធាន
៣-តំណាងក្រសួងមហាផ្ទៃ	សមាជិកអចិន្ត្រៃយ៍
៤-តំណាងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ	សមាជិក
៥-តំណាងអគ្គលេខាធិការដ្ឋាននៃក្រុមប្រឹក្សាកំណែទម្រង់រដ្ឋបាល	សមាជិក ។

ក្រសួង ស្ថាប័នពាក់ព័ន្ធខាងលើ ត្រូវបញ្ជូនសមាសភាពក្រុមការងារ មកលេខាធិការដ្ឋាន គ.ជ.អ.ប ដើម្បីរៀបចំដាក់ជូន គ.ជ.អ.ប ពិនិត្យ និង សម្រេច ។

ប្រការ ២ : ក្រុមការងារខាងលើ មានតួនាទី ភារកិច្ចដូចខាងក្រោម :

- រៀបចំផ្សព្វផ្សាយដល់រាជធានី ខេត្ត អំពីដំណើរការធ្វើសមាហរណកម្មមន្ត្រីរាជការក្នុងរចនាសម្ព័ន្ធបច្ចុប្បន្នទៅក្នុងរចនាសម្ព័ន្ធថ្មី តាមការចាំបាច់
- ណែនាំ និងគាំទ្រផ្នែកបច្ចេកទេស ជំនាញ និងសមត្ថភាពដល់រាជធានី ខេត្តក្នុងដំណើរការសមាហរណកម្ម
- ចូលរួមក្នុងការតាមដាន ត្រួតពិនិត្យ និងវាយតំលៃទៅលើដំណើរការធ្វើសមាហរណកម្មមន្ត្រីរាជការទៅក្នុងរចនាសម្ព័ន្ធថ្មី របស់សាលារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បូកសរុបលទ្ធផល និងធ្វើរបាយការណ៍អំពីដំណើរការនៃការធ្វើសមាហរណកម្មមន្ត្រីរាជការនៅតាមសាលារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ទៅក្នុងរចនាសម្ព័ន្ធថ្មី ជូនលេខាធិការដ្ឋាន គ.ជ.អ.ប ដើម្បីរាយការណ៍ជូន គ.ជ.អ.ប
- បំពេញភារកិច្ចផ្សេងៗទៀត តាមការប្រគល់ភារកិច្ចពីប្រធានលេខាធិការដ្ឋាន គ.ជ.អ.ប ។

ប្រការ ៣ : ប្រធានលេខាធិការដ្ឋាន គ.ជ.អ.ប មានភារកិច្ចសម្របសម្រួលយន្តការរវាងក្រុមការងារខាងលើ ជាមួយរាជធានី ខេត្ត នៅក្នុងដំណើរការធ្វើសមាហរណកម្មមន្ត្រីរាជការទៅក្នុងរចនាសម្ព័ន្ធថ្មី ។

ប្រធានលេខាធិការដ្ឋាន គ.ជ.អ.ប ត្រូវសម្របសម្រួលរៀបចំសមាសភាពមន្ត្រីដែលពាក់ព័ន្ធសំខាន់ៗជាក់ស្តែងនៅតាមបណ្តាអង្គភាពនានាចំណុះក្រសួង ស្ថាប័នពាក់ព័ន្ធ ដើម្បីជួយគាំទ្រដល់ក្រុមការងារ និងរាជធានី ខេត្ត ក្នុងដំណើរការធ្វើសមាហរណកម្មនេះ ។

ប្រការ ៤ : ការចំណាយ សោហ៊ុយបេសកកម្ម និងមធ្យោបាយផ្សេងៗ ក្នុងការបំពេញភារកិច្ចរបស់ក្រុមការងារ ជាបន្ទុករបស់លេខាធិការដ្ឋាន គ.ជ.អ.ប ។

ប្រការ ៥ : លេខាធិការដ្ឋាន គ.ជ.អ.ប ក្រុមប្រឹក្សា និងគណៈអភិបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ សមាសភាពដូចមានក្នុងប្រការ១ខាងលើ និងអង្គភាពពាក់ព័ន្ធនានាចំណុះទីស្តីការក្រសួងមហាផ្ទៃ ត្រូវអនុវត្តសេចក្តីសម្រេចនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។៚

ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ
និងជាប្រធាន គ.ជ.អ.ប

ស ខេង

កន្លែងទទួល :

- *ទីស្តីការគណៈរដ្ឋមន្ត្រី*
- *ក្រសួង ស្ថាប័នដែលជាសមាជិក គ.ជ.អ.ប*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
  "ដើម្បីជូនជ្រាប"
- *ដូចប្រការ ៥ (ដើម្បីអនុវត្ត)*
- *ឯកសារ - កាលប្បវត្តិ*

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែប

ប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ (គ.ជ.អ.ប)

លេខ ០០២...៤៨...../គ.ជ.អ.ប

រាជធានីភ្នំពេញ, ថ្ងៃទី ១១. ខែ កុម្ភៈ ..ឆ្នាំ២០១០

លិខិតចូល

ថ្ងៃទី..១១....ខែ ៥៣...ឆ្នាំ ២០១០

ផែនការណែនាំ

ស្តីពី

សកម្មភាពសំខាន់ៗមួយចំនួន ក្នុងការអនុវត្តលិខិតបទដ្ឋានគតិយុត្ត សម្រាប់គាំទ្រដល់ដំណើរការកំណែទម្រង់រដ្ឋបាលថ្នាក់ក្រោមជាតិ

ក្នុងកិច្ចប្រជុំសាមញ្ញលើកទី៣ គ.ជ.អ.ប បានពិភាក្សាសំរេចលើសេចក្តីព្រាងលិខិតបទដ្ឋានគតិយុត្តចំនួន ០៩ សម្រាប់អនុវត្តច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ។ សេចក្តីព្រាងលិខិតបទដ្ឋានគតិយុត្ត ចំនួន ០៦ ត្រូវបានរាជរដ្ឋាភិបាលពិនិត្យ និងអនុម័តក្នុងកិច្ចប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី កាលពីថ្ងៃទី ២០ ខែ វិច្ឆិកា ឆ្នាំ ២០០៩។ ផ្អែកតាមលិខិតបទដ្ឋានដែលសំរេចដោយរាជរដ្ឋាភិបាល ក្រសួងមហាផ្ទៃក៏បានចេញប្រកាសចំនួន ០៣ លើមូលដ្ឋាននៃសេចក្តីព្រាង ដែលបានអនុម័តដោយ គ.ជ.អ.ប។ លិខិតបទដ្ឋានគតិយុត្តទាំង ០៩នេះ រួមមាន :

១- អនុក្រឹត្យ ស្តីពីការកំណត់ប្រាក់ឧបត្ថម្ភចំពោះសមាជិកក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ។

២- អនុក្រឹត្យ ស្តីពីតួនាទី ភារកិច្ច និង ទំនាក់ទំនងការងាររបស់ក្រុមប្រឹក្សា គណៈអភិបាលរាជធានីភ្នំពេញ និងក្រុមប្រឹក្សា គណៈអភិបាលខណ្ឌនៃរាជធានីភ្នំពេញ ។

៣- អនុក្រឹត្យ ស្តីពីតួនាទី ភារកិច្ច និងទំនាក់ទំនងការងាររបស់ក្រុមប្រឹក្សា គណៈអភិបាលខេត្ត ក្រុមប្រឹក្សា គណៈអភិបាលក្រុង និងក្រុមប្រឹក្សា គណៈអភិបាលស្រុក ។

៤- អនុក្រឹត្យ ស្តីពីការបង្កើត ការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈកម្មាធិការសម្របសម្រួលបច្ចេកទេសក្រុមប្រឹក្សារាជធានីភ្នំពេញ និងគណៈកម្មាធិការសម្របសម្រួលបច្ចេកទេសក្រុមប្រឹក្សាខណ្ឌ ។

៥- អនុក្រឹត្យ ស្តីពីការបង្កើត ការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈកម្មាធិការសម្របសម្រួលបច្ចេកទេស ក្រុមប្រឹក្សាខេត្ត គណៈកម្មាធិការសម្របសម្រួលបច្ចេកទេសក្រុមប្រឹក្សាក្រុង និងគណៈកម្មាធិការសម្របសម្រួលបច្ចេកទេសក្រុមប្រឹក្សាស្រុក ។

៦- អនុក្រឹត្យ ស្តីពីផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគបីឆ្នាំរំកិលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ។

៧- ប្រកាស ស្តីពីការបង្កើតការិយាល័យចំណុះទីចាត់ការនៃសាលារាជធានីភ្នំពេញ ការបង្កើតការិយាល័យនៃសាលាខណ្ឌ និងការកំណត់តួនាទី ភារកិច្ច របៀបរបបការងារនៃការិយាល័យទាំងនោះ ។

៨- ប្រកាស ស្តីពីការបង្កើតការិយាល័យចំណុះទីចាត់ការ នៃសាលាខេត្ត ការបង្កើតការិយាល័យ នៃសាលាក្រុង ការបង្កើតការិយាល័យនៃសាលាស្រុក និងការកំណត់តួនាទី ភារកិច្ច របៀបរបបការងារនៃការិយាល័យទាំងនោះ ។

៩- ប្រកាស ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រី និងកុមារនៅក្នុងក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ ។

អនុក្រឹត្យ និងប្រកាសខាងលើនេះ គឺជាលិខិតបទដ្ឋានគតិយុត្តដ៏សំខាន់ សម្រាប់ជាមូលដ្ឋានក្នុងការបង្កើត និងធ្វើស្ថាប័នភាវូបនីយកម្មនូវរចនាសម្ព័ន្ធ និងប្រព័ន្ធអភិបាលកិច្ចថ្មីនៅរដ្ឋបាលថ្នាក់ក្រោមជាតិ ស្របតាមគោលការណ៍នានាដែលបានកំណត់នៅក្នុងច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ។ លិខិតបទដ្ឋានគតិយុត្តខាងលើនេះ ចាំបាច់ត្រូវរៀបចំអនុវត្តដោយមានផែនការ មានដំណាក់កាល មានការពិគ្រោះពិភាក្សា ដើម្បីធានាឱ្យកំណែទម្រង់រដ្ឋបាលនៅថ្នាក់ក្រោមជាតិប្រព្រឹត្តទៅដោយរលូន ហើយមិនបង្កការរាំងស្ទះដល់ដំណើរការរដ្ឋបាល និងការអភិវឌ្ឍនៅថ្នាក់រដ្ឋបាលនីមួយៗ ។

ដើម្បីឆ្លើយតបសំណូមពរខាងលើ ប្រធាន គ.ជ.អ.ប ដាក់នូវផែនការណែនាំ អំពីផែនការ ដំណាក់កាល និងសកម្មភាពសំខាន់ៗ សម្រាប់អនុវត្តលិខិតបទដ្ឋានខាងលើនេះ តាមលំដាប់លំដោយការងារ និងពេលវេលា ដូចខាងក្រោម :

១-ការផ្សព្វផ្សាយលិខិតបទដ្ឋាននៅថ្នាក់ជាតិ : (មិនហួសពីដំណាច់ខែ មករា និងដើមខែ កុម្ភៈ ឆ្នាំ ២០១០)

គ.ជ.អ.ប នឹងរៀបចំផ្សព្វផ្សាយលិខិតបទដ្ឋានគតិយុត្តទាំង ០៩ខាងលើនេះ នៅថ្នាក់ជាតិ ក្នុងអំឡុង **សប្តាហ៍ទី៣** ខែ មករា ឆ្នាំ២០១០និងសប្តាហ៍ទី១ ខែ កុម្ភៈ ឆ្នាំ ២០១០ ។ សមាសភាព ដែលនឹងអញ្ជើញចូលរួមផ្សព្វផ្សាយនេះ រួមមាន :

- ប្រធានក្រុមការងារវិមជ្ឈការ និងវិសហមជ្ឈការ នៃក្រសួង ស្ថាប័ននានា
- មន្ត្រីបង្គោលសំខាន់ៗ ក្នុងលេខាធិការដ្ឋាន គ.ជ.អ.ប និងអង្គភាពពាក់ព័ន្ធនានាចំណុះទីស្តីការក្រសួងមហាផ្ទៃ
- សមាជិកក្រុមប្រឹក្សារាជធានី និង ខេត្ត
- គណៈអភិបាលរាជធានី និង ខេត្ត
- នាយខុទ្ទកាល័យសាលារាជធានី និង ខេត្ត
- ប្រធាន អនុប្រធានសម្ព័ន្ធភាពជាតិសមាគមក្រុមប្រឹក្សាឃុំ សង្កាត់ ។

ចំពោះនៅក្រុង ស្រុក ខណ្ឌ ការផ្សព្វផ្សាយនឹងត្រូវរៀបចំធ្វើ បន្ទាប់ពីការធ្វើសមាហរណកម្មមន្ត្រីរាជការទៅក្នុងរចនាសម្ព័ន្ធថ្មីរួចហើយ ដោយរៀបចំធ្វើជាមួយវគ្គបណ្តុះបណ្តាលតម្រង់ទិសតែម្តង។

លេខាធិការដ្ឋាន គ.ជ.អ.ប មានភារកិច្ចរៀបចំកម្មវិធី ខ្លឹមសារ និងកិច្ចដំណើរការនៃការផ្សព្វផ្សាយនេះ។

២_ការធ្វើសមាហរណកម្មមន្ត្រី បុគ្គលិកនៃសាលារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ទៅក្នុងរចនាសម្ព័ន្ធថ្មីនៃសាលារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ : (ខែ កុម្ភៈ និងមីនា ឆ្នាំ ២០១០)

ដើម្បីធានាឱ្យដំណើរការនៃការធ្វើសមាហរណកម្មមន្ត្រី បុគ្គលិក ក្នុងរចនាសម្ព័ន្ធបច្ចុប្បន្ននៃសាលារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ទៅក្នុងរចនាសម្ព័ន្ធថ្មី ប្រព្រឹត្តទៅដោយរលូន និងមានតម្លាភាព ស្របតាមស្មារតីអនុក្រឹត្យ និង ប្រកាសដែលពាក់ព័ន្ធ ក្រសួងមហាផ្ទៃត្រូវចេញ**សេចក្តីណែនាំមួយ** ដើម្បីកំណត់អំពីគោលការណ៍ ដំណាក់កាល និងបែបបទ នីតិវិធីនៃការធ្វើសមាហរណកម្មនេះ ។

ដោយសារដំណើរការ នៃការធ្វើសមាហរណកម្មត្រូវធ្វើឡើងក្នុងដំណាក់កាលដែលរាជរដ្ឋាភិបាលបានផ្អាកការតែងតាំង ដំឡើងឋានៈ ឋានន្តរសក្តិ និងថ្នាក់ ចំពោះមន្ត្រីសាធារណៈទាំងអស់ក្នុងឆ្នាំ២០១០នេះ ហេតុនេះ ក្រសួងមហាផ្ទៃត្រូវយក**សេចក្តីណែនាំ**នេះ ទៅធ្វើការពិគ្រោះ ពិភាក្សាជាមុន ជាមួយរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ និងអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាកំណែទម្រង់រដ្ឋបាលសាធារណៈ ។

សេចក្តីណែនាំរបស់ក្រសួងមហាផ្ទៃនេះ ត្រូវធ្វើការណែនាំ ផ្សព្វផ្សាយជាមុនដល់រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ មុននឹងដំណើរការធ្វើសមាហរណកម្ម ។ រាជធានី ខេត្តនីមួយៗត្រូវចាត់អភិបាលរងរាជធានី ខេត្ត ០១ និង នាយខុទ្ទកាល័យឱ្យទទួលបន្ទុក និងមានភារកិច្ចផ្សព្វផ្សាយ ណែនាំអំពីការធ្វើសមាហរណកម្មដល់ក្រុង ស្រុក ខណ្ឌ។

ចំពោះរាជធានី ខេត្ត នឹងរៀបចំធ្វើការផ្សព្វផ្សាយដូចមានកំណត់នៅក្នុងចំណុចទី ១។

៣_ការបង្កើតគណៈកម្មាធិការរបស់ក្រុមប្រឹក្សា : (ខែ កុម្ភៈ និង ខែ មិនា ឆ្នាំ២០១០)

រាជធានី ឬខេត្ត ឬក្រុង ឬស្រុក ឬខណ្ឌណា ដែលបានដំណើរការធ្វើសមាហរណកម្មមន្ត្រី បុគ្គលិកទៅក្នុងរចនាសម្ព័ន្ធថ្មីរួចរាល់ហើយ ចាំបាច់ត្រូវរួសរាន់បង្កើតគណៈកម្មាធិការ ដែលច្បាប់បានតម្រូវឱ្យបង្កើត ហើយដែលមានលិខិតបទដ្ឋានគតិយុត្តិ កំណត់អំពីការរៀបចំ និងការប្រព្រឹត្តទៅរួចរាល់ហើយ ។

ដើម្បីជួយសម្រួលដល់ការងារនេះ គ.ជ.អ.ប នឹងបង្កើតឱ្យមាន**ក្រុមការងារ**មួយ ដែលមានសមាសភាពតំណាងមកពីអនុគណៈកម្មាធិការមុខងារ និងធនធាន និងអនុគណៈកម្មាធិការបុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិ ដើម្បីជួយគាំទ្រដល់រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ក្នុងការបង្កើត និងដាក់ឱ្យដំណើរការនូវគណៈកម្មាធិការនានារបស់ក្រុមប្រឹក្សាស្របតាមច្បាប់ និងលិខិតបទដ្ឋានដែលបានកំណត់ ។

លេខាធិការដ្ឋាន គ.ជ.អ.ប ត្រូវជួយគាំទ្រដល់ការរៀបចំបង្កើតក្រុមការងារខាងលើនេះ រួមទាំងការគាំទ្រដល់សកម្មភាពរបស់ក្រុមការងារនេះ ។

៤_ការបណ្តុះបណ្តាលតម្រង់ទិស : (ខែ មេសា និង ខែ ឧសភា ឆ្នាំ២០១០)

បន្ទាប់ពីបានធ្វើសមាហរណកម្មមន្ត្រី បុគ្គលិកក្នុងរចនាសម្ព័ន្ធបច្ចុប្បន្ននៃសាលារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ទៅក្នុងរចនាសម្ព័ន្ធថ្មី និងការបង្កើតគណៈកម្មាធិការរបស់ក្រុមប្រឹក្សារួចហើយ ចាំបាច់ត្រូវរៀបចំនូវវគ្គបណ្តុះបណ្តាលតម្រង់ទិសដល់មន្ត្រី បុគ្គលិក និងសមាជិកគណៈកម្មាធិការនានា ដែលបានបង្កើតឡើង សំដៅធានាដល់ការចាប់ផ្តើមដំណើរការនៃរចនាសម្ព័ន្ធរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ស្របតាមច្បាប់រៀបចំអង្គការ និងអនុក្រឹត្យ ព្រមទាំងប្រកាសខាងលើនេះ ។

អាចមានវគ្គតម្រង់ទិសចំនួន **០២** ដែលត្រូវរៀបចំជាបន្ទាន់ បន្ទាប់ពីការធ្វើសមាហរណកម្ម និងការបង្កើតគណៈកម្មាធិការរួច គឺ :

មួយ : វគ្គបណ្តុះបណ្តាលតម្រង់ទិសសម្រាប់ក្រុមប្រឹក្សា គណៈអភិបាល ប្រធាន អនុប្រធានអង្គភាពទាំងអស់ក្នុងរចនាសម្ព័ន្ធថ្មី ។

ពីរ : វគ្គបណ្តុះបណ្តាលសម្រាប់សមាជិកសំខាន់ៗ នៅក្នុងគណៈកម្មាធិការនានារបស់ក្រុមប្រឹក្សា។

អនុគណៈកម្មាធិការបុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិ មានភារកិច្ចរៀបចំនូវវគ្គបណ្តុះបណ្តាលទាំងពីរនេះ ស្របតាមប្រព័ន្ធបណ្តុះបណ្តាលរបស់ គ.ជ.អ.ប ។

លេខាធិការដ្ឋាន គ.ជ.អ.ប មានភារកិច្ចធ្វើជាសេនាធិការជូនអនុគណៈកម្មាធិការបុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិ ក្នុងការរៀបចំផែនការបណ្តុះបណ្តាល ឯកសារ សំភារៈ គ្រូឧទ្ទេស និងការគាំទ្រដទៃទៀត ក្នុងការបណ្តុះបណ្តាលទាំងពីរខាងលើ ។

លេខាធិការដ្ឋាន គ.ជ.អ.ប ត្រូវធ្វើរបាយការណ៍អំពីការអនុវត្តការងារ តាមដំណាក់កាលនីមួយៗ ជូន គ.ជ.អ.ប ដើម្បីដឹកនាំ ណែនាំការអនុវត្តបន្តទៀត ។

ទទួលបានផែនការណែនាំនេះ អនុគណៈកម្មាធិការ គ.ជ.អ.ប លេខាធិការដ្ឋាន គ.ជ.អ.ប និងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ត្រូវសហការ សម្របសម្រួល អនុវត្តឱ្យទទួលបានប្រសិទ្ធភាពខ្ពស់ ។

ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ
និងជាប្រធាន គ.ជ.អ.ប

ស ខេង

ចម្លងជូន :

- ទីស្តីការគណៈរដ្ឋមន្ត្រី
- គ្រប់ក្រសួង ស្ថាប័នសមាជិក គ.ជ.អ.ប
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ